ធនាគារជាតិ នៃ កម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.



# របាយការណ៍ ប្រចាំឆ្នាំ ២០២២





# មាតិកា

* * *

**អារម្ភកថា** ........ i

**អក្សរកាត់** ........ vii

**ខ្លឹមសារសង្ខេប** ........ xi

**ផ្នែកទី១ - របាយការណ៍ប្រចាំឆ្នាំ២០២២**

I- **ស្ថានភាពសេដ្ឋកិច្ចពិភពលោក** ........ ១

II- **ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា** ........ ៥

១- កំណើនសេដ្ឋកិច្ច ........ ៥

២- ស្ថានភាពអតិផរណា ........ ៩

៣- អត្រាប្តូរប្រាក់ ........ ១១

៤- ស្ថានភាពជញ្ជីងទូទាត់ ........ ១៤

៥- ទុនបម្រុងអន្តរជាតិ ........ ១៦

III- **ការគ្រប់គ្រងរូបិយវត្ថុ** ........ ១៧

១- ស្ថានភាពរូបិយវត្ថុ ........ ១៧

២- ការអនុវត្តនយោបាយរូបិយវត្ថុ ........ ១៧

IV- **ស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជា** ........ ២៤

១- ស្ថានភាពទូទៅ ........ ២៤

២- វិស័យធនាគារ ........ ២៨

៣- វិស័យមីក្រូហិរញ្ញវត្ថុ ........ ២៩

៤- គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ........ ៣១

៥- គ្រឹះស្ថានឥណទានជនបទ ........ ៣១

៦- អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន ........ ៣២

៧- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ........ ៣៣

V- **បរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន** ........ ៣៤

១- បរិយាបន្នហិរញ្ញវត្ថុ ........ ៣៤

២- ការអប់រំផ្នែកហិរញ្ញវត្ថុ ........ ៣៥

៣- កិច្ចការពារអតិថិជន ........ ៣៦

VI- **ការផ្គត់ផ្គង់សេវាធនាគារកណ្តាល** ........ ៣៧

១- ប្រព័ន្ធទូទាត់សងប្រាក់ ........ ៣៧

២- សេវាគ្រប់គ្រងគណនី ........ ៤៤

៣- ការគ្រប់គ្រងចរាចរណ៍ធនបត្រ ........................................................................ ៤៤
VII- **ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម** .............................................. ៤៧
១- ការពង្រឹងក្របខ័ណ្ឌនិងការអនុវត្តច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ........................................................................ ៤៧
២ -ការងារវិភាគ និងបញ្ជូនរបាយការណ៍ ........................................................................ ៤៨
៣- កិច្ចសហប្រតិបត្តិការរបស់ ស.ហ.ក ........................................................................ ៤៨
៤- ការបណ្តុះបណ្តាលនិងការផ្សព្វផ្សាយ ........................................................................ ៥០
VIII- **កិច្ចសហប្រតិបត្តិការអន្តរជាតិ** ........................................................................ ៥១
១- កិច្ចសហប្រតិបត្តិការពហុភាគី ........................................................................ ៥១
២- កិច្ចសហប្រតិបត្តិការទ្វេភាគី ........................................................................ ៥៤
IX- **ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា** ........................................................................ ៥៦
១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល ........................................................................ ៥៦
២- ការអភិវឌ្ឍធនធានមនុស្ស ........................................................................ ៥៧
៣- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ ........................................................................ ៥៩
៤- សាខាធនាគារជាតិនៃកម្ពុជា ........................................................................ ៥៩
**សន្និដ្ឋាន** ........................................................................ ៦០
**ផ្នែកទី២ - ទស្សនវិស័យ និងទិសដៅការងារឆ្នាំ២០២៣**
១- ការអនុវត្តនយោបាយរូបិយវត្ថុ ........................................................................ ៦៣
២- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ........................................................................ ៦៤
៣- ប្រព័ន្ធទូទាត់សងប្រាក់ ........................................................................ ៦៤
៤- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........................................................................ ៦៤
៥- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ........................................................................ ៦៥
៦- ការងារប្រតិបត្តិការ ........................................................................ ៦៥
៧- ការងារបោះផ្សាយនិងឃ្លាំងបេឡា ........................................................................ ៦៦
៨- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ ........................................................................ ៦៦
៩- ការគ្រប់គ្រងសាខា ........................................................................ ៦៦
១០- គណនេយ្យ ........................................................................ ៦៦
១១- ការគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស ........................................................................ ៦៧
១២- កិច្ចសហប្រតិបត្តិការអន្តរជាតិ ........................................................................ ៦៧
១៣- ការស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ច ........................................................................ ៦៧
១៤ -ការងារស្ថិតិ ........................................................................ ៦៨

**ផ្នែកទី៣ - ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធ ១ តារាង ១ -ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវា ........................ ៦៩
ឧបសម្ព័ន្ធ ២ តារាង ២ -ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ (អត្រាទិញចុងខែ)...... ៧០
ឧបសម្ព័ន្ធ ៣ តារាង ៣ -ស្ថិតិស្ថានភាពធនាគារកណ្តាល ............................................... ៧១
ឧបសម្ព័ន្ធ ៤ តារាង ៤ -ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត ................. ៧២
ឧបសម្ព័ន្ធ ៥ តារាង ៥ -ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើ.................................. ៧៣
ឧបសម្ព័ន្ធ ៦ តារាង ៦ -ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត.............................. ៧៤
ឧបសម្ព័ន្ធ ៧ តារាង ៧ -ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុ ............................................ ៧៥
ឧបសម្ព័ន្ធ ៨ តារាង ៨ -ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច.......................... ៧៦
ឧបសម្ព័ន្ធ ៩ តារាង ៩ -សរុបប្រតិបត្តិការប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ..................... ៧៧
ឧបសម្ព័ន្ធ ១០ តារាង ១០ -ជញ្ជីងទូទាត់ប្រទេសកម្ពុជា .................................................. ៧៨
ឧបសម្ព័ន្ធ ១១ តារាង ១១ -បណ្តាញព័ត៌មានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុពីឆ្នាំ ២០១៧ - កញ្ញា ២០២២ ......................................................................................... ៧៩
ឧបសម្ព័ន្ធ ១២ បញ្ជីលេខទូរសព្ទទំនាក់ទំនងអំពីចម្ងល់និងបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ ........................................................................................ ៨១

# អារម្ភកថា

នៅឆ្នាំ២០២២ ការរាលដាលនៃជំងឺកូវីដ-១៩ លើពិភពលោកមានភាពធូរស្រាល ហើយប្រទេសនានាបានបើកដំណើរការសេដ្ឋកិច្ចឡើងវិញជាលំដាប់ ដែលបានគាំទ្រដល់ការងើបឡើងនៃសេដ្ឋកិច្ច លើកលែងតែប្រទេសចិន ដែលនៅបន្តអនុវត្តវិធានការគ្មានកូវីដ (Zero Covid Policy) យ៉ាងតឹងរ៉ឹង។ ប៉ុន្តែ ពិភពលោកបានជួបប្រទះនឹងវិបត្តិភូមិសាស្ត្រនយោបាយ ដោយសារសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលបានបង្កឱ្យមានការឡើងថ្លៃប្រេងឥន្ធនៈនិងម្ហូបអាហារជាសកល។ ការអូសបន្លាយនៃសង្គ្រាមនេះ បានធ្វើឱ្យអតិផរណាជារួមកើនឡើងខ្ពស់យ៉ាងឆាប់រហ័ស បន្ថែមទៅលើនិន្នាការកើនឡើងស្រាប់ពីកត្តាតម្រូវការដោយសារការងើបឡើងនៃសេដ្ឋកិច្ចពិភពលោក។ នៅក្នុងស្ថានភាពប្រឈមថ្មីនេះ ប្រទេសនានាបានអនុវត្តនយោបាយរូបិយវត្ថុរឹតត្បិត ដើម្បីគ្រប់គ្រងសម្ពាធអតិផរណាដែលមានប្រភពចេញពីកត្តាផ្គត់ផ្គង់ តាមរយៈការបង្កើនអត្រាការប្រាក់គោល ខណៈដែលលំហនយោបាយសារពើពន្ធបានរួមតូច។ ធនាគារកណ្តាលអាមេរិកបានដំឡើងអត្រាការប្រាក់គោលលឿនជាងការរំពឹងទុក ដែលបណ្តាលឱ្យមូលធនហូរចូលទៅសហរដ្ឋអាមេរិក ស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិមានភាពរឹតត្បិត និងថ្លៃរូបិយប័ណ្ណរបស់ប្រទេសជាច្រើនធ្លាក់ចុះ។ ជាការឆ្លើយតបធនាគារកណ្តាលភាគច្រើនបានធ្វើអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ ដើម្បីទប់ទល់នឹងសម្ពាធធ្លាក់ថ្លៃនៃរូបិយប័ណ្ណរបស់ប្រទេសខ្លួន ដែលជាលទ្ធផលធ្វើឱ្យទុនបម្រុងអន្តរជាតិរបស់ប្រទេសមួយចំនួនស្រុតចុះគួរឱ្យកត់សម្គាល់។ ថ្វីត្បិតតែការអនុវត្តវិធានការទាំងនេះ បានបន្ទាបអត្រាអតិផរណាបានមួយកម្រិត ប៉ុន្តែនិន្នាការនៃអតិផរណាមានភាពមិនច្បាស់លាស់នៅឡើយ ស្របពេលដែលធនាគារកណ្តាលអាមេរិកអាចបន្តយុទ្ធនាការប្រឆាំងអតិផរណា តាមរយៈការបង្កើនអត្រាការប្រាក់គោលថែមទៀត ដែលបាននាំឱ្យកំណើនសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០២២ ទាបជាងការព្យាករកាលពីដើមឆ្នាំ ហើយកំណើនសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០២៣ អាចប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់។

នៅកម្ពុជា អតិផរណាបានកើនឡើង ជាពិសេសនាពាក់កណ្តាលឆ្នាំ ដោយសារការឡើងថ្លៃប្រេងឥន្ធនៈនិងម្ហូបអាហារ ខណៈដែលតម្រូវការក្នុងស្រុកកើនឡើងស្រាប់ ក្នុងស្ថានភាពដែលសេដ្ឋកិច្ចក្នុងស្រុកបានវិលទៅរកប្រក្រតីភាពវិញ។ ក៏ប៉ុន្តែ អតិផរណាបានថយចុះជាលំដាប់នៅក្នុងឆមាសទី២ បន្ទាប់ពីថ្លៃក្រុមទំនិញទាំងពីរនេះបានថយចុះ ដែលធ្វើឱ្យអត្រាអតិផរណាមធ្យមប្រចាំឆ្នាំ២០២២ មានកម្រិតត្រឹម ៥,៣% ដែលមិនប៉ះពាល់ខ្លាំងដល់ការវិនិយោគ ផលិតកម្ម និងការប្រើប្រាស់ក៏ដូចជាជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។ ជាមួយគ្នានេះ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកត្រូវបានរក្សាឱ្យមានស្ថិរភាព ដើម្បីការពារអំណាចទិញរបស់ប្រាក់ចំណូលប្រជាជន បើទោះបីជាប្រាក់ដុល្លារអាមេរិកមាននិន្នាការឡើងថ្លៃនៅលើទីផ្សារអន្តរជាតិក៏ដោយ។ ការរក្សាបានស្ថិរភាពតម្លៃប្រាក់រៀលបានរួមចំណែកយ៉ាងសំខាន់ក្នុងការបន្ថយសម្ពាធអតិផរណា ដោយបន្ទាបថ្លៃទំនិញនាំចូលបានមួយកម្រិត។ គួររំលេចថា ធនាគារជាតិនៃកម្ពុជាបានសម្រេចកំណត់យកអត្រាប្តូរប្រាក់ផ្លូវការ តាមរយៈការគណនាអត្រាប្តូរប្រាក់មធ្យមថ្លឹង នៃប្រតិបត្តិការប្តូរប្រាក់ជាក់ស្តែងប្រចាំថ្ងៃ នៅលើ

ផ្លែតហ្វមធនាគារជាតិនៃកម្ពុជា (NBCP) ដែលផ្តល់នូវអត្រាប្តូរប្រាក់មួយផ្អែកលើយន្តការទីផ្សារ មានតម្លាភាព និងប្រសិទ្ធភាព។

ការសម្រេចបានស្ថិរភាពអត្រាប្តូរប្រាក់ គឺដោយសារការអនុវត្តនយោបាយរូបិយវត្ថុនិងអត្រាប្តូរប្រាក់ប្រកបដោយភាពប្រុងប្រយ័ត្ន និងបានថ្លឹងថ្លែងលើការរួមចំណែកគាំទ្រការរីកចម្រើននៃសេដ្ឋកិច្ច។ ប្រាក់រៀលត្រូវបានបញ្ចេញក្នុងបរិមាណសមស្របឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុខ្ចីក្នុងអត្រាការប្រាក់ទាបតាមរយៈការដេញថ្លៃ ដើម្បីរក្សាស្ថិរភាពអត្រាការប្រាក់ជារៀល ហើយអត្រាប្រាក់បម្រុងកាតព្វកិច្ចត្រូវបានបន្តរក្សាក្នុងកម្រិតទាប ដើម្បីផ្តល់សន្ទនីយភាពបន្ថែមដល់ប្រព័ន្ធធនាគារ។ ទន្ទឹមនេះ ការស្រូបយកសន្ទនីយភាពលើសមកវិញ ទាំងជាប្រាក់រៀលនិងដុល្លារអាមេរិកត្រូវបានធ្វើឡើងតាមរយៈការចេញផ្សាយមូលបត្រអាចជួញដូរបាន សំដៅរក្សាតុល្យភាពរវាងតម្រូវការនិងការផ្គត់ផ្គង់សន្ទនីយភាព។ គួររំលេចថា ការធ្វើអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ត្រូវបានធ្វើឡើងក្នុងទំហំបន្តិចបន្តួចប៉ុណ្ណោះ តាមផ្លែតហ្វម NBCP ដោយសារឧបករណ៍នយោបាយរូបិយវត្ថុនានាបានរួមចំណែកកាន់តែសកម្មក្នុងការរក្សាស្ថិរភាពអត្រាប្តូរប្រាក់។ ការធ្វើអន្តរាគមន៍ក្នុងកម្រិតទាប និងការគ្រប់គ្រងទុនបម្រុងប្រកបដោយភាពប្រុងប្រយ័ត្ន បានធ្វើឱ្យទុនបម្រុងអន្តរជាតិរក្សាបានកម្រិតខ្ពស់គ្រប់គ្រាន់ បើទោះបីជាបានថយចុះដោយសាររងសម្ពាធពីការប្រែប្រួលនៃស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិក៏ដោយ។ នៅក្នុងឆ្នាំនេះ រាជរដ្ឋាភិបាលបានបោះផ្សាយមូលបត្ររដ្ឋជាប្រាក់រៀលឡើងវិញ បន្ទាប់ពីអាក់ខានមួយរយៈមក។ មូលបត្ររដ្ឋនឹងក្លាយជាឧបករណ៍នយោបាយរូបិយវត្ថុថ្មីមួយទៀតនាពេលអនាគត ដែលនឹងលើកកម្ពស់ប្រសិទ្ធភាពនយោបាយរូបិយវត្ថុ ក្នុងស្ថានភាពដែលដុល្លារូបនីយកម្មនៅមានកម្រិតខ្ពស់នៅឡើយ។

កម្រិតសមស្របនៃអត្រាអតិផរណា ស្ថិរភាពអត្រាប្តូរប្រាក់រៀល និងការរក្សាបានកម្រិតខ្ពស់គ្រប់គ្រាន់នៃទុនបម្រុងអន្តរជាតិ បានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាលំនឹងម៉ាក្រូសេដ្ឋកិច្ច និងទំនុកចិត្តវិនិយោគិនមកលើសេដ្ឋកិច្ចកម្ពុជា។ បរិយាកាសអំណោយផលនេះបានបន្តគាំទ្រសេដ្ឋកិច្ចកម្ពុជាឱ្យរីកចម្រើនថែមទៀត។ លើសពីនេះ ប្រព័ន្ធធនាគារកម្ពុជាបានដើរតួនាទីកាន់តែសកម្មក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចនិងការរក្សាស្ថិរភាពហិរញ្ញវត្ថុ ទាំងក្នុងនិងក្រោយវិបត្តិកូវីដ-១៩។ ជាក់ស្តែង ការបន្ធូរបន្ថយបទប្បញ្ញត្តិម៉ាក្រូនិងមីក្រូប្រុងប្រយ័ត្នមួយចំនួនចាប់តាំងពីឆ្នាំ២០២០មក បានបង្កើនសន្ទនីយភាពនៅក្នុងប្រព័ន្ធធនាគារ និងរក្សាបាននូវនិរន្តរភាពនៃការបែងចែកឥណទានដល់វិស័យនានា សំដៅគាំទ្រដល់ការវិនិយោគនិងការប្រើប្រាស់។ ប៉ុន្តែ ក្នុងស្ថានភាពដែលសេដ្ឋកិច្ចប្រឈមនឹងភាពមិនច្បាស់លាស់ កំណើនឥណទានខ្ពស់ក៏អាចភ្ជាប់មកជាមួយនូវហានិភ័យនៃការគរពូនបំណុលលើសលប់ និងកំណើនឥណទានមិនដំណើរការផងដែរ។ ហេតុដូច្នេះ ការត្រួតពិនិត្យប្រព័ន្ធធនាគារត្រូវបានបន្តពង្រឹងជាប្រចាំ ផ្អែកលើហានិភ័យនិងទស្សនៈអនាគត ស្របតាមស្តង់ដារអន្តរជាតិ ទន្ទឹមនឹងការធ្វើស្ត្រេសតេស្តលើភាពរឹងមាំនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ម្យ៉ាងទៀត កិច្ចការពារអតិថិជននិងចំណេះដឹងផ្នែកហិរញ្ញវត្ថុក៏ត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់ ដើម្បីពង្រឹងការប្រើប្រាស់ឥណទានប្រកបដោយការទទួលខុសត្រូវ និងទាញយកអត្ថប្រយោជន៍ពីវិស័យហិរញ្ញវត្ថុជាអតិបរមា

ក្នុងការលើកស្ទួយជីវភាពរស់នៅ។ គួររំលេចថា ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ ប្រព័ន្ធចែករំលែកព័ត៌មានឥណទានដែលផ្ដួចផ្ដើមឡើងដោយធនាគារជាតិនៃកម្ពុជា បានរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងការគ្រប់គ្រងហានិភ័យឥណទាន លើកកម្ពស់តម្លាភាព និងបន្ថយអត្រាការប្រាក់ឥណទាន។

ក្នុងអំឡុងពេលវិបត្តិកូវីដ-១៩ ការរៀបចំឥណទានឡើងវិញបានជួយជ្រោងដំណើរការក៏ដូចជាការរស់រានរបស់អាជីវកម្ម និងសម្រួលដល់ការលំបាករបស់ប្រជាជនក្នុងការសងប្រាក់នៅពេលដែលប្រាក់ចំណូលធ្លាក់ចុះ។ ដោយសារសេដ្ឋកិច្ចបានងើបឡើងជាលំដាប់ ទំហំទឹកប្រាក់នៃការរៀបចំឥណទានឡើងវិញបានថយចុះជាបន្តបន្ទាប់។ ក្នុងស្ថានភាពនេះ ការបន្តរៀបចំឥណទានឡើងវិញត្រូវបានអនុញ្ញាតត្រឹមពាក់កណ្ដាលឆ្នាំ២០២២ ចំពោះអតិថិជនដែលមិនធ្លាប់ត្រូវបានរៀបចំឥណទានឡើងវិញ ហើយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានតម្រូវឱ្យធ្វើសំវិធានធន ចំពោះឥណទានរៀបចំឡើងវិញតាមចំណាត់ថ្នាក់ជាក់ស្ដែង។ ទោះយ៉ាងណា ធនាគារជាតិនៃកម្ពុជាក៏បានអនុញ្ញាតឱ្យមានការរៀបចំឥណទានឡើងវិញសម្រាប់ប្រជាពលរដ្ឋ ដែលទទួលរងគ្រោះដោយទឹកជំនន់ដែលការរៀបចំឥណទាននេះជារួមមានកម្រិតទាបប៉ុណ្ណោះ។ ការបញ្ចប់កម្មវិធីរៀបចំឥណទានឡើងវិញគឺជាផ្នែកមួយនៃការអនុវត្តយុទ្ធសាស្ត្រចាកចេញពីវិបត្តិ ដែលត្រូវបានអនុវត្តឡើងស្របតាមស្ថានភាពជាក់ស្ដែង។

ដោយសារផលប៉ះពាល់ពីវិបត្តិកូវីដ-១៩នៅបន្តមាន ដូចជា ការគរពូនបំណុលរបស់ក្រុមហ៊ុន-សហគ្រាសនិងអង្គភាពគ្រួសារ កំណើនខ្ពស់នៃឥណទាននៅតែជាហានិភ័យចម្បងមួយចំពោះប្រព័ន្ធធនាគារ ជាពិសេសក្នុងពេលដែលឥណទានមិនដំណើរការមាននិន្នាការកើនឡើង។ ជាមួយគ្នានេះ បញ្ហាប្រឈមខាងក្រៅក៏បានកើនឡើងផងដែរ ដោយសារការដំឡើងអត្រាការប្រាក់គោលនៅសហរដ្ឋអាមេរិក និងការរឹតត្បិតស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ដែលបាននិងកំពុងដាក់សម្ពាធដល់អត្រាការប្រាក់ឥណទាននិងលទ្ធភាពទទួលបានប្រភពទុនពីក្រៅប្រទេស។ កន្លងមក ដោយសារប្រព័ន្ធធនាគារនៅមានសន្ទនីយភាពខ្ពស់ អត្រាការប្រាក់បានកើនឡើងបន្តិចបន្តួចប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើអត្រាការប្រាក់នៅលើទីផ្សារអន្តរជាតិបន្តកើនឡើងថែមទៀតក្នុងរយៈពេលយូរ នោះអត្រាការប្រាក់នៅកម្ពុជាក៏នឹងរងសម្ពាធកើនឡើងផងដែរនាពេលខាងមុខ។ ក្នុងស្ថានភាពនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុគួរខិតខំប្រឹងប្រែងធ្វើពិពិធកម្មប្រភពទុន ក៏ដូចជាប្រភពចំណូល តាមរយៈការខ្ចីឬផ្ដល់ឥណទាននៅលើទីផ្សារអន្តរធនាគារក្នុងស្រុកនិងការផ្ដល់សេវាហិរញ្ញវត្ថុថ្មីៗ ដែលឆ្លើយតបនឹងតម្រូវការទីផ្សារ។

ដោយឡែក ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ជាពិសេសប្រព័ន្ធទូទាត់ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសម្រួលដល់ការទូទាត់នៅក្នុងសេដ្ឋកិច្ចឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងឆាប់រហ័ស។ ដោយនិន្នាការនៃការប្រើប្រាស់បច្ចេកវិទ្យាបន្តកើនឡើងឥតឈប់ឈរ និងអាចក្លាយជាប្រភពកំណើនសេដ្ឋកិច្ចថ្មីមួយដ៏សំខាន់ ប្រព័ន្ធទូទាត់ត្រូវបានបន្តអភិវឌ្ឍឱ្យកាន់តែប្រសើរឡើង ដើម្បីសម្រួលដល់ការទូទាត់ឆ្លងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការតភ្ជាប់ជាមួយប្រទេសផ្សេងទៀតនៅក្នុងតំបន់ សំដៅរួមចំណែកលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគ ទេសចរណ៍ និងការបង្វែរប្រាក់

ពីក្រៅប្រទេស។ អត្ថប្រយោជន៍នៃទំនើបកម្មប្រព័ន្ធទូទាត់ ត្រូវបានបង្ហាញយ៉ាងជាក់ស្បាន់ក្នុងអំឡុងពេលបិទខ្ទប់ ដោយបានគាំទ្រដល់ដំណើរការអាជីវកម្មនានាតាមប្រព័ន្ធអនឡាញ និងវិធានការគាំពារសង្គម-សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលក្នុងការផ្ទេរប្រាក់ឧបត្ថម្ភដល់កម្មករ-និយោជិតនិងប្រជាពលរដ្ឋក្រីក្រនិងងាយរងគ្រោះ បានយ៉ាងឆាប់រហ័សនិងមានតម្លាភាព។ លើសពីនេះ ប្រព័ន្ធទូទាត់បាគងនិងខេអេចឃ្យូអរ (KHQR) បាននិងកំពុងលើកមុខមាត់នៃប្រព័ន្ធទូទាត់កម្ពុជានៅលើឆាកអន្តរជាតិចំពោះភាពច្នៃប្រឌិតនិងនវានុវត្តន៍ខ្ពស់ និងការជំរុញបរិយាបន្នហិរញ្ញវត្ថុ។ ទោះយ៉ាងណាការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ ក៏អាចនាំមកនូវហានិភ័យ ដូចជា បញ្ហាឧក្រិដ្ឋកម្មបច្ចេកវិទ្យា (Cybercrime) ដែលតម្រូវឱ្យមានការពង្រឹងបទប្បញ្ញត្តិគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា និងការប្រុងប្រយ័ត្នខ្ពស់ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងតាមដានយ៉ាងយកចិត្តទុកដាក់ពីនិន្នាការនៃការអភិវឌ្ឍរូបិយប័ណ្ណឌីជីថលធនាគារកណ្តាល (CBDC) នៅក្នុងពិភពលោកនិងតំបន់ ដើម្បីថ្លឹងថ្លែងពីសក្តានុពលនិងហានិភ័យនៃរូបិយប័ណ្ណឌីជីថល សម្រាប់ជាប្រយោជន៍ក្នុងការអភិវឌ្ឍរូបិយប័ណ្ណនេះនាពេលខាងមុខ ប្រសិនបើមានតម្រូវការចាំបាច់។

វិបត្តិកូវីដ-១៩និងបញ្ហាប្រឈមដែលបានកើតមានជាបន្តបន្ទាប់បានគូសបញ្ជាក់ពីសារៈសំខាន់នៃការពង្រឹងសមាហរណកម្មនិងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់ ដើម្បីរក្សាភាពធន់នៃសេដ្ឋកិច្ចប្រឈមនឹងវិបត្តិ និងស្វែងរកសក្តានុពលថ្មីៗ ក្នុងការពង្រឹងពាណិជ្ជកម្ម ការវិនិយោគ និងការអភិវឌ្ឍទីផ្សារមូលធន ក៏ដូចជាការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក។ ក្នុងនាមកម្ពុជាជាប្រធានអាស៊ានឆ្នាំ២០២២ ធនាគារជាតិនៃកម្ពុជាបានដឹកនាំនិងសហការដឹកនាំកិច្ចប្រជុំនានាពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ ដើម្បីជំរុញសេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុអាស៊ាន សមាហរណកម្មវិស័យធនាគារ បរិយាបន្នហិរញ្ញវត្ថុ ហិរញ្ញប្បទានប្រកបដោយចីរភាព និងការទូទាត់ឆ្លងដែន។ ដូចគ្នានេះដែរ ធនាគារជាតិនៃកម្ពុជាក៏បានធ្វើជាសហប្រធានដឹកនាំកិច្ចប្រជុំអាស៊ាន+៣ សំដៅពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់ សមត្ថភាពអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ក្នុងការតាមដានស្ថានភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសសមាជិក និងការជំរុញការចេញផ្សាយសញ្ញាប័ណ្ណក្នុងតំបន់អាស៊ាន+៣។ ក្នុងនាមជាប្រធានប្តូរវេនឆ្នាំ២០២៣ នៃក្រុមប្រឹក្សាភិបាលនៃទេសាភិបាលស៊ាសិន (BOG) ធនាគារជាតិនៃកម្ពុជានឹងបន្តរួមចំណែកកំណត់ទិសដៅយុទ្ធសាស្រ្តក្នុងការអភិវឌ្ឍសមត្ថភាពជំនាញនិងការស្រាវជ្រាវក្នុងតំបន់។

ដោយឡែក ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម មានសារៈសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។ ការពង្រឹងក្របខ័ណ្ឌនិងការអនុវត្តច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការពង្រីកវិសាលភាពនៃសហប្រតិបត្តិការជាមួយអាជ្ញាធរនិងភាគីពាក់ព័ន្ធទាំងក្នុងស្រុកនិងអន្តរជាតិ បាននិងកំពុងបង្កើនប្រសិទ្ធភាព ដើម្បីធានាថាកម្ពុជាមិនមែនជាគោលដៅនៃបទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនោះទេ។

នៅឆ្នាំ២០២២នេះ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថាមានកំណើន ៥,១% ដែលគាំទ្រជាចម្បងដោយការនាំចេញផលិតផលកម្មន្តសាល ការងើបឡើងលឿននៃវិស័យទេសចរណ៍ និងការវិលមករកប្រក្រតីភាពឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក។ ទន្ទឹមនេះ វិស័យសំណង់និងអចលនទ្រព្យបានងើបឡើងវិញ ខណៈដែលវិស័យកសិកម្មបន្តកើនឡើងក្នុងល្បឿនយឺត។ សម្រាប់ឆ្នាំ២០២៣ សេដ្ឋកិច្ចកម្ពុជារំពឹងថានឹងបន្តកើនក្នុងរង្វង់ ៦% ហើយអត្រាអតិផរណាត្រូវបានព្យាករថានឹងថយចុះមកកម្រិតទាបវិញក្នុងអត្រា ២,៥% ដោយសារថ្លៃប្រេងឥន្ធនៈអាចថមថយក្នុងបរិការណ៍នៃកំណើនយឺតជាងមុននៃសេដ្ឋកិច្ចពិភពលោក និងភាពប្រសើរឡើងនៃខ្សែច្រវាក់ផ្គត់ផ្គង់សកល។ ទុនបម្រុងអន្តរជាតិរំពឹងថានឹងកើនឡើងវិញបន្តិច ដែលអាចធានាការនាំចូលទំនិញនិងសេវាបានប្រមាណ ៧ខែ ស្របពេលដែលភាពរឹងមាំនៃប្រព័ន្ធធនាគារនឹងបន្តរួមចំណែកផ្តល់ថាមភាពដល់កំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ។ ទោះយ៉ាងណា សេដ្ឋកិច្ចកម្ពុជាក៏ត្រូវប្រឈមនឹងហានិភ័យមួយចំនួន រួមមាន៖ i/-ការថមថយកំណើនសេដ្ឋកិច្ចនៅបណ្តាប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា ដែលអាចប៉ះពាល់ដល់ពាណិជ្ជកម្ម ការវិនិយោគ និងការងើបឡើងនៃវិស័យទេសចរណ៍ ii/-ភាពរឹតត្បិតនៃស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ដោយសារការដំឡើងអត្រាការប្រាក់គោលនៅប្រទេសអភិវឌ្ឍន៍ ដែលអាចដាក់សម្ពាធលើថ្លៃដើមនៃការខ្ចីពីក្រៅប្រទេសនិងលំហូរវិនិយោគមកកម្ពុជា iii/-ការឡើងថ្លៃប្រាក់ដុល្លារអាមេរិក ដែលអាចដាក់សម្ពាធលើភាពប្រកួតប្រជែងលើការនាំចេញរបស់កម្ពុជា និងការចំណាយរបស់ភ្ញៀវទេសចរដោយសារតែកម្រិតខ្ពស់នៃដុល្លារូបនីយកម្ម ព្រមទាំងអាចបង្កជាសម្ពាធលើស្ថិរភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក iv/-ភាពមិនច្បាស់លាស់នៃថ្លៃប្រេងអន្តរជាតិនិងថ្លៃវត្ថុធាតុដើមកសិកម្ម ដោយសារការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលអាចមានឥទ្ធិពលលើអត្រាអតិផរណាកម្ពុជា និងបង្កើនចំណាយនាំចូល v/-បញ្ហាសេដ្ឋកិច្ច-សង្គមបន្សល់ទុកដោយវិបត្តិកូវីដ-១៩ ដែលអាចដាក់បន្ទុកលើសក្តានុពលនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យមនិងវែង ដូចជា ការផ្លាស់ប្តូររចនាសម្ព័ន្ធការងារ និងការកើនឡើងនៃភាពក្រីក្រនិងវិសមភាពសង្គម vi/-ការប្រែប្រួលអាកាសធាតុដែលអាចប៉ះពាល់ខ្លាំងដល់វិស័យកសិកម្ម និង vii/-លទ្ធភាពនៃការកើតមានមេរោគកូវីដ-១៩ បំប្លែងថ្មី ដែលមានភាពស៊ាំនឹងវ៉ាក់សាំង។

ឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តចូលរួមគាំទ្រគោល-នយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារនិងកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច សំដៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ នយោបាយរូបិយវត្ថុនឹងបន្តអនុវត្តប្រកបដោយស្មារតីបុរេសកម្ម ទន់ភ្លន់ និងប្រុងប្រយ័ត្ន។ យុទ្ធសាស្ត្រចាកចេញពីវិបត្តិនឹងត្រូវធ្វើឡើងតាមការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពង្រឹងទ្រនាប់គោលនយោបាយសម្រាប់ឆ្លើយតបនឹងការប៉ះទង្គិចជាយថាហេតុនាពេលអនាគត។ សេវាហិរញ្ញវត្ថុនិងប្រព័ន្ធទូទាត់នឹងត្រូវបន្តធ្វើទំនើបកម្ម ស្របតាមការផ្លាស់ប្តូរនៃដំណើរការប្រព័ន្ធសេដ្ឋកិច្ចនិងសង្គម ដែលពឹងផ្អែកកាន់តែខ្លាំងជាងមុនទៅលើប្រព័ន្ធឌីជីថល ទន្ទឹមនឹងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងឌីជីថលដល់ប្រជាពលរដ្ឋ។ ការបន្តពង្រឹងនិងពង្រីកផលិតផលនិងសេវាហិរញ្ញវត្ថុថ្មីៗ នឹងបង្កើនបរិយាបន្នហិរញ្ញវត្ថុ ដែលកន្លងមកបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន។ ប្រព័ន្ធធនាគារកម្ពុជា

នឹងបន្តអនុវត្តគោលការណ៍ហិរញ្ញប្បទានបៃតងនិងប្រកបដោយចីរភាព តាមរយៈការផ្តល់ហិរញ្ញប្បទានដល់គម្រោងវិនិយោគដែលគិតគូរដល់គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG)។ ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាធនាគារកណ្តាល អាជ្ញាធររូបិយវត្ថុ និងស្ថាប័នហិរញ្ញវត្ថុនានា ទាំងក្នុងក្របខ័ណ្ឌទ្វេភាគីនិងពហុភាគី ជាពិសេសក្នុងក្របខ័ណ្ឌអាស៊ាន អាស៊ាន+៣ ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ និងដៃគូយុទ្ធសាស្ត្រនានា ដើម្បីពង្រឹងសហប្រតិបត្តិការ សមាហរណកម្ម និងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុ សំដៅគាំទ្រកំណើននិងបង្កើនភាពធន់នៃសេដ្ឋកិច្ចទល់នឹងវិបត្តិ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាដែលតែងតែផ្តល់ការគាំទ្រ និងមន្ត្រីបុគ្គលិកគ្រប់លំដាប់ថ្នាក់ដែលបានខិតខំបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមគ្នាកសាងប្រព័ន្ធធនាគារឱ្យមានការអភិវឌ្ឍជឿនលឿននិងប្រកបដោយចីរភាព។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានាដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អនាពេលកន្លងមក។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ និងភាគីពាក់ព័ន្ធនានានឹងបន្តគាំទ្រ និងរួមចំណែកសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀតក្នុងប្រព័ន្ធធនាគារ ដែលនឹងបម្រើជាប្រយោជន៍រួមសម្រាប់ជាតិមាតុភូមិនិងប្រជាជនកម្ពុជា។

**ទេសាភិបាល**

**ជា.ចាន់តូ**

# អក្សរកាត់

| | | |
|---|---|---|
| គ.ស.ហ. | គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និង ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | National Coordination Committee on Anti-Money-Laundering and Combating the Financing of Terrorism and Financing of Proliferation of Weapons of Mass Destruction |
| គ.វ.ក-១៩ | គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ | The Covid-19 Vaccination Committee |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product (GDP) |
| ស.ហ.ក | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | Cambodia Financial Intelligence Unit (CAFIU) |
| អ.វ.ហ | អនុគណៈកម្មាធិការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | National Risk Assessment Sub-Committee for Combating Money Laundering and Countering Financing Terrorism and Financing of Proliferation |
| អ.អ.ផ. | អនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួមនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ | The Sub-Committee for the Implementation of Action Plan of Asia/Pacific Joint Group on International Co-operation Review |
| ABC | សមាគមធនាគារនៅកម្ពុជា | The Association of Banks in Cambodia |
| ACCA | សមាគមគណនេយ្យករជំនាញ | Association Of Certified Chartered Accountants |
| ACGM | កិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន | ASEAN Central Bank Governors' Meeting |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី | Asian Development Bank |
| AFI | សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ | Alliance for Financial Inclusion |

| | | |
|---|---|---|
| AMRO | អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ | The ASEAN+3 Macroeconomic Research Office |
| APG | ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ | Asia/Pacific Group on Money Laundering |
| ATM | ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ | Automated Teller Machine |
| Bakong LVPS | ប្រព័ន្ធទូទាត់តម្លៃធំបាគង | Bakong Large Value Payment System |
| BIS | ធនាគារសម្រាប់ការទូទាត់អន្តរជាតិ | Bank for International Settlements |
| BOG | ក្រុមប្រឹក្សាភិបាលនៃទេសាភិបាល | Board Of Governors |
| BOK-KPP | កម្មវិធីស្រាវជ្រាវរួមគ្នាជាមួយធនាគារកណ្តាលកូរ៉េ | Bank of Korea-Knowledge Partnership Program |
| CBDC | រូបិយប័ណ្ណឌីជីថលធនាគារកណ្តាល | Central Bank Digital Currency |
| CBS | មណ្ឌលសិក្សាបច្ចេកទេសធនាគារ | Center for Banking Studies |
| CFA | ជំនាញវិភាគហិរញ្ញវត្ថុ | Chartered Financial Analyst |
| CIA | ជំនាញសវនកម្មផ្ទៃក្នុង | Certified Internal Audit |
| CMIM | ពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ | Chiang Mai Initiative Multilateralization |
| CPA | ជំនាញគណនេយ្យករសាធារណៈ | Certified Public Accountant |
| CSS | ប្រព័ន្ធខេមបូឌានស៊ែស្វីច | Cambodian Shared Switch |
| CUFA | សហព័ន្ធឥណទានមូលដ្ឋានអូស្ត្រាលី | Credit Union Foundation Australia |
| EGMONT | ក្រុមអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ | Egmont Group of Financial Intelligence Units |
| ENEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចេញ | Export-weighted Nominal Effective Exchange Rate |
| EREER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចេញ | Export-weighted Real Effective Exchange Rate |
| ESG | បរិស្ថាន សង្គម និងអភិបាលកិច្ច | Environmental, Social and Governance |
| FAST | ប្រព័ន្ធសេវាទូទាត់រហ័ស | Fast System |
| FATF | ក្រុមការងារហិរញ្ញវត្ថុ | Financial Action Task Force |
| FCD | អនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណ | Foreign Currency Deposit |

| | | |
|---|---|---|
| FICG | ក្រុមការងារប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ | Financial Intelligence Consultative Group |
| FPP | កម្មវិធីនិងគោលនយោបាយហិរញ្ញវត្ថុ | Financial Programing and Policies |
| FSI Connect | កម្មវិធីសិក្សារបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុ | Financial Stability Institute Connect |
| IBF | វិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ | Institute of Banking and Finance |
| ICRG-JG | ក្រុមការងារត្រួតពិនិត្យរួមគ្នានៃប្រទេសអាស៊ី-ប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ | International Cooperation Review Group- Joint Group |
| IEWG | ក្រុមការងារផ្លាស់ប្តូរព័ត៌មាន | Information Exchange Working Group |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ | International Finance Corporation |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ | International Monetary Fund |
| INEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចូល | Import-weighted Nominal Effective Exchange Rate |
| IREER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចូល | Import-weighted Real Effective Exchange Rate |
| ITRS | ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ | International Transactions Reporting System |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន | Japan International Cooperation Agency |
| LPCO | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា | Liquidity-Providing Collateralized Operation |
| MLF | ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី | Marginal Lending Facility |
| MSCWG | ក្រុមការងារសមាជិកភាព ការគាំទ្រ និងអនុលោមភាព | Membership, Support, and Compliance Group |
| NBCP | ផ្លែតហ្វមរបស់ធនាគារជាតិនៃកម្ពុជា | National Bank of Cambodia Platform |
| NCD | មូលបត្រអាចជួញដូរបាន | Negotiable Certificate of Deposit |
| NCS | ប្រព័ន្ធផាត់ទាត់ជាតិ | National Clearing System |
| OBS | ប្រព័ន្ធធនាគារអនឡាញ | Online Banking System |

| | | |
|---|---|---|
| PPWG | ក្រុមការងារគោលនយោបាយនិងនីតិវិធី | Policy and Procedure Working Group |
| RCEP | ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ | Regional Comprehensive Economic Partnership |
| ROA | អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម | Return on Asset |
| ROE | អនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក | Return on Equity |
| RPPI | សន្ទស្សន៍ថ្លៃលំនៅឋាន | Residential Property Price Indices |
| SEACEN | មជ្ឈមណ្ឌលស៊ាសិន | South East Asian Central Banks |
| SREP | វិធីសាស្ត្រត្រួតពិនិត្យ និងវាយតម្លៃ | Supervisory Review and Evaluation Process |
| TATWG | ក្រុមការងារជំនួយបច្ចេកទេសនិងការបណ្តុះបណ្តាល | Technical Assistance and Training Working Group |
| UNCDF | មូលនិធិអភិវឌ្ឍន៍មូលធនរបស់អង្គការសហ-ប្រជាជាតិ | United Nations Capital Development Fund |
| UNDP | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ | United Nations Development Programme |
| UNESCAP | គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក | United Nations Economic and Social Commission for Asia and the Pacific |
| WB | ធនាគារពិភពលោក | World Bank |
| WHO | អង្គការសុខភាពពិភពលោក | World Health Organization |

## ខ្លឹមសារសង្ខេប

នៅឆ្នាំ២០២២ សេដ្ឋកិច្ចពិភពលោកមានកំណើនទាបជាងការរំពឹងទុក ដោយសារឥទ្ធិពលសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ការកើនឡើងខ្ពស់នៃអតិផរណា និងការរឹតត្បិតស្ថានភាពហិរញ្ញវត្ថុអន្តរជាតិ។ យោងតាមការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ កំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានប៉ាន់ស្មានថាថយល្បឿនមក ៣,២% ក្នុងនោះ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍កើន ២,៤% និងប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍កើន ៣,៧% ខណៈដែលសេដ្ឋកិច្ចតំបន់អាស៊ានអាចរក្សាបានកំណើន ៥,២%។

ចំពោះកម្ពុជា សេដ្ឋកិច្ចបានបន្តងើបឡើងក្នុងអត្រា ៥,១% ដែលគាំទ្រជាចម្បងដោយការបើកទូលាយសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកឡើងវិញ និងកំណើនតម្រូវការខាងក្រៅ។ វិស័យកម្មន្តសាលសម្រេចបានកំណើនរឹងមាំ ដែលក្នុងនោះផលិតផលកាត់ដេរសម្រាប់នាំចេញកើន ៦៤,៣% ផលិតផលមិនមែនកាត់ដេរសម្រាប់នាំចេញកើន ១,១ដង និងផលិតផលកម្មន្តសាលសម្រាប់បម្រើទីផ្សារក្នុងស្រុកកើន ៨៨,៥%។ ជាមួយគ្នានេះ វិស័យទេសចរណ៍មានកំណើនល្អ ដោយភ្ញៀវអន្តរជាតិបានកើនឡើងខ្ពស់ជាងការរំពឹងទុកដល់ ២,២ លាននាក់ ថ្វីបើនៅមានកម្រិតត្រឹម ១/៣ នៃគ្រាមុនវិបត្តិក៏ដោយ ខណៈដែលទេសចរក្នុងស្រុកបានវិលមកប្រក្រតីភាពទាំងស្រុង។ វិស័យសំណង់និងអចលនទ្រព្យមានកំណើនទាបត្រឹម ០,៨% និង ០,៥% រៀងគ្នា ដែលគាំទ្រដោយកំណើនតម្រូវការក្នុងស្រុក ស្របពេលដែលវិស័យកសិកម្មបន្តកើនឡើងក្នុងល្បឿនយឺតត្រឹម ០,៧% ដែលបណ្ដាលមកពីទឹកភ្លៀងធ្លាក់លឿននិងមានបរិមាណច្រើន និងការកើនឡើងថ្លៃដើមផលិត ដោយសារការឡើងថ្លៃប្រេងឥន្ធនៈ និងជីកសិកម្ម។ ជញ្ជីងទូទាត់ត្រូវបានប៉ាន់ស្មានថាមានភាពប្រសើរឡើងដោយមានអតិរេក ២៩៨,៨ លានដុល្លារអាមេរិក ដោយសារលំហូរចូលនៃគណនីហិរញ្ញវត្ថុ និងការថយចុះឱនភាពគណនីចរន្ត និងដើមទុន។ ទុនបម្រុងអន្តរជាតិមានកម្រិតខ្ពស់គ្រប់គ្រាន់ ទោះបីជាបានថយចុះបន្តិចក្ដី ដោយមានចំនួនប្រមាណ ១៧,៨ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ៧ខែ នៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (៣ខែ)។

អតិផរណាបានកើនឡើងដល់ ៥,៣% ខ្ពស់ជាងឆ្នាំ២០២១ (២,៩%) ដែលជាចម្បងបណ្ដាលមកពីកំណើនថ្លៃប្រេងឥន្ធនៈនិងម្ហូបអាហារ ក្រោមឥទ្ធិពលសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងភាពរអាក់រអួលខ្សែច្រវាក់ផ្គត់ផ្គង់សកល ស្របពេលដែលតម្រូវការក្នុងស្រុកមានកំណើនជាលំដាប់។ អត្រាប្ដូរប្រាក់មានស្ថិរភាពក្នុងរង្វង់ ៤.១០២ រៀលក្នុងមួយដុល្លារអាមេរិក ដោយប្រាក់រៀលបានថយថ្លៃបន្តិច ០,១% ធៀបនឹងឆ្នាំមុន។ រូបិយវត្ថុទូទៅ (M2) បានកើនឡើង ៩% ទាបជាងកំណើនឆ្នាំមុន (១៦,៤%) ដោយសារកំណើនទាបនៃប្រាក់បញ្ញើទាំងជាប្រាក់រៀលនិងរូបិយប័ណ្ណ និងការថយចុះនៃរូបិយវត្ថុក្នុងចរាចរណ៍។ ធនាគារជាតិនៃកម្ពុជាបានរក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ចក្នុងកម្រិត ៧% ដែលអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានសន្ទនីយភាពបន្ថែម សម្រាប់ផ្ដល់ឥណទានទៅដល់វិស័យនានា ដើម្បីគាំទ្រការងើបឡើងវិញនៃសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩។ ការស្រូបយកនិងបញ្ចេញសន្ទនីយភាពត្រូវបានធ្វើឡើង ដោយថ្លឹងថ្លែងពីតម្រូវការសន្ទនីយភាព និងការរក្សាស្ថិរភាពតម្លៃប្រាក់រៀល។ ការចេញផ្សាយមូលបត្រអាចជួញដូរបាន (NCD) ចារឹកជាប្រាក់រៀលនិងដុល្លារអាមេរិកសរុបមានចំនួន ៣៧,៥ ប៊ីលានដុល្លារអាមេរិក ដែលបានកើនឡើង ៣,៧% ហើយការបញ្ចេញសន្ទនីយភាពជារៀលតាមរយៈប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានា (LPCO) ត្រូវបានកាត់បន្ថយមកត្រឹម ១,៥ ទ្រីលានរៀល ដែលបានថយចុះជិត ៣ដង។ ឧបករណ៍ផ្ដល់សន្ទនីយភាព

រយៈពេលខ្លី (MLF) ក៏បានផ្តល់សន្ទនីយភាពចំនួន ៣២,៨ ប៊ីលានរៀល ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានតម្រូវការប្រាក់រៀលរយៈពេលខ្លីផងដែរ។ មូលបត្ររដ្ឋត្រូវបានបោះផ្សាយចំនួន ៧២,១ ប៊ីលានរៀល ដែលមានឥណប្រតិទាន ១ឆ្នាំ ជាមួយអត្រាចំណូល ២,២%។ ទោះយ៉ាងណាការអនុវត្តនយោបាយរូបិយវត្ថុមិនទាន់មានប្រសិទ្ធភាពពេញលេញនៅឡើយ ដោយសារកម្រិតដុល្លារូបនីយកម្មខ្ពស់ ដែលឆ្លុះបញ្ចាំងដោយអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅ ៨៩,១%។

ចំពោះស្ថានភាពប្រព័ន្ធធនាគារ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តមានសុខភាពល្អ ព្រមទាំងបានរួមចំណែកគាំទ្រការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច។ ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារបានកើនឡើង ១៩,៥% ឥណទានទៅកាន់វិស័យចម្បងៗមានកំណើន ២០,២% និងប្រាក់បញ្ញើអតិថិជនកើន ១១,៣%។ បរិយាបន្នហិរញ្ញវត្ថុបានកើនឡើងជាលំដាប់ ដែលឆ្លុះបញ្ចាំងដោយកំណើនចំនួនគណនីប្រាក់បញ្ញើអតិថិជនពី ១២,៧ លាន ដល់ ១៥,៣ លានគណនី និងគណនីឥណទានអតិថិជនពី ៣,៥ លាន ដល់ ៣,៧ លានគណនី។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានផ្តល់ការអនុគ្រោះដល់អ្នកខ្ចីប្រាក់ តាមរយៈការរៀបចំឥណទានឡើងវិញចំនួន ១៨៣.១១៧ គណនី (ថយ -៥៩%) ដែលមានទំហំឥណទាន ៣,៣ ប៊ីលានដុល្លារអាមេរិក (ថយ -៣៨%) ដើម្បីរួមចំណែកជួយសម្រាលបន្ទុកប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងគ្រោះទឹកជំនន់។ ឥណទានបន្តមានគុណភាពល្អ ដោយអនុបាតឥណទានមិនដំណើរការមានកម្រិតទាប ទោះជាបានកើនឡើងបន្តិចក៏ដោយ ក្នុងនោះអនុបាតឥណទានមិនដំណើរការសម្រាប់វិស័យធនាគារមានកម្រិត ៣,២% និងវិស័យមីក្រូហិរញ្ញវត្ថុ ២,៦%។ ទន្ទឹមនេះ ស្ថានភាពដើមទុននិងសន្ទនីយភាពមានភាពរឹងមាំ ដោយអនុបាតសាធនភាពមានកម្រិតខ្ពស់ដល់ ២២,៥% សម្រាប់វិស័យធនាគារ និង ២១,២% សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ធៀបនឹងកម្រិតអប្បបរមាកំណត់ដោយបទប្បញ្ញត្តិ ១៥% ហើយអនុបាតគ្របខណ្ឌសន្ទនីយភាពមានអត្រា ១៥៣% សម្រាប់គ្រឹះស្ថានធនាគារពាណិជ្ជ និង ១៧២,៨% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ខ្ពស់ជាងកម្រិតអប្បបរមាកំណត់ដោយបទប្បញ្ញត្តិ ១០០%។ លទ្ធផលនៃការត្រួតពិនិត្យលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបង្ហាញពីភាពធន់នៃប្រព័ន្ធធនាគារទៅនឹងការប៉ះទង្គិចនានា។

ស្ថិតក្នុងបរិការណ៍នៃប្រក្រតីកម្មថ្មីដែលបច្ចេកវិទ្យាថ្មីៗត្រូវបានដាក់ឱ្យប្រើប្រាស់កាន់តែច្រើន ធនាគារជាតិនៃកម្ពុជាបានធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធទូទាត់ និងដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់ការទូទាត់ជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់សុវត្ថិភាពនិងប្រសិទ្ធភាព។ ប្រព័ន្ធផាត់ទាត់ជាតិនិងប្រព័ន្ធសេវាទូទាត់រហ័ស កំពុងត្រូវបានធ្វើបច្ចុប្បន្នកម្មឱ្យមានភាពប្រសើរជាងមុន ហើយស្តង់ដារ KHQR កូដត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ ដើម្បីពង្រឹងសុវត្ថិភាព កាត់បន្ថយចំណាយប្រតិបត្តិការ និងជំរុញបរិយាបន្នហិរញ្ញវត្ថុ។ ប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់កន្លោង បានជួយសម្រួលអន្តរប្រតិបត្តិការរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បង្កើនប្រសិទ្ធភាពក្នុងប្រព័ន្ធទូទាត់សងប្រាក់ និងជំរុញការទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់។ ចំនួនគណនីអ៊ីវ៉ាឡេតបានកើនឡើងគួរឱ្យកត់សម្គាល់ដល់ ១៧,៩ លានគណនី ហើយចំនួនប្រតិបត្តិការរបស់សេវាទូទាត់សងប្រាក់បានកើនដល់ប្រមាណ ១ ប៊ីលានប្រតិបត្តិការ ក្នុងទំហំទឹកប្រាក់ ២៧២,៥ ប៊ីលានដុល្លារអាមេរិក ស្មើនឹងជាង ១០ដងនៃផ.ស.ស.។ ការទូទាត់ឆ្លងដែនជាមួយបណ្តាប្រទេសក្នុងតំបន់ត្រូវបានពង្រីក

ជាពិសេសជាមួយប្រទេសជិតខាង ដែលបច្ចុប្បន្នកំពុងតភ្ជាប់ការទូទាត់ឆ្លងដែនជាមួយប្រទេសឡាវ និងវៀតណាម បន្ទាប់ពីសម្រេចបានការតភ្ជាប់ជាមួយប្រទេសថៃនិងម៉ាឡេស៊ី ដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងការផ្ទេរប្រាក់ឆ្លងដែនឱ្យកាន់តែមានភាពងាយស្រួល ឆាប់រហ័ស និងសុវត្ថិភាព។

ថ្វីត្បិតតែប្រព័ន្ធទូទាត់អេឡិចត្រូនិកត្រូវបានទទួលយកយ៉ាងឆាប់រហ័សនៅកម្ពុជា សេដ្ឋកិច្ចក្នុងស្រុកនៅបន្តពឹងផ្អែកលើការប្រើប្រាស់ក្រដាសប្រាក់។ ក្នុងបរិការណ៍នេះ ការចរាចរសាច់ប្រាក់ត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាព ដែលបានបំពេញតម្រូវការរបស់សាធារណជននៅទូទាំងប្រទេស ជាមួយនឹងការលើកកម្ពស់គុណភាពនិងសោភ័ណភាពក្រដាសប្រាក់រៀល។ បន្ថែមលើនេះ យុទ្ធនាការលើកកម្ពស់ប្រាក់រៀល ក៏ត្រូវបានរៀបចំឡើងនិងបានបង្កើនចំណេះដឹងរបស់ប្រជាជនអំពីអត្ថប្រយោជន៍នៃរូបិយវត្ថុជាតិ ព្រមទាំងបំផុសស្មារតីយុវជនឱ្យស្រឡាញ់និងប្រើប្រាស់ប្រាក់រៀលកាន់តែទូលំទូលាយ។

មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសសរុបមាន ១.៨៨៩ នាក់ កើនឡើង ៦,៥% ក្នុងនោះជាស្ត្រីមានសមាមាត្រ ៤៩,២%។ ដើម្បីបង្កើនប្រសិទ្ធភាពការងារ ការអភិវឌ្ឍសមត្ថភាពធនធានមនុស្សក៏ត្រូវបានលើកកម្ពស់ជាប្រចាំ តាមរយៈការបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេស និងការសិក្សាតាមប្រព័ន្ធអនឡាញ ដែលបានពង្រឹងចំណេះដឹង ឯកទេសកម្ម និងជំនាញ ឆ្លើយតបទៅនឹងតម្រូវការការងារនិងការប្រែប្រួលស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ មណ្ឌលសិក្សាបច្ចេកទេសធនាគារបាននិងកំពុងបណ្តុះបណ្តាលនិស្សិត ២៨០ នាក់ ហើយអគារថ្មីនៃមណ្ឌលសិក្សាក៏ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ ដែលនឹងបន្តពង្រឹងគុណភាពនិងប្រសិទ្ធភាពសិក្សាថែមទៀត។ លើសពីនេះ ការងារសវនកម្មនិងអធិការកិច្ចក៏ត្រូវបានអនុវត្តជាបន្តបន្ទាប់ទាំងនៅស្នាក់ការកណ្តាល និងសាខារាជធានី-ខេត្ត ដោយបានលើកកម្ពស់អភិបាលកិច្ចល្អ គុណភាពសេវាធនាគារកណ្តាល និងការគ្រប់គ្រងហានិភ័យនានា។

ដោយឡែក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) បានបន្តអនុវត្តការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មជាប្រចាំ តាមរយៈការពង្រឹងការអនុវត្តកាតព្វកិច្ចរបស់បុគ្គលរាយការណ៍ ការបញ្ជូនរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុទៅអាជ្ញាធរអនុវត្តច្បាប់ កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ ការបណ្តុះបណ្តាលនិងការផ្សព្វផ្សាយ ព្រមទាំងចូលរួមនិងសម្របសម្រួលការអនុវត្តផែនការសកម្មភាពរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF)។

ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិ ធនាគារជាតិនៃកម្ពុជាបានរួមចំណែកជំរុញសមាហរណកម្មហិរញ្ញវត្ថុឱ្យកាន់តែស៊ីជម្រៅទៅក្នុងតំបន់និងពិភពលោក ពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុ និងអភិវឌ្ឍធនធានមនុស្សក្នុងតំបន់ តាមរយៈការបំពេញតួនាទីជាប្រធានកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន និងសហប្រធានកិច្ចប្រជុំរួមរវាងរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្តាលអាស៊ាន និងអាស៊ាន+៣ នៅឆ្នាំ២០២២នេះ និងបានបំពេញតួនាទីជាប្រធានប្តូរវេននៃក្រុមប្រឹក្សាទេសាភិបាលមជ្ឈមណ្ឌលស៊ាសិន (BOG) សម្រាប់ឆ្នាំ២០២៣។ កិច្ចសហប្រតិបត្តិការទ្វេភាគីត្រូវបានពង្រឹងតាមរយៈការជួបប្រជុំទ្វេភាគី និងបង្កើនកិច្ចសហប្រតិបត្តិការនៅលើផ្នែកនានា ជាពិសេសពាក់ព័ន្ធនឹងការត្រួតពិនិត្យ ការតភ្ជាប់ប្រព័ន្ធទូទាត់ និងការផ្លាស់ប្តូរបទពិសោធន៍។ល។

# ផ្នែកទី១ - របាយការណ៍ប្រចាំឆ្នាំ២០២២

## I- ស្ថានភាពសេដ្ឋកិច្ចពិភពលោក

ក្រាហ្វ ១ ៖ ចំណែកផ.ស.សពិភពលោក

(គិតត្រឹមឆ្នាំ២០២១)




ប្រភព៖ ធនាគារពិភពលោក

នៅឆ្នាំ២០២២នេះ ការរាលដាលនៃជំងឺកូវីដ-១៩ បានថយចុះ ហើយប្រទេសភាគច្រើនបានបើកប្រទេសឡើងវិញ។ សកម្មភាពសេដ្ឋកិច្ចក្នុងស្រុកបានវិលមកប្រក្រតីភាពវិញជាលំដាប់ ហើយទំហំពាណិជ្ជកម្មពិភពលោកបានកើនឡើង ៤,៣%[១] និងទេសចរអន្តរជាតិកើនប្រមាណ ១,៧ ដង[២] បើធៀបនឹងឆ្នាំ២០២១។ ដោយឡែក ប្រទេសចិនបានបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលនយោបាយគ្មានកូវីដ (Zero Covid Policy) ដែលបានធ្វើឱ្យមជ្ឈមណ្ឌលពាណិជ្ជកម្មសំខាន់ៗដំណើរការមិនពេញលេញ និងបណ្ដាលឱ្យរាំងស្ទះដល់ខ្សែច្រវាក់ផ្គត់ផ្គង់សកល ព្រមទាំងប៉ះពាល់ដល់វិស័យទេសចរណ៍។ ខណៈពេលដែលជំងឺកូវីដ-១៩ នៅមិនទាន់បានបញ្ចប់ទាំងស្រុងនៅឡើយ សេដ្ឋកិច្ចពិភពលោកបានទទួលរងនូវបញ្ហាប្រឈមថ្មីមួយទៀតគឺការកើនឡើងខ្លាំងនៃអតិផរណា ដោយសារការឡើងថ្លៃនៃប្រេងឥន្ធនៈនិងម្ហូបអាហារ ដែលបណ្ដាលមកពីការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន[៣]។

ក្រាហ្វ ២ ៖ កំណើនទេសចរអន្តរជាតិ

(ឆ្នាំ២០១៩ - ឆ្នាំ២០២២)




ប្រភព៖ Word Tourism Organization (UNWTO)

*បម្រែបម្រួលធៀបនឹងឆ្នាំ២០១៩

[១] របាយការណ៍ WEO – Countering the Cost-of-living Crisis។

[២] របាយការណ៍ UNWTO World Toursim Barometer។ ទិន្នន័យ ៧ ខែដើមឆ្នាំ២០២២។

[៣] រុស្ស៊ីដែលជាប្រទេសនាំចេញប្រេងធំជាងគេទៅតំបន់អឺរ៉ុប ជីកសិកម្មធំជាងគេ និងស្រូវសាលីធំជាងគេក្នុងពិភពលោក ជាពិសេសទៅកាន់តំបន់អាស៊ីកណ្ដាលនិងអាហ្វ្រិក ខណៈដែលអ៊ុយក្រែនក៏ជាប្រទេសនាំចេញគ្រាប់ធញ្ញជាតិរួមមានស្រូវសាលី ពោត និងផលិតផលពាក់ព័ន្ធនឹងចំណីអាហារ ជីកសិកម្ម ផងដែរ។

អតិផរណាពិភពលោកបានកើនដល់ ៨,៨%[៤] នៅឆ្នាំ២០២២ ធៀបនឹង ៣,៤% នៅឆ្នាំ២០២១ ដែលក្នុងនោះ៖ អតិផរណានៅប្រទេសអភិវឌ្ឍន៍បានកើនដល់ ៧,២% (ធៀបនឹង ៣,១% ឆ្នាំមុន) ស្របពេលដែលប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍កើនដល់ ៩,៩% (ធៀបនឹង ៥,៩% ឆ្នាំមុន)។ នៅសហរដ្ឋអាមេរិកអតិផរណាបានកើនឡើងដល់កម្រិត ៨% ខ្ពស់បំផុតក្នុងរយៈពេល ៤ ទសវត្សរ៍ចុងក្រោយ អង់គ្លេស ៨,៦% ឥណ្ឌា ៧% និងប្រទេសក្នុងតំបន់អឺរ៉ុប ដូចជា អាល្លឺម៉ង់ ៧,៣% អ៊ីតាលី ៧,២% និងអេស្ប៉ាញ ៨%[៥]។ ការកើនឡើងខ្ពស់នៃអតិផរណាបានធ្វើឱ្យស្ថានភាពហិរញ្ញវត្ថុសកលមានភាពរឹតបន្តឹង នាំទៅដល់ការថយចុះនៃតម្រូវការរបស់ប្រទេសអភិវឌ្ឍន៍ ស្ថានភាពបំណុលសម្រាប់ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍កើនឡើង ទុនបម្រុងអន្តរជាតិនិងតម្លៃរូបិយប័ណ្ណថយចុះ។

**ក្រាហ្វ ៣៖ អត្រាអតិផរណាពិភពលោក**
(គិតជាភាគរយ, ឆ្នាំ២០១៩ - ឆ្នាំ២០២២ប)




ប្រភព៖ IMF, *ព=ព្យាករណ៍

**ក្រាហ្វ ៤៖ ស្ថានភាពហិរញ្ញវត្ថុអន្តរជាតិ**
(សន្ទស្សន៍, ឆ្នាំ២០០៦ - ខែកញ្ញា ឆ្នាំ២០២២)




ប្រភព៖ World Economic Outlook

ឆ្លើយតបនឹងការកើនឡើងខ្ពស់នៃអតិផរណា ធនាគារកណ្ដាលអាមេរិកបានដំឡើងអត្រាការប្រាក់គោលលឿនជាងការរំពឹងទុក ចំនួន ៧[៦] ដង ក្នុងឆ្នាំ២០២២ ពី ០,២៥% ដល់ ៤,៥%[៧] ដែលបណ្ដាលឱ្យមានលំហូរទុនចូលក្នុងសហរដ្ឋអាមេរិកនិងប្រាក់ដុល្លារអាមេរិកឡើងថ្លៃ។ គួយ៉ាង ធៀបនឹងដុល្លារអាមេរិក ប្រាក់យេនជប៉ុនធ្លាក់ថ្លៃ -១៥,៩% យ៉ន់ចិន -៨,៧% ផោនអង់គ្លេស -៨,២% ប្រាក់អឺរ៉ូធ្លាក់ថ្លៃ -៦,៤% ដុល្លារអូស្ត្រាលី -៥,៨% និង រូបិយប័ណ្ណផ្សេងទៀតក្នុងតំបន់អាស៊ានមាន រីងហ្គីតម៉ាឡេស៊ី -៤,៥% និងបាតថៃ -៣,៦%។

---

[៤] របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក របស់ IMF ចេញផ្សាយខែតុលា ឆ្នាំ២០២២
[៥] របាយការណ៍ព្យាករណ៍អតិផរណាប្រចាំឆ្នាំ២០២២ របស់ Euromonitor International ចេញផ្សាយខែកញ្ញា ឆ្នាំ២០២២
[៦] ពី ០,២៥% ក្នុងខែកុម្ភៈ ដល់ ០,៥% ក្នុងខែមីនា, ១% ក្នុងខែឧសភា, ១,៧៥% ក្នុងខែមិថុនា, ២,៥% ក្នុងខែកក្កដា, ៣,២៥% ក្នុងខែតុលា និង ៤% ក្នុងខែវិច្ឆិកា ឆ្នាំ២០២២។
[៧] ជាអត្រាខ្ពស់បំផុតចាប់តាំងពីឆ្នាំ២០០៨

**ក្រាហ្វ ៥ ៖ អត្រាការប្រាក់គោលនៃប្រទេសអភិវឌ្ឍន៍**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២០ - ខែធ្នូ ឆ្នាំ២០២២)




ប្រភព៖ Trading Economics

**ក្រាហ្វ ៦ ៖ អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិក**

(សន្ទស្សន៍, ខែមករា ឆ្នាំ២០២១ - ខែធ្នូ ឆ្នាំ២០២២)




ប្រភព៖ គេហទំព័រ www.fred.stlouisfed.org និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧ ៖ អត្រាការប្រាក់គោលនៃប្រទេសក្នុងតំបន់អាស៊ីមួយចំនួន**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២០ - ខែធ្នូ ឆ្នាំ២០២២)




ប្រភព៖ Trading Economics

ដើម្បីរក្សាតម្លៃរូបិយវត្ថុ និងបន្ថយសម្ពាធអតិផរណា ធនាគារកណ្តាលភាគច្រើនបានសម្រេចដំឡើងអត្រាការប្រាក់គោលផងដែរ ដូចជា ធនាគារកណ្តាលអឺរ៉ុបបានដំឡើងចំនួន៤ដង[៨] ពី 0% ដល់ ២,៥% និងធនាគារកណ្តាលអង់គ្លេសដំឡើងចំនួន៨ដង[៩] ពី ០,១% ដល់ ៣,៥%។ ដោយឡែក ធនាគារកណ្តាលជប៉ុនបានបន្តរក្សាអត្រាការប្រាក់គោលត្រឹម -0,១% ដោយសារអត្រាអតិផរណានៃប្រទេសជប៉ុននៅមានកម្រិតទាបនៅឡើយ ម្យ៉ាងវិញទៀតការដំឡើងអត្រាការប្រាក់គោលអាចធ្វើឱ្យប៉ះពាល់ដល់តម្រូវការក្នុងស្រុក ដាក់សម្ពាធលើបំណុលរដ្ឋាភិបាល និងបង្កើនបន្ទុកបំណុលរបស់សាជីវកម្ម។ ធនាគារកណ្តាលចិនបានបន្ថយអត្រាការប្រាក់គោលមកត្រឹម ៣,៦៥% ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ចបន្ទាប់ពីផលរំខានដែលបង្កដោយសារការរាលដាលនៃជំងឺកូវីដ-១៩។ សម្រាប់តំបន់អាស៊ាន ធនាគារកណ្តាលភាគច្រើនបានដំឡើងអត្រាការប្រាក់គោល ដើម្បីគ្រប់គ្រងសម្ពាធអតិផរណា ដូចជា ធនាគារកណ្តាលថៃ ដំឡើងពី ០,៥% ដល់ ១,២៥% ធនាគារកណ្តាលម៉ាឡេស៊ីពី ១,៧៥% ដល់ ២,៧៥% ធនាគារកណ្តាលឥណ្ឌូណេស៊ីពី ៣,៥% ដល់ ៥,២៥%។

ជាមួយគ្នានេះ ធនាគារកណ្តាលមួយចំនួនក៏បានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ដើម្បីកាត់បន្ថយសម្ពាធលើការធ្លាក់ចុះរូបិយប័ណ្ណរបស់ខ្លួន។ ធនាគារកណ្តាលជប៉ុនធ្វើអន្តរាគមន៍លក់ប្រាក់ដុល្លារអាមេរិកកាលពីខែកញ្ញាកន្លងទៅរហូតដល់ ១៩,៧ ប៊ីលានដុល្លារអាមេរិក[១០] ដែលជា

---

[៨] ពី 0% ក្នុងខែមិថុនា ដល់ ០,៥% ក្នុងខែកក្កដា, ១,២៥% ក្នុងខែកញ្ញា, ២% ក្នុងខែតុលា និង ២,៥% ក្នុងខែធ្នូ ឆ្នាំ២០២២។

[៩] ពី ០,២៥% ក្នុងខែមករា ដល់ ០,៥% ក្នុងខែកុម្ភៈ, ០,៧៥% ក្នុងខែមីនា, ១% ក្នុងខែឧសភា, ១,២៥% ក្នុងខែមិថុនា, ១,៧៥% ក្នុងខែសីហា, ២,២៥% ក្នុងខែកញ្ញា, ៣% ក្នុងខែវិច្ឆិកា និង ៣,៥% ក្នុងខែធ្នូ ឆ្នាំ២០២២។

[១០] ប្រហាក់ប្រហែល ២,៨៤ ទ្រីលានយេន ប្រភព៖ Bloomberg

អន្តរាគមន៍លើកដំបូងគិតចាប់ពីវិបត្តិហិរញ្ញវត្ថុនៅអាស៊ីឆ្នាំ១៩៩៧។ ធនាគារកណ្តាលឥណ្ឌូណេស៊ីបានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ដោយបានចំណាយទុនបម្រុង ចំនួន ៩,២១ ប៊ីលានដុល្លារអាមេរិក នាខែកក្កដា ឆ្នាំ២០២២ ដើម្បីកាត់បន្ថយការធ្លាក់ចុះនៃប្រាក់រូពីឥណ្ឌូណេស៊ី[១១]។ ធនាគារកណ្តាលចិនបានជូនដំណឹងដល់ធនាគាររដ្ឋធំៗក្នុងប្រទេសឱ្យត្រៀមខ្លួនក្នុងការលក់ដុល្លារអាមេរិក និងបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់ការធ្លាក់ចុះប្រាក់យន់ចិន។ ការធ្វើអន្តរាគមន៍បានបណ្តាលឱ្យទុនបម្រុងអន្តរជាតិ[១២] ធ្លាក់ចុះ ដូចជា ប្រទេសចិនធ្លាក់ចុះ -៥% កូរ៉េ -១០% ជប៉ុន -១២% ឥណ្ឌា -១៧% និងអង់គ្លេស -១៩%។

**ក្រាហ្វ ៨ ៖ អនុបាតទុនបម្រុងអន្តរជាតិធៀបនឹងផ.ស.ស**

(គិតជាភាគរយ, ឆ្នាំ២០២១ - ខែវិច្ឆិកា ឆ្នាំ២០២២)




ប្រភព៖ Bloomberg និង ការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៩ ៖ ការប្រែប្រួលទុនបម្រុងអន្តរជាតិ**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០១៩ - ខែកញ្ញា ឆ្នាំ២០២២)




ប្រភព៖ គេហទំព័រ www.fred.stlouisfed.org និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

ដោយសារបញ្ហាប្រឈមខាងលើកំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករថានឹងថយចុះពី ៦% ឆ្នាំ២០២១ មក ៣,២%[១៣] ស្របពេលដែលសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ថយចុះមកត្រឹម ២,៤% (៥,២% ឆ្នាំ២០២១) និងប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ ៣,៧% (៦,៦% ឆ្នាំ២០២១)។ ដោយឡែក សេដ្ឋកិច្ចអាស៊ានកើនឡើង ៥,២% (៣,១% ឆ្នាំ២០២១) ដែលគាំទ្រដោយកំណើនតម្រូវការក្នុងស្រុកនិងការនាំចេញ ព្រមទាំងកំណើនវិនិយោគរបស់ប្រទេសសមាជិក ដូចជាវៀតណាម ឥណ្ឌូណេស៊ី ម៉ាឡេស៊ី និងហ្វីលីពីន[១៤]។

**ក្រាហ្វ ១០ ៖ កំណើនសេដ្ឋកិច្ចពិភពលោក និងតំបន់**

(គិតជាភាគរយ, ឆ្នាំ២០២០ - ឆ្នាំ២០២៣ព)




ប្រភព៖ IMF និង AMRO, *ប=ប៉ាន់ស្មាន, *ព=ព្យាករណ៍

---

[១១] ធនាគាររដ្ឋវៀតណាមបានធ្វើអន្តរាគមន៍ទីផ្សារប្តូរប្រាក់ ចាប់តាំងពីដើមឆ្នាំ២០២២ តាមរយៈការលក់រូបិយប័ណ្ណបរទេសដោយប្រើមធ្យោបាយសមស្រប ក្នុងគោលដៅផ្គត់ផ្គង់រូបិយប័ណ្ណបរទេសទៅកាន់ទីផ្សារស្របតាមស្ថានភាពសេដ្ឋកិច្ច។ ធនាគារកណ្តាលហ្វីលីពីនបានធ្វើអន្តរាគមន៍ទីផ្សារប្តូរប្រាក់ដោយប្រើប្រាស់វិធីសាស្ត្រចំនួន២ ៖ i/-ធ្វើអន្តរាគមន៍ខ្លាំងជាងមុន ដោយសារការប្រែប្រួលនៃរូបិយប័ណ្ណនាពេលបច្ចុប្បន្នខ្ពស់ជាងមុន និង ii/-កាត់បន្ថយរូបិយប័ណ្ណក្នុងស្រុកដោយការខ្ចីប្រាក់បន្ថែមទៀតពីការដេញថ្លៃប្រចាំសប្តាហ៍របស់ធនាគារកណ្តាល។

[១២] ទុនបម្រុងអន្តរជាតិមិនរាប់បញ្ចូលមាស គិតត្រឹមខែកញ្ញា ឆ្នាំ២០២២

[១៣] ការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)

[១៤] យោងតាមរបាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក របស់ IMF ចេញផ្សាយខែតុលា ឆ្នាំ២០២២ សេដ្ឋកិច្ចរបស់ប្រទេសវៀតណាមបានកើនពី ២,៦% ក្នុងឆ្នាំ២០២១ ដល់ ៧% ក្នុងឆ្នាំ២០២២ ស្របពេលដែលប្រទេសឥណ្ឌូណេស៊ីកើនពី ៣,៧% ដល់ ៥,៣% ប្រទេសម៉ាឡេស៊ីពី ៣,១% ដល់ ៥,៤% និងប្រទេសហ្វីលីពីនពី ៥,៧% ដល់ ៦,៥%។

## II- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា

### ១- កំណើនសេដ្ឋកិច្ច

ការគ្រប់គ្រងការរាលដាលនៃជំងឺកូវីដ-១៩ យ៉ាងមានប្រសិទ្ធភាព បានធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកវិលមករកប្រក្រតីភាពឡើងវិញ។ កត្តានេះគួបផ្សំនឹងភាពអំណោយផលនៃកំណើនតម្រូវការខាងក្រៅ បានធ្វើឱ្យវិស័យចម្បងៗ រួមមាន វិស័យកម្មន្តសាល និងវិស័យទេសចរណ៍ដែលទទួលបានកំណើនខ្ពស់ជាងការរំពឹងទុក ស្របពេលដែលវិស័យកសិកម្មបន្តមានកំណើនយឺត ហើយវិស័យសំណង់ទទួលបានកំណើនវិជ្ជមានឡើងវិញ ប៉ុន្តែក្នុងកម្រិតទាប។ ក្នុងបរិការណ៍នេះ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានដោយសុទិដ្ឋិនិយមថានឹងបន្តងើបឡើងក្នុងរង្វង់ ៥,១%។

**ក្រាហ្វ ១១ ៖ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ**

(ឆ្នាំ១៩៩៥ - ២០២៣ព)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

**វិស័យកម្មន្តសាល៖** វិស័យកម្មន្តសាលបន្តដើរតួនាទីជាសសរស្តម្ភសំខាន់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ដែលក្នុងនោះផលិតផលកម្មន្តសាលសរុបកើន ៨២,៩%។ ផលិតផលកម្មន្ត-សាលសម្រាប់បម្រើការនាំចេញបន្តសម្រេចបានកំណើនខ្ពស់គួរឱ្យកត់សម្គាល់ ដែលក្នុងនោះផលិតផលកាត់ដេរ[១៩] ដែលមានចំណែកធំជាងគេក្នុងវិស័យកម្មន្តសាលមានកំណើន ៦៤,៣% ស្របពេលដែលផលិតផលមិនមែនកាត់ដេរមានកំណើន ១,១ដង (បរិក្ខារអេឡិចត្រូនិកនិងអគ្គិសនី កើន ៩៨,២% យានយន្តនិងគ្រឿងបន្សំសម្រាប់យានយន្ត កើន ៨ ដង និង កង់និងគ្រឿងបន្លាស់កង់ កើន ១,៥ដង)។

**ក្រាហ្វ ១២ ៖ តម្លៃនិងកំណើនផលិតផលកម្មន្តសាលសរុប**

(ឆ្នាំ២០១៧ - ឆ្នាំ២០២២ប)




ប្រភព៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

---

[១៩] ផ្នែកវាយនភ័ណ្ឌ សម្លៀកបំពាក់ កាបូប ស្បែកជើង និងផលិតផលពីស្បែក

ផលិតផលកម្មន្តសាលសម្រាប់បម្រើទីផ្សារក្នុងស្រុក ក៏បានកើនឡើងខ្ពស់ក្នុងអត្រា ៨៨,៥% ដែលក្នុងនោះ ផលិតកម្មអាហារនិងភេសជ្ជៈ (កើន ១,៦ដង) លោហៈកែច្នៃ (១,៧ដង) ផលិតផលធ្វើពីជ័រ (៣៦,១%)។

ចំនួនរោងចក្រនៅក្នុងវិស័យកម្មន្តសាលបានកើនឡើងដល់ ១.៩៧៩ រោងចក្រ ពី ១.៨៧៩ រោងចក្រ នៅឆ្នាំមុន ដែលអាចបង្កើតការងារបានជាង ១លាននាក់។

**ក្រាហ្វ ១៣៖ ចំនួនរោងចក្រសរុប**
(ឆ្នាំ២០១៧ - ឆ្នាំ២០២២ប)




ប្រភព៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

**វិស័យទេសចរណ៍៖** វិស័យទេសចរណ៍ត្រូវបានប៉ាន់ស្មានថាងើបឡើងខ្ពស់ជាងការរំពឹងទុកក្នុងអត្រា ១៥,២%។ ភ្ញៀវអន្តរជាតិ[១៦] បានកើនឡើងដល់ ២,២ លាននាក់ (កើន ១០,៤ដង) ដោយរាជធានីភ្នំពេញ ខេត្តសៀមរាបនិងតំបន់ឆ្នេរទទួលបានភ្ញៀវច្រើនជាងគេ។ ការកើនឡើងនៃភ្ញៀវទេសចរត្រូវបានគាំទ្រដោយការបើកប្រទេសឡើងវិញ ស្របពេលដែលទេសចរណ៍ក្នុងតំបន់មានភាពប្រសើរឡើង ជាមួយនឹងការតភ្ជាប់ជើងហោះហើរមកកម្ពុជាបានដំណើរការឡើងវិញនិងកើនឡើង[១៧] ជាបន្តបន្ទាប់ ជាពិសេសជើងហោះហើរពីប្រទេសជិតខាងដូចជា ប្រទេសថៃ វៀតណាម និងសិង្ហបុរី។ ទោះយ៉ាងណា ការងើបឡើងនេះនៅមានកម្រិតទាបនៅឡើយ បើធៀបទៅនឹងកម្រិតមុនវិបត្តិ ពោលគឺមានកម្រិតត្រឹមប្រមាណ ១ ភាគ ៣ នៃចំនួនភ្ញៀវអន្តរជាតិដែលចូលមកកម្ពុជានៅឆ្នាំ២០១៩ (៦,៦ លាននាក់)។

**ក្រាហ្វ ១៤៖ ភ្ញៀវអន្តរជាតិ**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២ប)




ប្រភព៖ ក្រសួងទេសចរណ៍ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

[១៦] ក្នុងឆ្នាំ២០២២ ភ្ញៀវថៃឈរនៅលំដាប់ទី១ ដែលមានសមាមាត្រ ៣៨% នៃភ្ញៀវអន្តរជាតិសរុប ភ្ញៀវវៀតណាមឈរលំដាប់ទី២ (២១%) និងភ្ញៀវចិនឈរលំដាប់ទី៣ (៥%)។

[១៧] គិតត្រឹម១០ខែ ជើងហោះហើរមកកាន់កម្ពុជាមាន២ម៉ឺនជើង កើនជាង១ម៉ឺនជើង បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០២១ (ជាង៨ពាន់ជើង)

ដោយឡែក ទេសចរណ៍ក្នុងស្រុកបានវិលមករកស្ថានភាពមុនវិបត្តិជំងឺកូវីដ-១៩ វិញ ដោយទេសចរក្នុងស្រុកបានកើន ១,៧ដង ដល់ប្រមាណ ១២,៦ លាននាក់ ក្នុងនោះតំបន់ឆ្នេរទទួលទេសចរច្រើនជាងគេ ដែលមានសមាមាត្រ ៥០,៦% (កើន ២,១%) នៃទេសចរក្នុងស្រុកសរុប បន្ទាប់ពីរាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការផ្លូវល្បឿនលឿន គួបផ្សំនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ក្នុងតំបន់នោះ។ រាជធានីភ្នំពេញឈរនៅលំដាប់ទី២ (សមាមាត្រ ១៧,៤%) ខេត្តសៀមរាបឈរលំដាប់ទី៣ (១៦,៥%) និងតំបន់អេកូទេសចរណ៍ឈរលំដាប់ទី៤ (៥,១%)។

**ក្រាហ្វ ១៥ ៖ ទេសចរក្នុងស្រុក**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២ប)




ប្រភព៖ ក្រសួងទេសចរណ៍ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

**វិស័យកសិកម្ម៖** វិស័យកសិកម្មមានកំណើន ០,៧% ដែលទាបជាងការរំពឹងទុក ដោយសារជំនន់ទឹកភ្លៀង និងការឡើងថ្លៃប្រេងឥន្ធនៈនិងជីកសិកម្ម។ ផលស្រូវរដូវប្រាំងសម្រេចបានកំណើនទាបត្រឹម ០,៣% (១១,៩% ឆ្នាំមុន) ហើយផលស្រូវរដូវវស្សាមានកំណើន ០,៦% (កើន ១១,៥% ឆ្នាំមុន)។

**ក្រាហ្វ ១៦ ៖ ផលស្រូវ**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២ប)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

ផលកៅស៊ូបានថយចុះបន្តិច -០,៦% ស្របពេលដែលតម្លៃកៅស៊ូជាមធ្យមក្នុងមួយតោនបានថយចុះ -១១,៥% ដោយសារតម្រូវការកៅស៊ូថយចុះក្នុងបរិការណ៍ភាពតានតឹងភូមិសាស្ត្រនយោបាយ ការរាំងស្ទះខ្សែច្រវាក់ផលិតកម្ម និងគោលនយោបាយគ្មានកូវីដរបស់ប្រទេសចិន។ គួររំលេចថាតម្លៃកៅស៊ូនៅកម្ពុជាទទួលរងឥទ្ធិពលពីតម្លៃកៅស៊ូនៅទីផ្សារអន្តរជាតិ។

**ក្រាហ្វ ១៧ ៖ ផលនិងតម្លៃកៅស៊ូ**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២ប)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

ចំពោះផលវារីវប្បកម្ម (ចិញ្ចឹមត្រីនិងបង្គា) បានកើន ៣,៣% ដែលគាំទ្រដោយកំណើនតម្រូវការគួបផ្សំនឹងការដាក់ចេញយុទ្ធសាស្ត្រលើកកម្ពស់សមត្ថភាពនៃការធ្វើវារីវប្បកម្មសម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងស្រុកនិងនាំចេញក្រៅប្រទេសរបស់រាជរដ្ឋាភិបាល។

**វិស័យសំណង់និងអចលនទ្រព្យ៖** វិស័យសំណង់និងអចលនទ្រព្យមានកំណើនវិជ្ជមានឡើងវិញ ប៉ុន្តែក្នុងអត្រាទាប ០,៨% និង ០,៥% រៀងគ្នា។ វិស័យសំណង់នៅបន្តទទួលរងផលប៉ះពាល់ ជាពិសេសសំណង់ប្រភេទប្រណីតដែលបម្រើដល់តម្រូវការអនិវេសជន។ ប៉ុន្តែសំណង់លំនៅឋានបានកើន ០,៩% ដោយសារកំណើនតម្រូវការក្នុងស្រុក ជាពិសេសសំណង់លំនៅឋានដែលមានតម្លៃទាបនិងមធ្យម។ គម្រោងសំណង់ដែលទទួលបានការអនុម័តបានថយចុះ -២,៦% មក ៤.១៩១[១៨] គម្រោង ស្របពេលដែលផ្ទៃក្រឡានិងតម្លៃគម្រោងសំណង់មានការថយចុះ -៤៣,៦% និង -៤៥,៣% រៀងគ្នា។

កំណើននៃវិស័យអចលនទ្រព្យ ជាចម្បងដោយសារសកម្មភាពលក់លំនៅឋានដែលមានតម្លៃទាបនិងមធ្យម។ សកម្មភាពលក់លំនៅឋាន[១៩] (ផ្ទះល្វែង វីឡាភ្លោះនិងទោល) ត្រូវបានប៉ាន់ស្មានថាកើនឡើងប្រមាណ ៨០% ខណៈដែលការលក់ខុនដូនៅតែបន្តថយចុះ -៥៨,២%។ ក្នុងស្ថានភាពដែលសកម្មភាពលក់លំនៅឋានសម្រាប់ទីផ្សារក្នុងស្រុកហាក់មិនសូវមានការប្រែប្រួលខ្លាំង

**ក្រាហ្វ ១៨ ៖ សកម្មភាពវារីវប្បកម្ម**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២ប)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

**ក្រាហ្វ ១៩ ៖ ចំនួននិងផ្ទៃក្រឡាគម្រោងសំណង់**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២ប)




ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា , *ប=ប៉ាន់ស្មាន

**ក្រាហ្វ ២០ ៖ កំណើនថ្លៃលំនៅឋានកម្ពុជា**
(ខែមករា ឆ្នាំ២០២១ - ខែវិច្ឆិកា ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

---

[១៨] ទិន្នន័យប៉ាន់ស្មានសម្រាប់ខែធ្នូ ឆ្នាំ២០២២

[១៩] និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

សន្ទស្សន៍ថ្លៃលំនៅឋាន[២០] (RPPI) បានកើនឡើង ៤,២% (ឆ្នាំលើឆ្នាំ) ក្នុងនោះនៅរាជធានីភ្នំពេញបានកើនឡើង ៤% និងតាមបណ្ដាខេត្តបានកើនឡើង ៧% ដែលបង្ហាញថាវិស័យអចលនទ្រព្យបានចាប់ផ្ដើមងើបឡើងវិញ ទោះជានៅទទួលរងសម្ពាធពីវិបត្តិនៅឡើយ។

## ២- ស្ថានភាពអតិផរណា

**ក្រាហ្វ ២១ ៖ អតិផរណារួម និងការរួមចំណែកក្នុងអតិផរណារួម**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២០ - ខែធ្នូ ឆ្នាំ២០២២)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា (*ទិន្នន័យខែវិច្ឆិកា ធ្នូ ឆ្នាំ២០២២ ជាទិន្នន័យប៉ាន់ស្មាន)

**ក្រាហ្វ ២២ ៖ អតិផរណារួម និងអតិផរណាក្រុមទាំងបី**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០១៩ - ខែធ្នូ ឆ្នាំ២០២២)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា (*ទិន្នន័យខែវិច្ឆិកា ធ្នូ ឆ្នាំ២០២២ ជាទិន្នន័យប៉ាន់ស្មាន)

អតិផរណារួមនៅឆ្នាំ២០២២ បានកើនក្នុងអត្រា ៥,៣% ខ្ពស់ជាងឆ្នាំ២០២១ (២,៩%) ជាពិសេស នៅឆមាសទី១ ដែលបានកើនខ្ពស់ជាងគេនៅខែមិថុនា ក្នុងអត្រា ៧,៨% ដោយសារឥទ្ធិពលនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន បន្ថែមលើកំណើនតម្រូវការក្នុងស្រុក នៅពេលស្ថានភាពសេដ្ឋកិច្ចមានភាពប្រសើរឡើងវិញ។ ប៉ុន្តែ អត្រាអតិផរណាបានថយចុះមកវិញជាបន្តបន្ទាប់នៅឆមាសទី២ ដែលជាចម្បងបណ្ដាលមកពីថយថ្លៃប្រេងឥន្ធនៈនិងម្ហូបអាហារពិភពលោកក្រោមបរិការណ៍នៃការបញ្ចេញប្រេងបម្រុងនិងបង្កើនផលិតកម្ម ការថយចុះកំណើនសេដ្ឋកិច្ចពិភពលោក និងកិច្ចព្រមព្រៀងនាំចេញរបស់អ៊ុយក្រែនដែលគាំទ្រដោយអង្គការសហប្រជាជាតិ។

អតិផរណាក្រុមម្ហូបអាហារ[២១] បានកើនល្បឿនដល់ ៤,៨% (២,៧% នៅឆ្នាំ២០២១) ដែលរួមចំណែកជាចម្បងដោយសារការឡើងថ្លៃដើមផលិត ភាពរអាក់រអួលនៃខ្សែច្រវាក់ផ្គត់ផ្គង់សកល និងការបន្តកើនឡើងនៃតម្រូវការ។ ថ្លៃម្ហូបអាហារសំខាន់ៗដែលបានកើនឡើងមានដូចជា ផ្លែឈើ (៧,៩%) បន្លែ (៨,១%) ត្រី (៥%) និងសាច់ជ្រូក (៤,១%)។

---

[២០] ទិន្នន័យគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២២

[២១] ក្រុមម្ហូបអាហារមានសមាមាត្រ ៤៤,៨% ក្នុងការគណនាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

អតិផរណាស្នូល[២២] បានកើនឡើង ៤,៤% (១,៦% នៅឆ្នាំ២០២១) ដែលជាចម្បងដោយសារការបន្តងើបឡើងវិញនៃតម្រូវការក្នុងស្រុក និងឥទ្ធិពលនៃការឡើងថ្លៃម្ហូបអាហារនិងប្រេងឥន្ធនៈ។ ថ្លៃទំនិញនិងសេវាស្នូលសំខាន់ៗដែលបានកើនឡើង មានដូចជា សម្លៀកបំពាក់ (៧,១%) ភោជនីយដ្ឋាន (៦,៩%) កម្សាន្តនិងវប្បធម៌ (៥,៧%) ផ្ទះសម្បែង (៤,១%) និងសុខាភិបាល (២,៨%)។

អតិផរណាក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ[២៣] បានកើនឡើងដល់ ១១,៣% (៨,៧% នៅឆ្នាំ២០២១) ក្នុងស្ថានភាពដែលតម្លៃប្រេងឆៅពិភពលោកបានកើនឡើង ៤៣,៣% ពី ៧១ ដុល្លារអាមេរិកក្នុងមួយបារ៉ែលនៅឆ្នាំ២០២១ ដល់ ១០១ ដុល្លារអាមេរិកក្នុងមួយបារ៉ែលនៅឆ្នាំ២០២២។ ថ្លៃទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈសំខាន់ៗដែលបានកើនឡើង មានដូចជា សាំង (២៦,៧%) ឧស្ម័ន (២០,៣%) និងឥន្ធនៈរឹង (៦%)។

### -អតិផរណាព្យាករណ៍[២៤]សម្រាប់ឆ្នាំ២០២៣

អតិផរណានៅឆ្នាំ២០២៣នៅមានភាពមិនច្បាស់លាស់ច្រើន ដោយសារការអូសបន្លាយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចពិភពលោក។ យោងតាមការសន្មតដោយសុទិដ្ឋិនិយម អតិផរណាត្រូវបានព្យាករថានឹងមានអត្រា ២,៥%[២៥] ទាបជាងឆ្នាំ២០២២ (៥,៣%) ដែលរួមចំណែកដោយ៖ i/-ថ្លៃទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈនឹងថមថយមកវិញ (៣%) ដោយសារកំណើនយឺតនៃសេដ្ឋកិច្ចពិភពលោក ii/-កំណើនថ្លៃម្ហូបអាហារនឹងថយល្បឿន (២,៤%) ដែលបណ្តាលមកពីភាពប្រសើរឡើងនៃស្ថានភាពផ្គត់ផ្គង់និងការថយចុះថ្លៃដើមផលិត និង iii/-អតិផរណាស្នូលនឹងថយមកវិញបន្តិច (២,៦%) ដោយសារឥទ្ធិពលពីការថមថយកំណើនថ្លៃម្ហូបអាហារ រួមទាំងការថយចុះថ្លៃប្រេងឥន្ធនៈ គួបផ្សំនឹងការរំពឹងពីការថយល្បឿនកំណើនឥណទាន ក្នុងបរិការណ៍នៃការកើនឡើងអត្រាការប្រាក់។ ការព្យាករនេះមាននិន្នាការស្របនឹងការព្យាករនៃអតិផរណាពិភពលោកផងដែរ ដោយត្រូវបានរំពឹងថានឹងថយចុះមក ៦,៥% នៅឆ្នាំ២០២៣ ពី ៨,៨% នៅឆ្នាំ២០២២ ក្នុងនោះសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ ៤,៤% (៧,២% នៅឆ្នាំមុន) និងប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ ៨,១% (៩,៩% នៅឆ្នាំមុន)[២៦]។

---

[២២] អតិផរណាស្នូលមានសមាមាត្រ ៣៩,៦% ក្នុងការគណនាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

[២៣] ក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ មានសមាមាត្រ ១៥,៦% ក្នុងការគណនាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

[២៤] ការព្យាករត្រូវបានធ្វើឡើងដោយប្រើម៉ូឌែល៖ i/- Multiple regression ដែលសិក្សាពីទំនាក់ទំនងរវាងអតិផរណា និងសូចនាករសំខាន់មួយចំនួន រួមមាន អតិផរណានៅត្រីមាសមុន អតិផរណាដែគូនាំចូល បម្រែបម្រួលថ្លៃប្រេងឥន្ធនៈពិភពលោក កំណើនឥណទាន និងបម្រែបម្រួលអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ii/- ARIMA (p,d,q) ដែលធ្វើការព្យាករក្រុមទាំង ១២ នៅក្នុងកន្ត្រកទំនិញប្រើប្រាស់ដោយផ្អែកលើតម្លៃគ្រាមុននិងគន្លងរបស់អថេរទាំងនោះ iii/- VARX ដែលមានអត្រាអតិផរណា កំណើនឥណទាន ការប្រែប្រួលអត្រាប្តូរប្រាក់ អតិផរណាដៃគូនាំចូល និងដាក់ថ្លៃប្រេងជា exogenous variables iv/- ARIMA (៣,១,៣) អត្រាអតិផរណាគ្រាមុនៗចំនួន ៣ ត្រីមាស និង v/- VARX ដែលព្យាករអតិផរណាស្នូល អតិផរណាក្រុមម្ហូបអាហារ និងអតិផរណាក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ។

[២៥] ក្រោមការសន្មតថា i/-តម្លៃប្រេងឆៅពិភពលោកត្រូវបានរំពឹងថានឹងថយចុះដល់ ៩៥ ដុល្លារអាមេរិកក្នុងមួយបារ៉ែល ii/-អត្រាប្តូរប្រាក់ជាមធ្យមនឹងបន្តមានស្ថិរភាពក្នុងកម្រិតជាមធ្យម ៤.០៩០ iii/-ផ.ស.សនឹងមានកំណើន ៦% នៅឆ្នាំ២០២៣ ហើយនឹងបន្តងើបឡើងវិញបន្តិចម្តងៗឆ្ពោះទៅនិន្នាការរយៈពេលវែង និង iv/-និន្នាការអតិផរណានៃក្រុមទាំងបីនឹងវិវត្តតាមការរំពឹងទុកដូចបានរៀបរាប់ខាងលើ។

[២៦] របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក របស់ IMF ចេញផ្សាយខែតុលា ឆ្នាំ២០២២

**ក្រាហ្វ ២៣ ៖ អតិផរណាព្យាករណ៍**

(ឆ្នាំ២០១៨ - ឆ្នាំ២០២៣)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## ៣- អត្រាប្តូរប្រាក់

អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកនៅឆ្នាំ២០២២ បន្តមានស្ថិរភាពល្អប្រសើរ បើទោះបីមានកម្រិតខ្ពស់បន្តិចធៀបនឹងគ្រាមុនមានវិបត្តិកូវីដ-១៩ ដោយសារប្រាក់រៀលបន្តទទួលរងសម្ពាធឡើងថ្លៃនៃដុល្លារអាមេរិក បន្ទាប់ពីមានការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលអាមេរិក ខណៈតម្រូវការប្រាក់រៀលមានការកើនឡើង នៅពេលសកម្មភាពសេដ្ឋកិច្ចងើបឡើងវិញក៏ដោយ។

**ក្រាហ្វ ២៤ ៖ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក**

(គិតជារៀលក្នុងមួយដុល្លារអាមេរិក, ឆ្នាំ២០១៦ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកមានកម្រិតជាមធ្យម ៤.១០២ រៀលក្នុងមួយដុល្លារអាមេរិក ដោយប្រាក់រៀលបានថយថ្លៃត្រឹម ១,២% ធៀបនឹងគ្រាមុនវិបត្តិ (២០១៦-២០១៨) និងថយថ្លៃត្រឹម ០,១% ធៀបនឹងឆ្នាំមុន (៤.០៩៩ រៀល)។ នៅឆ្នាំ២០២២នេះ អត្រាប្តូរប្រាក់ផ្លូវការដែលបានចេញដោយធនាគារជាតិនៃកម្ពុជាត្រូវបានគណនាចេញពីអត្រាប្តូរប្រាក់ជាក់ស្តែងដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រើប្រាស់ក្នុងការដោះដូរនៅលើផ្លែតហ្វម NBCP ប្រចាំថ្ងៃ។ ដូច្នេះ អត្រាប្តូរប្រាក់មានកម្រិតស្មើនឹងអត្រាទីផ្សារ ដែលធ្វើឱ្យអត្រាផ្លូវការឆ្លុះបញ្ចាំងពីស្ថានភាពទីផ្សារប្តូរប្រាក់បានកាន់តែប្រសើរ និងមានប្រសិទ្ធភាព។ អត្រាប្តូរប្រាក់ផ្លូវការត្រូវបានផ្សព្វផ្សាយរៀងរាល់ថ្ងៃចុងប្រតិបត្តិការនិងនាពេលព្រឹក។

**ក្រាហ្វ ២៥ ៖ សន្ទស្សន៍ប្រាក់ដុល្លារអាមេរិក**

(មករា ឆ្នាំ២០១៨=១០០, ឆ្នាំ២០១៨ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ប្រអប់ទី១៖ ប្រតិបត្តិការប្ដូរប្រាក់នៅលើផ្ទៃតហ្វម NBCP

ក្រាហ្វ ២៦៖ ទំហំប្រតិបត្តិការប្ដូរប្រាក់តាមផ្លែតហ្វម NBCP
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៨ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ផ្លែតហ្វម NBCP ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៨ ដែលមកដល់បច្ចុប្បន្នមានសមាជិកជួញដូរក្នុងប្រព័ន្ធចំនួន ៦៩ គ្រឹះស្ថាន រួមមាន៖ ធនាគារពាណិជ្ជ ៥០ ធនាគារឯកទេស ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ១០ និងអាជីវករប្ដូរប្រាក់ចំនួន ៥។ គ្រឹះស្ថាន ២៩ ក្នុងចំណោមគ្រឹះស្ថានទាំងអស់ដែលសកម្មក្នុងការជួញដូរប្រចាំថ្ងៃ។ ប្រតិបត្តិការជួញដូរប្រាក់ដុល្លារអាមេរិកក្នុងផ្លែតហ្វម NBCP បានកើនឡើងជាលំដាប់ពីប្រមាណ ៦១០ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨ រហូតដល់ប្រមាណ ១,៨ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ២០២១ និងកើនដល់ ១,៩ ប៊ីលានដុល្លារអាមេរិក[២៧] ក្នុងឆ្នាំ២០២២នេះ។ ចំពោះទំហំប្រតិបត្តិការជួញដូរប្រចាំថ្ងៃជាមធ្យមបានកើនពីប្រមាណ ៤ លានដុល្លារអាមេរិក ដល់ប្រមាណ ៨ លានដុល្លារអាមេរិក ក្នុងមួយថ្ងៃ។ ជារួម ប្រតិបត្តិការនេះមាននិន្នាការកើនឡើងជាលំដាប់ ហើយនិងមានសក្ដានុពលកើនឡើងជាច្រើនទៀត ដោយសារការជឿទុកចិត្តលើការជួញដូរតាមផ្លែតហ្វម NBCP តាមរយៈភាពងាយស្រួលក្នុងការប្រើប្រាស់ សុវត្ថិភាពក្នុងការទូទាត់ និងគ្មានហានិភ័យទូទាត់ ជាដើម។

### វិធីសាស្ត្រគណនាអត្រាជួញដូរ NBCP

អត្រាប្ដូរប្រាក់ផ្លូវការ ត្រូវបានគណនាចេញពីអត្រាមធ្យមថ្លឹងនៃរាល់ប្រតិបត្តិការប្ដូរនៅលើផ្លែតហ្វម NBCP ប្រចាំថ្ងៃ។ ឧទាហរណ៍ អត្រាប្ដូរប្រាក់ផ្លូវការសម្រាប់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ ត្រូវបានគណនា ដូចខាងក្រោម៖

**អត្រាប្ដូរប្រាក់ផ្លូវការសម្រាប់ថ្ងៃទី២២ =**
**[(អត្រាប្ដូរប្រាក់ EX1 នៃ T-1) * (ទំហំប្ដូរប្រាក់ EX1 នៃ T-1) + (អត្រាប្ដូរប្រាក់ EX2 នៃ T-1) * (ទំហំប្ដូរប្រាក់ EX2 នៃ T-1) + …… (អត្រាប្ដូរ ប្រាក់ EXn នៃ T-1) * (ទំហំប្ដូរប្រាក់ EXn នៃ T-1)] / ទំហំទឹកប្រាក់ប្ដូរសរុប**

- EX តំណាងឱ្យប្រតិបត្តិការប្ដូរប្រាក់ ហើយ EX1 តំណាងឱ្យប្រតិបត្តិការទី១ នៃប្រតិបត្តិការសរុប
- T តំណាងពេលវេលា នៃការកំណត់អត្រាប្ដូរប្រាក់ ហើយ T-1 តំណាងឱ្យថ្ងៃម្សិលមិញ
- n តំណាងឱ្យចំនួនប្រតិបត្តិការ

[២៧] គិតត្រឹមថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២

អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចូល (IREER) មាននិន្នាការថយចុះ ដែលបានជួយបន្ធូរបន្ថយសម្ពាធអតិផរណាពីការនាំចូល។ IREER បានថយចុះ -៥,៩% ដោយសារអត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចូល (INEER)[២៨] បានថយចុះ -២,៩% ហើយអត្រាអតិផរណារបស់កម្ពុជាមានកម្រិតខ្ពស់ជាងប្រទេសដៃគូនាំចូល។ បន្ថែមពីនេះ ការថយចុះ INEER បណ្តាលមកពីរូបិយប័ណ្ណនៃប្រទេសនាំចូលមកកម្ពុជាមួយចំនួន (ប្រាក់យ៉ន់ចិន រូពីឥណ្ឌូណេស៊ី វូនកូរ៉េ រីងហ្គីតម៉ាឡេស៊ី ដុល្លារសិង្ហបុរី ដុល្លារតៃវ៉ាន់ និងដុងវៀតណាម) បានថយថ្លៃធៀបនឹងប្រាក់រៀល។

**ក្រាហ្វ ២៧ ៖ អត្រាប្តូរប្រាក់ប្រសិទ្ធភាព**
(សន្ទស្សន៍ ២០១៥=១០០, ឆ្នាំ២០១៥ - ២០២២ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន

អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចេញ (EREER) ថយចុះ -១,៩% ដែលបណ្តាលមកពីការថយចុះអត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចេញ (ENEER)[២៩] -៣,៨% បើទោះជាអត្រាអតិផរណារបស់កម្ពុជាមានកម្រិតទាបជាងប្រទេសដៃគូនាំចេញ។ ការថយចុះ ENEER បណ្តាលមកពីរូបិយប័ណ្ណនៃប្រទេសគោលដៅនាំចេញរបស់កម្ពុជាមួយចំនួនបានថយថ្លៃធៀបនឹងប្រាក់រៀល (ផោនអង់គ្លេស អឺរ៉ូ ដុល្លារកាណាដា យ៉ន់ចិន និងដុងវៀតណាម) ដែលបង្ហាញពីការថមថយនៃឧត្តមភាពប្រកួតប្រជែងលើការនាំចេញរបស់កម្ពុជា។

[២៨] ប្រទេសដៃគូនាំចូលមកកម្ពុជាចម្បងៗរួមមាន៖ ចិន ថៃ វៀតណាម តៃវ៉ាន់ សិង្ហបុរី ជប៉ុន ហុងកុង កូរ៉េ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី និងសហរដ្ឋអាមេរិក។

[២៩] ប្រទេសគោលដៅនាំចេញរបស់កម្ពុជាជាចម្បងៗរួមមាន៖ សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អាល្លឺម៉ង់ ជប៉ុន កាណាដា ចិន ថៃ អេស្ប៉ាញ បែលហ្ស៊ិក បារាំង ហូឡង់ វៀតណាម ហុងកុង អ៊ីតាលី។

## ៤- ស្ថានភាពជញ្ជីងទូទាត់

ជញ្ជីងទូទាត់ត្រូវបានប៉ាន់ស្មានថាមានភាពប្រសើរឡើងដោយមានអតិរេក ២៩៨,៨ លានដុល្លារអាមេរិក ធៀបនឹងអតិរេក ៨២,៧ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១។ អតិរេកនេះត្រូវបានគាំទ្រដោយលំហូរចូលនៃគណនីហិរញ្ញវត្ថុ ស្របពេលដែលឱនភាពគណនីចរន្តនិងដើមទុនបានថយចុះ។

**ក្រាហ្វ ២៨ ៖ ជញ្ជីងទូទាត់កម្ពុជា**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១២ - ២០២២ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន

### ក- គណនីចរន្ត និងដើមទុន

ស្ថានភាពគណនីចរន្តនិងដើមទុនមានភាពប្រសើរឡើងធៀបនឹងការកើនឡើងឱនភាពយ៉ាងគំហុកនៅឆ្នាំ២០២១ ដែលបណ្តាលមកពីកំណើនយ៉ាងខ្លាំងនៃការនាំចូល ជាពិសេស ការនាំចូលមាសនិងបរិក្ខារនិងថ្នាំពេទ្យស្របពេលដែលវិស័យទេសចរណ៍បានធ្លាក់ចុះមិនធ្លាប់មានពីមុនមកដោយសារឥទ្ធិពលនៃវិបត្តិកូវីដ-១៩។ គណនីចរន្តនិងដើមទុនក្នុងឆ្នាំ២០២២ បានថយចុះមកត្រឹម ៣០,៦% នៃផ.ស.ស. (១៥,៥% នៃផ.ស.ស. មិនរាប់បញ្ចូលមាស) ធៀបនឹង ៤៤,៨% នៃផ.ស.ស. ក្នុងឆ្នាំ២០២១ (២៣,២% នៃផ.ស.ស. មិនរាប់បញ្ចូលមាស) ដោយសារការថយចុះឱនភាពពាណិជ្ជកម្មទំនិញ ស្របពេលដែលចំណូលពីវិស័យទេសចរណ៍ និងប្រាក់បង្វែររបស់ពលករពីក្រៅប្រទេសបានកើនឡើង។

**ក្រាហ្វ ២៩ ៖ គណនីចរន្ត និងគណនីដើមទុន**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១២ - ឆ្នាំ២០២២ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន

ឱនភាពពាណិជ្ជកម្មទំនិញបានថយចុះ -២០% (ឆ្នាំមុនកើន ៣,៤ដង) ដោយសារការនាំចេញបានកើនឡើង ១៨,៣%[៣០] (ឆ្នាំមុនកើន ៥,១%) ជាពិសេសទៅសហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុប ខណៈដែលការនាំចូលទំនិញបានកើនឡើង ៤,៣%[៣១] (ឆ្នាំមុនកើន ៤៥,៩%) ដោយសារកំណើនតម្រូវការប្រើប្រាស់និងផលិតកម្មក្នុងស្រុក គួបផ្សំនឹងការកើនឡើងនៃតម្លៃប្រេងឥន្ធនៈ សម្ភារសំណង់ និងទំនិញផ្សេងទៀត។

---

[៣០] ក្នុងនោះ សម្លៀកបំពាក់កើន ១២,៧% ស្បែកជើង ២៤,៨% ផលិតផលវាយនភ័ណ្ឌផ្សេងទៀត ១២% គ្រឿងអេឡិចត្រូនិក ២៧,៤% ទោចក្រយាន ៥៣,៣% និងផលិតផលផ្សេងៗ ២៣,៩%។

[៣១] ការនាំចូលប្រេងឥន្ធនៈ ៥២,៧% យានយន្ត ២១,៩% និងម្ហូបអាហារនិងភេសជ្ជៈ ៣៣,៨% ខណៈដែលការនាំចូលសម្ភារនិងបរិក្ខារសំណង់បានថយចុះ -២៦,៤%។

**ក្រាហ្វ ៣០ ៖ ការនាំចេញ-នាំចូលទំនិញសម្រាប់ឆ្នាំ២០២២**

(គិតជាលានដុល្លារអាមេរិក)




ប្រភព ៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

ឱនភាពគណនីសេវាសុទ្ធបានថយចុះ -៦៩,៧% ដោយសារការកើនឡើងចំណូលពីសេវាធ្វើដំណើរ ៧,៣ដង ខណៈដែលឱនភាពគណនីចំណូលបឋមបានកើនឡើង ៧,៨% ដោយសារការកើនឡើងការទូទាត់ទៅក្រៅប្រទេស ៩,៦% ក្នុងនោះការទូទាត់ការប្រាក់កើន ៣,៧% និងការបែងចែកភាគលាភនិងប្រាក់ចំណេញពីការវិនិយោគផ្ទាល់កើន ៩,៣%។ អតិរេកគណនីចំណូលបន្ទាប់បន្សំបានថយចុះ -១,៦% ដោយសារការថយចុះជំនួយរបស់រាជរដ្ឋាភិបាល -៦,៣% ខណៈដែលប្រាក់បង្វែររបស់ពលករពីក្រៅប្រទេស កើនឡើង ០,៤%។

## ខ- គណនីហិរញ្ញវត្ថុ

សមតុល្យគណនីហិរញ្ញវត្ថុត្រូវបានប៉ាន់ស្មានថា មានលំហូរចូលសុទ្ធ ៩,៤ ប៊ីលានដុល្លារអាមេរិក ដែលគាំទ្រដោយវិនិយោគផ្ទាល់បរទេសសុទ្ធលើវិស័យមិនមែនធនាគារ និងវិនិយោគផ្សេងទៀត។ លំហូរវិនិយោគផ្ទាល់បរទេសសុទ្ធ មានចំនួន ៣,៥ ប៊ីលានដុល្លារអាមេរិក បានកើនឡើង ២,៦% ដោយសារការវិនិយោគលើវិស័យមិនមែនធនាគារបានកើនឡើង ៩,៣%[៣២] ខណៈដែលការវិនិយោគលើវិស័យធនាគារបានថយចុះ -៧,៧%។ វិនិយោគផ្សេងទៀតមានលំហូរចូលសុទ្ធ ៦ ប៊ីលានដុល្លារអាមេរិក បានថយចុះ -៣១% ដោយសារការថយចុះខ្ទង់វិនិយោគផ្សេងទៀតរបស់វិស័យឯកជន -៦៧,៩% ខណៈទ្រព្យសកម្មបរទេសសុទ្ធរបស់វិស័យធនាគារកើន ៦,៥% និងការខ្ចីរបស់រាជរដ្ឋាភិបាលសុទ្ធកើន ១៤,៤%។

**ក្រាហ្វ ៣១ ៖ គណនីហិរញ្ញវត្ថុ**

(ឆ្នាំ២០១២ - ឆ្នាំ២០២២ប)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

---

[៣២] ការវិនិយោគលើវិស័យកម្មន្តសាលកើនឡើង ៦,៨% (កាត់ដេរសម្លៀកបំពាក់កើន ៤,៨% ផលិតកម្មផ្ទាំងសូឡា ១,៥ដង ផលិតផលចំណីអាហារ ៦,៦% និងកម្មន្តសាលផ្សេងៗ ៤៨,២%) វិស័យថាមពល ៩១,៩% វិស័យសំណង់ ៥៣,១% វិស័យអាជីវកម្មធនធានរ៉ែ ២៤% ខណៈការវិនិយោគលើវិស័យកសិកម្មថយចុះ -១៧,៦% វិស័យទូរគមនាគមន៍ -១២,៥% វិស័យសណ្ឋាគារនិងការកម្សាន្ត -៣,៨% វិស័យអចលនទ្រព្យ -៣,៤% និងវិស័យផ្សេងៗទៀត -៨,២%។

## ៥- ទុនបម្រុងអន្តរជាតិ

**ក្រាហ្វ ៣២ ៖ ទុនបម្រុងអន្តរជាតិ**
(ឆ្នាំ២០១២ - ឆ្នាំ២០២២)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ទីផ្សារហិរញ្ញវត្ថុពិភពលោកទទួលរងសម្ពាធខ្លាំងពីការរឹតបន្តឹងនយោបាយរូបិយវត្ថុរបស់បណ្តាធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍ ជាពិសេសធនាគារកណ្តាលអាមេរិក ដែលបានធ្វើឱ្យប្រាក់ដុល្លារអាមេរិកឡើងថ្លៃ និងតម្លៃមូលបត្រធ្លាក់ចុះ។ កត្តាទាំងនេះ នាំឱ្យមានឥទ្ធិពលអវិជ្ជមានដល់ទុនបម្រុងអន្តរជាតិរបស់ប្រទេសជាច្រើន ព្រមទាំងប្រទេសកម្ពុជាផងដែរ។ ទុនបម្រុងអន្តរជាតិបានថយចុះ -១២,១% ដល់ ១៧,៨ ប៊ីលានដុល្លារអាមេរិក (២០,៣ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១) ដែលស្មើនឹងប្រមាណ ៧ខែ នៃការនាំចូលទំនិញនិងសេវា[៣៣] សម្រាប់គ្រាបន្ទាប់ (ខ្ពស់ជាងកម្រិតអប្បបរមាចំនួន ៣ខែ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍)។

ទុនបម្រុងអន្តរជាតិរបស់កម្ពុជាត្រូវបានវិនិយោគស្របតាមស្ថានភាពហិរញ្ញវត្ថុអន្តរជាតិ។ ហានិភ័យនៃការវិនិយោគត្រូវបានគ្រប់គ្រង និងតាមដានយ៉ាងហ្មត់ចត់ អនុលោមតាមសេចក្តីណែនាំការវិនិយោគរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីធានាបានការគ្រប់គ្រងទុនបម្រុងអន្តរជាតិប្រកបដោយសុវត្ថិភាព សន្ទនីយភាព និងទទួលបានចំណូលសមស្រប។ សមាសភាគនៃចំណែកទុនបម្រុងវិនិយោគត្រូវបានកែសម្រួលដើម្បីឆ្លើយតបនឹងកំណើននៃតម្រូវការសន្ទនីយភាព និងលទ្ធភាពខ្ពស់ក្នុងការចាប់យកឱកាសពីការប្រែប្រួលនៃអត្រាការប្រាក់នៅលើទីផ្សារ ដើម្បីរក្សាបានកម្រិតចំណូលវិនិយោគសមស្រប។ លើសពីនេះទៀត ក្នុងនាមជាសមាជិកបណ្តាញប្រព័ន្ធហិរញ្ញវត្ថុបៃតង (Network for Greening Finance System) ធនាគារជាតិនៃកម្ពុជាបានបន្តយកចិត្តទុកដាក់លើការបង្កើនការ វិនិយោគលើសញ្ញាប័ណ្ណបៃតង (Green bonds) និងបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ដែលបោះផ្សាយដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ នៅប្រទេសចិន កូរ៉េខាងត្បូង ជប៉ុន និងនៅតំបន់អឺរ៉ុប។ បច្ចុប្បន្នការវិនិយោគលើសញ្ញាប័ណ្ណបៃតង និង ESG មានសមាមាត្រ ៥% នៃទុនបម្រុងអន្តរជាតិសរុប ដែលឆ្លុះបញ្ចាំងពីការរួមចំណែករបស់ធនាគារជាតិនៃកម្ពុជាក្នុងការលើកកម្ពស់ការអនុវត្តតាមនយោបាយវិនិយោគប្រកបដោយការទទួលខុសត្រូវទៅលើបរិស្ថាន សង្គម និងអភិបាលកិច្ច និងរក្សាបានចីរភាព និងសុវត្ថិភាព ស្របតាមនិន្នាការនៃការវិនិយោគសកល។

[៣៣] មិនរាប់បញ្ចូលការនាំចូលមាស

# III- ការគ្រប់គ្រងរូបិយវត្ថុ

## ១- ស្ថានភាពរូបិយវត្ថុ

រូបិយវត្ថុទូទៅ (M2) បន្តបន្ថយល្បឿន ដោយបានកើនឡើងក្នុងអត្រា ៩% ទាបជាងកំណើនឆ្នាំមុន (១៦,៩%) និងមធ្យមរយៈពេល៥ឆ្នាំចុងក្រោយ (១៨%)។ ការថមថយល្បឿនកំណើននេះ បណ្ដាលមកពីកំណើនទាបជាងមុននៃប្រាក់បញ្ញើសរុប[៣៤] ក្នុងអត្រា ១០,៦% ធៀបនឹងកំណើនឆ្នាំមុន ១៧,៣% ខណៈដែលរូបិយវត្ថុក្នុងចរាចរណ៍បានធ្លាក់ចុះ -៨,៩% ធៀបនឹងកំណើនឆ្នាំមុន ៨,២%។ ការថយចុះនៃរូបិយវត្ថុក្នុងចរាចរណ៍ ដោយសារការអនុវត្តនយោបាយរូបិយវត្ថុប្រុងប្រយ័ត្នក្នុងគោលដៅបន្ថយសម្ពាធលើអត្រាប្ដូរប្រាក់។

កម្រិតដុល្លារូបនីយកម្មដែលវាស់តាមអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅ (FCD/M2) បន្តស្ថិតក្នុងកម្រិតខ្ពស់ ៨៩,១% (ធៀបនឹងឆ្នាំមុន ៨៣%)។ ប្រាក់រៀលក្នុងចរាចរណ៍មានសមាមាត្រ ៧,៧% (៣,៩ ប៊ីលានដុល្លារអាមេរិក) នៃរូបិយវត្ថុទូទៅ ហើយប្រាក់បញ្ញើជារៀលមានសមាមាត្រ ៨,៩% នៃប្រាក់បញ្ញើសរុប ខណៈឥណទានជារៀលមានសមាមាត្រ ១១,២% នៃសំពៀតឥណទានសរុប។

**ក្រាហ្វ ៣៣ ៖ សមាសធាតុ និងកំណើនរូបិយវត្ថុទូទៅ**
(ឆ្នាំ២០១២ - ឆ្នាំ២០២២ប)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា, *ប=បឋាន់ស្មាន

**ក្រាហ្វ ៣៤ ៖ ប្រាក់បញ្ញើជារៀល និងរូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ**
(ឆ្នាំ២០១២ - ឆ្នាំ២០២២ប)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា, *ប=បឋាន់ស្មាន

## ២- ការអនុវត្តនយោបាយរូបិយវត្ថុ

ការអនុវត្តនយោបាយរូបិយវត្ថុមានបញ្ហាប្រឈមខ្លាំង ដោយសារអតិផរណាបានកើនឡើងដែលបណ្ដាលមកពីកត្តាខាងក្រៅ (ការឡើងថ្លៃប្រេងឥន្ធនៈ និងម្ហូបអាហារសកល) ខណៈដែលអត្រាប្ដូរប្រាក់បន្តរងសម្ពាធធ្លាក់ថ្លៃក្នុងស្ថានភាពដែលដុល្លារអាមេរិកឡើងថ្លៃ ក្រោយពេលដែលធនាគារកណ្ដាលអាមេរិកដំឡើងអត្រាការប្រាក់។ លើសពីនេះ នយោបាយរូបិយវត្ថុក៏ត្រូវគាំទ្រដល់ការងើបឡើងនៃសេដ្ឋកិច្ចក្រោយវិបត្តិកូវីដ-១៩។ ក្នុងស្ថានភាពនេះ ឧបករណ៍រូបិយវត្ថុនានាត្រូវបានប្រើប្រាស់ដោយប្រុងប្រយ័ត្ន និងថ្លឹងថ្លែងដើម្បីរក្សាស្ថិរភាពអត្រាប្ដូរប្រាក់ក្នុងគោលដៅរួមចំណែកបន្ថយសម្ពាធអតិផរណា និងការពារអំណាចទិញនៃប្រាក់រៀល ព្រមទាំងរក្សាកម្រិតសន្ទនីយភាពសមស្របជាមួយការបន្ទាបអត្រាការប្រាក់រៀលដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច។

---

[៣៤] ជាប្រាក់ដុល្លារអាមេរិកកើន ១១,១% និងជាប្រាក់រៀលកើន ១៨,៧%

## ក- ការធ្វើអន្តរាគមន៍ទីផ្សារប្តូរប្រាក់

ធនាគារជាតិនៃកម្ពុជាបានលក់ដុល្លារអាមេរិកត្រឹមតែ ៩ លានដុល្លារអាមេរិកទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធៀបនឹងការលក់ ៥៩១,២ លានដុល្លារអាមេរិក និងទិញ ៣៧ លានដុល្លារអាមេរិក កាលពីឆ្នាំមុន។ ដោយឡែក មានការលក់ប្រាក់ដុល្លារអាមេរិក ៥៤ លានដុល្លារអាមេរិក និងការទិញ ២៣,១ លានដុល្លារអាមេរិកជាមួយស្ថាប័នរដ្ឋ ធៀបនឹងកាលពីឆ្នាំ២០២១មានការលក់ ៧,១ លានដុល្លារអាមេរិក និងការទិញ ៥៥,៣ លានដុល្លារអាមេរិក។

**ក្រាហ្វ ៣៥ ៖ អន្តរាគមន៍ទិញ-លក់ប្រាក់ដុល្លារអាមេរិក**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៨ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣៦ ៖ ការទិញលក់ប្រាក់ដុល្លារអាមេរិកជាមួយស្ថាប័នរដ្ឋ**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៨ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ- អត្រាប្រាក់បម្រុងកាតព្វកិច្ច

អត្រាប្រាក់បម្រុងកាតព្វកិច្ចត្រូវបានរក្សាក្នុងកម្រិត ៧% ទាំងជារៀល និងជាដុល្លារអាមេរិក[៣៥]។ ជាមួយនឹងកម្រិតទាបនេះ ប្រព័ន្ធធនាគារមានសន្ទនីយភាពបន្ថែមចំនួន ១០,៩ ទ្រីលានរៀល (២,៦ ប៊ីលានដុល្លារអាមេរិក) បើធៀបនឹងអត្រាមុនវិបត្តិ (១២,៥% សម្រាប់ដុល្លារអាមេរិក និង ៨% សម្រាប់រៀល)។ ការផ្តល់សន្ទនីយភាពដល់ប្រព័ន្ធធនាគារបានរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្ត

**ក្រាហ្វ ៣៧ ៖ ទំហំនិងអត្រាប្រាក់បម្រុងកាតព្វកិច្ច**
(ទិន្នន័យចុងគ្រា, ឆ្នាំ១៩៩៣ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៣៥] អត្រាប្រាក់បម្រុងកាតព្វកិច្ចត្រូវបានកាត់បន្ថយពី ៨% ចំពោះប្រាក់រៀល និង ១២,៥% ចំពោះរូបិយប័ណ្ណ មកត្រឹម ៧% ទាំងចំពោះប្រាក់រៀលនិងរូបិយប័ណ្ណ ចាប់ពីខែមេសា ឆ្នាំ២០២០។

វិធានការរៀបចំឥណទានឡើងវិញ ការបង្កើនសំវិធានធន គាំទ្រកំណើនឥណទាននិងពង្រឹងការការពារហានិភ័យសន្ទនីយភាព។ បច្ចុប្បន្ន ប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិកមាន ១៣,៧ ទ្រីលានរៀល (ប្រមាណ ៣,៣ ប៊ីលានដុល្លារអាមេរិក) និងជារៀល ១,៣ ទ្រីលានរៀល (៣១៧,៧ លានដុល្លារអាមេរិក) ដែលប្រាក់បម្រុងកាតព្វកិច្ចមាននិន្នាការកើនឡើង ១១% និង ២៣% រៀងគ្នា ធៀបនឹងឆ្នាំ២០២១ ស្របតាមកំណើនប្រាក់បញ្ញើរបស់អតិថិជន និងការខ្ចីក្រៅប្រទេស។

**ក្រាហ្វ ៣៨ ៖ សន្ទនីយភាពលើសជារៀល និងដុល្លារអាមេរិក**
(ខែមករា ឆ្នាំ២០១៩ - ខែធ្នូ ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សន្ទនីយភាពលើសជាដុល្លារអាមេរិកបានថយចុះ -២៥,៦% ធៀបនឹងឆ្នាំមុន មកត្រឹម ២១,២ ទ្រីលានរៀល (៥,១ ប៊ីលានដុល្លារអាមេរិក) និងសន្ទនីយភាពលើសជារៀលបានកើនឡើង ៨% ដល់ ៤,៧ ទ្រីលានរៀល (១,១ ប៊ីលានដុល្លារអាមេរិក) ដោយសារការថយចុះនៃប្រាក់បញ្ញើរដ្ឋាភិបាល (-១២,៣%) និងរូបិយវត្ថុក្នុងចរាចរណ៍ (-១,៧%)។ អនុបាតសន្ទនីយភាពលើសធៀបនឹងប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិកមានកម្រិត ១៥៥% (៣,៣ ប៊ីលានដុល្លារអាមេរិក) និងជារៀល ១៧០% (៣១៧,៧ លានដុល្លារអាមេរិក) ដែលបង្ហាញពីសន្ទនីយភាពខ្ពស់ក្នុងប្រព័ន្ធធនាគារ។

**ក្រាហ្វ ៣៩ ៖ អនុបាតសន្ទនីយភាពលើសធៀបនឹងប្រាក់បម្រុងកាតព្វកិច្ចជារៀល និងដុល្លារអាមេរិក**
(ខែមករា ឆ្នាំ២០១៩ - ខែធ្នូ ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## គ- ការចេញផ្សាយមូលបត្រអាចជួញដូរបាន

មូលបត្រអាចជួញដូរបាន (NCD) ត្រូវបានប្រើប្រាស់ជាឧបករណ៍ស្រូបយកសន្ទនីយភាពលើសពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងផ្តល់ជាវត្ថុធានាសម្រាប់ប្រតិបត្តិការអន្តរធនាគារ។ NCD ដែលបានចេញផ្សាយសរុបមាន ៣៧,៥ ប៊ីលានដុល្លារអាមេរិក (កើន ៣,៧%) ដោយសារសន្ទនីយភាពលើសមួយផ្នែកត្រូវបានប្រើប្រាស់ដើម្បីគាំទ្រកំណើនឥណទានទៅកាន់វិស័យឯកជន។

**ក្រាហ្វ ៤០ ៖ ចំនួន និងទំហំទឹកប្រាក់ NCD ជាដុល្លារអាមេរិក ដែលបានចេញផ្សាយ និងមិនទាន់ដល់កាលប្រតិទាន**
(ឆ្នាំ២០១៣ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ចំពោះប្រាក់រៀល ការចេញផ្សាយ NCD បានថយចុះ -៤,៥% ដែលក្នុងនោះ NCD ជារៀលដែលមានឥណប្រតិទាន ៧ថ្ងៃ ២៨ថ្ងៃ និង៩១ថ្ងៃ បានថយចុះ -១៦% -២៤,៣% និង -៤២,១% មក ៦,៦ ទ្រីលានរៀល ៣,៣ ទ្រីលានរៀលនិង ៤៤៣ ប៊ីលានរៀល រៀងគ្នា បើទោះបីជា NCD ជារៀលដែលមានឥណប្រតិទាន ១៤ថ្ងៃ ១៨២ថ្ងៃ និង ៣៦៤ថ្ងៃ បានកើនឡើង ០,៦% ២៧,៣% និង ៨៣៤,២% ដល់ ៤,៩ ទ្រីលានរៀល ៣១ ប៊ីលានរៀល និង ៣៥,៥ ប៊ីលានរៀល ក៏ដោយ។

**ក្រាហ្វ ៤១ ៖ ចំនួន និងទំហំទឹកប្រាក់ NCD ជារៀល ដែលបានចេញផ្សាយ និងមិនទាន់ដល់ឥណប្រតិទាន**
(ឆ្នាំ២០១៤ - ឆ្នាំ២០២២)



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ចំពោះប្រាក់ដុល្លារអាមេរិក ការចេញផ្សាយ NCD បានកើនឡើង ៤,៩% ដែលបណ្តាលមកពីកំណើនរឹងមាំនៃឥណទានទៅកាន់វិស័យឯកជន ដែលក្នុងនោះ NCD ឥណប្រតិទាន ២៨ថ្ងៃ ៩១ថ្ងៃ និង១៨២ថ្ងៃ ថយចុះ -៣៩,១% -៣២,៤% និង -៣៤,៥% មកត្រឹម ៧,៣ ប៊ីលាន ១,៩ ប៊ីលាន និង ៧០៧ លានដុល្លារអាមេរិក រៀងគ្នា ខណៈដែលការចេញផ្សាយ NCD ដែលមានឥណប្រតិទាន ៧ថ្ងៃ ១៤ថ្ងៃ និង៣៦៤ថ្ងៃ កើន ៣២,៤% ១០,៩% និង ១,៩% ដល់ ១៤,១ ប៊ីលាន ៤,៦ ប៊ីលាន និង ៩០២ លានដុល្លារអាមេរិក។

អត្រាការប្រាក់ NCD ជារៀលបានកើនបន្តិចពី ១,២២% នៅឆ្នាំមុនទៅ ១,៣៧% ស្របពេលដែលជាដុល្លារអាមេរិកបានកើនឡើងគួរកត់សម្គាល់ ពី ០,០៦% ទៅ ១,៥៤% ដោយសារនិន្នាការកើនឡើងនៃទីផ្សារអន្តរធនាគារនៅសហរដ្ឋអាមេរិក (SOFR) បន្ទាប់ពីធនាគារកណ្តាលអាមេរិកដំឡើងអត្រាការប្រាក់គោលជាបន្តបន្ទាប់។ អត្រាការប្រាក់ NCD ជារៀល ជាមធ្យមសម្រាប់ឥណប្រតិទាន ៧ថ្ងៃ ១៤ថ្ងៃ ២៨ថ្ងៃ ៩១ថ្ងៃ ១៨២ថ្ងៃ និង៣៦៤ថ្ងៃ បានកើនពី ០,៤៩% ០,៥៩% ០,៩៩% ១,៥៦% ១,៧៥% និង ១,៩៥% ទៅ ០,៨៥% ០,៩៤% ១,០៤% ១,៥៩% ១,៧៩% និង ១,៩៩% រៀងគ្នា។ អត្រាការប្រាក់ NCD ជាដុល្លារអាមេរិកបានកើនឡើងពី ០,០២% ០,០២% ០,០២% ០,០៥% ០,១០% និង ០,១៥% ទៅដល់ ១,១៤% ១,១៩% ១,២៨% ១,៥៨% ១,៨៨% និង ២,២០% រៀងគ្នា។ ជារួម ការកើនឡើងនៃអត្រាការប្រាក់នេះមានកម្រិតប្រហាក់ប្រហែលនឹងការកើនឡើងនៃ SOFR ដោយបានកើនឡើងពី ០,០៥% កាលពីឆ្នាំមុន ទៅ ២,១% នៅឆ្នាំនេះ។ ទោះយ៉ាងណា កម្រិតនៃកំណើននេះមានភាពមិនស្មើគ្នារវាងឥណប្រតិទាន

**ក្រាហ្វ ៤២ ៖ អត្រាការប្រាក់ NCD ជារៀលនិងដុល្លារអាមេរិក**
(គិតជាមធ្យមប្រចាំថ្ងៃ, ឆ្នាំ២០២១ - ឆ្នាំ២០២២)



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ទាំងអស់នោះទេ ដោយឥណប្រតិទានស្មើឬក្រោម ៩១ថ្ងៃ SOFR មានការកើនឡើងលឿនជាងអត្រាការប្រាក់ NCD ជាដុល្លារអាមេរិកប្រមាណ ០,៥១% ចំណែកឥណប្រតិទានចាប់ពី ១៨២ថ្ងៃ SOFR បានកើនឡើងក្នុងកម្រិតលឿនជាង ០,៦៥%។

### ឃ- ការបោះផ្សាយមូលបត្ររដ្ឋ

**ក្រាហ្វ ៤៣ ៖ មូលបត្ររដ្ឋដែលបានដេញថ្លៃ**
(គិតត្រឹមឆ្នាំ២០២២)



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

បន្ទាប់ពីបានផ្អាកមួយរយៈ រាជរដ្ឋាភិបាលបានសម្រេចបោះផ្សាយមូលបត្ររដ្ឋឡើងវិញ ក្នុងគោលបំណងរួមចំណែកអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុកម្ពុជា និងកេណ្ឌប្រមូលមូលធនក្នុងស្រុកជាប្រាក់រៀល ដើម្បីប្រើប្រាស់ក្នុងការវិនិយោគរយៈពេលមធ្យមនិងវែង។ ធនាគារជាតិនៃកម្ពុជាបានទទួលបន្ទុកជាភ្នាក់ងារបោះផ្សាយនិងទូទាត់មូលបត្រ[៣៦]នៅលើទីផ្សារដំបូង (Primary market) ដែលមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាអ្នកចូលរួមជាវ។

នៅឆ្នាំ២០២២នេះ មូលបត្ររដ្ឋត្រូវបានបោះផ្សាយចំនួន ៥ លើក តាមរយៈការដេញថ្លៃនៅលើផ្លែតហ្វម NBCP ដែលមានទឹកប្រាក់ចំនួន ៧២,១ ប៊ីលានរៀល (១៧,៦ លានដុល្លារអាមេរិក) ទាបជាងការគ្រោងទុក (១,២ ទ្រីលានរៀល ឬ៣០០លានដុល្លារអាមេរិក)។ ការបោះផ្សាយបានក្នុងចំនួនទាបជាងការគ្រោងទុកនេះ គឺដោយសារការពន្យារពេលនៃការចេញបោះផ្សាយ[៣៧]ក៏ដូចជាការដេញថ្លៃមួយចំនួនមិនទទួលបានជោគជ័យ។ ឥណប្រតិទាននៃមូលបត្ររដ្ឋដែលបានបោះផ្សាយមានរយៈពេល ១ឆ្នាំ ក្នុងអត្រាចំណូលជាមធ្យម ២,២%។

ការបោះផ្សាយមូលបត្ររដ្ឋគឺជាជំហានយ៉ាងសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុក្នុងស្រុកបន្ថែមទៀត ក៏ដូចជាការលើកកម្ពស់ការអនុវត្តនយោបាយរូបិយវត្ថុ ផ្អែកលើយន្តការទីផ្សារតាមរយៈការបង្កើតឧបករណ៍រូបិយវត្ថុមួយដែលគ្មានហានិភ័យ ការផ្តល់ជាឧបករណ៍សម្រាប់ប្រើជាប្រាតិភោគដើម្បីទទួលបានហិរញ្ញប្បទាន ជាប្រភពទុនដែលមានស្ថិរភាពធៀបនឹងប្រភពទុនក្រៅប្រទេស និងជួយជំរុញការប្រើប្រាស់ប្រាក់រៀលនៅកម្ពុជា។

[៣៦] ធនាគារជាតិនៃកម្ពុជាត្រូវបានចាត់តាំងជាអាណត្តិគាហករបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ការបោះផ្សាយមូលបត្ររដ្ឋ ហើយមានតួនាទីសម្របសម្រួលដល់ប្រតិបត្តិការនេះ។ មូលបត្ររដ្ឋត្រូវបានដាក់ឱ្យដេញថ្លៃលើផ្លែតហ្វមធនាគារជាតិនៃកម្ពុជា (NBCP) សម្រាប់សមាជិករបស់ NBCP ដោយប្រើយន្តការកំណត់តម្លៃតែមួយ (Single Price)។

[៣៧] ការបោះផ្សាយលើកដំបូងត្រូវបានធ្វើឡើង នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២២។

## ខ- ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា

ការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ត្រូវបានធ្វើឡើងចំនួន ២៤ លើក ស្មើនឹង ១,៥ ទ្រីលានរៀល។ LPCO ដែលមានឥណប្រតិទាន ៩១ថ្ងៃ បានថយ -៦៨% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន មកត្រឹម ៣៧៤ ប៊ីលានរៀល ឥណប្រតិទាន ១៨២ថ្ងៃ ថយ -៦៦,៨% មកត្រឹម ៥០៤ ប៊ីលានរៀល និងឥណប្រតិទាន ៣៦៤ថ្ងៃ ថយ -៦០% មកត្រឹម ៦៣២ ប៊ីលានរៀល។ ទំហំប្រតិបត្តិការ LPCO ថយចុះ -៦៥% ធៀបនឹងឆ្នាំមុន (៤,២ ទ្រីលានរៀល ស្មើនឹងប្រមាណ ១ ប៊ីលានដុល្លារអាមេរិក) ដោយសារការកាត់បន្ថយចំនួនទឹកប្រាក់ដេញថ្លៃ ដើម្បីរួមចំណែកបន្ថយសម្ពាធថយថ្លៃនៃអត្រាប្តូរប្រាក់រៀល។ ក៏ប៉ុន្តែការបន្ថយចំនួនទឹកប្រាក់ LPCO ក៏បានធ្វើឱ្យអត្រាការប្រាក់ LPCO បានកើនឡើងផងដែរ។ ជាក់ស្តែងអត្រាការប្រាក់មធ្យមសម្រាប់ឥណប្រតិទាន ៩១ថ្ងៃ បានកើនពី ៤,២% នៅឆ្នាំ២០២១ ដល់ ៥,៥% សម្រាប់ឥណប្រតិទាន ១៨២ថ្ងៃ កើនពី ៤,៤% ដល់ ៥,៨% និងសម្រាប់ឥណប្រតិទាន ៣៦៤ថ្ងៃ កើនពី ៤,៩% ដល់ ៦,០%។ ជាលទ្ធផល ទំហំទឹកប្រាក់ប្រតិបត្តិការ LPCO ដែលមិនទាន់ដល់ឥណប្រតិទានបានថយចុះ -៥៣,៧% មកនៅ ៩៤៧ ប៊ីលានរៀល (ស្មើនឹង ២៣០,៩ លានដុល្លារអាមេរិក)។

**ក្រាហ្វ ៤៤ ៖ ការផ្តល់សន្ទនីយភាពជារៀលតាមរយៈប្រតិបត្តិការ LPCO ប្រចាំខែ**
(គិតជាប៊ីលានរៀល, ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤៥ ៖ ការផ្តល់សន្ទនីយភាពជារៀលតាមរយៈប្រតិបត្តិការ LPCO ប្រចាំឆ្នាំ**
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៨ - ២០២២)




**ក្រាហ្វ ៤៦ ៖ អត្រាការប្រាក់ដេញថ្លៃឈ្នះប្រតិបត្តិការ LPCO ប្រចាំខែ**
(គិតជាភាគរយ, ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ច- ប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF)

MLF ជាឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លីដែលជួយបំពេញតម្រូវការសន្ទនីយភាពចាំបាច់ជាប្រាក់រៀលសម្រាប់រយៈពេលមួយថ្ងៃ និងអាចបន្តបានរយៈពេល ៥ ថ្ងៃ ក្នុងអត្រាការប្រាក់ ៤% ក្នុងមួយឆ្នាំ ដោយមានវត្ថុធានាជា NCD ជាប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិក[៣៨] និងមូលបត្ររដ្ឋ។ គ្រឹះស្ថានធនាគារចំនួន ៣ បានប្រើប្រាស់ MLF ចំនួន ៣២,៨ ប៊ីលានរៀល ដែល MLF របស់ធនាគារនីមួយៗ មានឥណប្រតិទានចំនួន ១ថ្ងៃ។ បច្ចុប្បន្ន មានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ២៩ ទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាសម្រាប់ការប្រើប្រាស់ MLF។

**ក្រាហ្វ ៤៧ ៖ ប្រតិបត្តិការសន្ទនីយភាពរយៈពេលខ្លី**
(ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ឆ- ការចាក់បញ្ចូលសន្ទនីយភាពសុទ្ធជារៀល

ការចាក់បញ្ចូលសន្ទនីយភាពសុទ្ធជារៀល[៣៩] មាននិន្នាការថយចុះជាបន្តបន្ទាប់ពី ៥៨៥,១ ប៊ីលានរៀល នៅខែមករា ឆ្នាំ២០២២ មកត្រឹម ២៨៨,៨ ប៊ីលានរៀល ក្នុងខែតុលា និងបានស្រូបយកសន្ទនីយភាពជារៀលវិញចាប់ពីខែវិច្ឆិកា ឆ្នាំ២០២២ ក្នុងកម្រិត ៤៩០ ប៊ីលានរៀល (ថយចុះ -១៦១% ធៀបនឹងឆ្នាំមុន)។ និន្នាការថយចុះនេះ បណ្តាលមកពីការកាត់បន្ថយទំហំប្រតិបត្តិការ LPCO (LPCO មិនទាន់ដល់ឥណប្រតិទានថយ -៥៤% ពី ២,១ ទ្រីលានរៀល នៅគ្រាដូចគ្នាឆ្នាំមុន មក ៩៦៩,៤ ប៊ីលានរៀល នៅ ចុងឆ្នាំ២០២២) ស្របពេលដែល NCD មិនទាន់ដល់ឥណប្រតិទានមាននិន្នាការកើនឡើងមកវិញជាលំដាប់ដល់ ១,៤ ទ្រីលានរៀល បន្ទាប់ពីបានថយចុះដល់ ២៧៣,៦ ប៊ីលានរៀល កាលពីខែមីនា។ ការរឹតត្បិតការបញ្ចេញសន្ទនីយភាពជារៀលនេះ ធ្វើឡើងដើម្បីរួមចំណែកបន្ថយសម្ពាធថយថ្លៃនៃប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ក្នុងបរិការណ៍នៃការឡើងថ្លៃប្រាក់ដុល្លារអាមេរិកនៅលើទីផ្សារអន្តរជាតិ។

**ក្រាហ្វ ៤៨ ៖ ការចាក់បញ្ចូលសន្ទនីយភាព**
(គិតជាទ្រីលានរៀល, ខែមករា ឆ្នាំ២០១៧ - ខែធ្នូ ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

---

[៣៩] ការចាក់បញ្ចូលសន្ទនីយភាពសុទ្ធជារៀល ជាផលដករវាងប្រតិបត្តិការ LPCO មិនទាន់ដល់ឥណប្រតិទាន និង NCD មិនទាន់ដល់ឥណប្រតិទាន។ នៅពេលដែលផលដកមានសញ្ញាវិជ្ជមាន មានន័យថាជាការចាក់បញ្ចូលសន្ទនីយភាពសុទ្ធជារៀល ដោយឡែក នៅពេលដែលផលដកមានសញ្ញាអវិជ្ជមាន មានន័យថាជាការស្រូបយកសន្ទនីយភាពសុទ្ធជារៀល។

## IV- ស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជា

### ១- ស្ថានភាពទូទៅ

ប្រព័ន្ធធនាគារកម្ពុជាមានធនាគារពាណិជ្ជ ៥៩ ធនាគារឯកទេស ៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៨២ គ្រឹះស្ថានឥណទានជនបទ ២២៤ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ១៦ អ្នកដំណើរការតតិយភាគី ៥ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ៣៤ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ១ ការិយាល័យតំណាងធនាគារបរទេស ៦ និងអាជីវកម្មប្តូរប្រាក់ ២.៨៦៩។

**ក្រាហ្វ ៤៩ ៖ ប្រព័ន្ធធនាគារកម្ពុជា**

(គិតជាចំនួន, ខែតុលា ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រព័ន្ធធនាគារកម្ពុជានៅបន្តប្រមូលផ្តុំភាគច្រើនដោយវិស័យធនាគារ ដែលរួមចំណែកប្រមាណ ៨៥,២% នៃទ្រព្យសកម្មសរុបប្រព័ន្ធធនាគារ បន្ទាប់មកវិស័យមីក្រូហិរញ្ញវត្ថុរួមចំណែកប្រមាណ ១៤,២% និងគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ០,៦%។ ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារ[៤០]បន្តមានកំណើន ១៤,៥% (១៦% ឆ្នាំមុន) ដល់ ៣២៥,៨ ទ្រីលានរៀល (៧៩,៧ ប៊ីលានដុល្លារអាមេរិក) ដោយសារការកើនឡើងនៃចំនួនគ្រឹះស្ថានថ្មីៗចំនួន៧ (គ្រឹះស្ថានធនាគារពាណិជ្ជ ៤ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៣) ដែលទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការពីធនាគារជាតិនៃកម្ពុជា។

---

[៤០] រាប់បញ្ចូលធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ។

**ក្រាហ្វ ៥០ ៖ ចំណែកទ្រព្យសកម្មក្នុងប្រព័ន្ធធនាគារ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២២ប)




**ក្រាហ្វ ៥១ ៖ ទ្រព្យសកម្មក្នុងប្រព័ន្ធធនាគារ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២២ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

ឥណទានអតិថិជនកើនឡើង ២០,២% (២១,២% ឆ្នាំមុន) ដល់ ២២៩,៥ ទ្រីលានរៀល (៥៦,១ ប៊ីលានដុល្លារអាមេរិក) ជាចម្បងដោយសារការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច និងតម្រូវការហិរញ្ញប្បទានរបស់អតិថិជន។ ជាមួយគ្នានេះដែរ ប្រាក់បញ្ញើអតិថិជនមានកំណើន ១១,៣% (១៥,៤% ឆ្នាំមុន) ដល់ ១៧៨,៥ ទ្រីលានរៀល (៤៤,៦ ប៊ីលានដុល្លារអាមេរិក)។

**ក្រាហ្វ ៥២ ៖ ឥណទានក្នុងប្រព័ន្ធធនាគារ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២២ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

**ក្រាហ្វ ៥៣ ៖ ប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២២ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

ដើម្បីរួមចំណែកជួយសម្រាលបន្ទុកប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងពីគ្រោះទឹកជំនន់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានផ្តល់ការអនុគ្រោះដល់អ្នកខ្ចីប្រាក់ តាមរយៈការរៀបចំឥណទានឡើងវិញចំនួន ១៨៣.១១៧ គណនី (ថយ -៤៩% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន) និងជាទំហំទឹកប្រាក់ ៣,៣ ប៊ីលានដុល្លារអាមេរិក (ថយ -៣៨%) ដែលមានសមាមាត្រប្រមាណ ៦,២% នៃទំហំឥណទានសរុបក្នុងប្រព័ន្ធធនាគារ (១២,៥% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន)។ ជារួម ឥណទានរៀបចំឡើងវិញបានបង្ហាញនិន្នាការថយចុះជាលំដាប់ ដែលមួយផ្នែកដោយសារការបញ្ចប់វិធានការអនុគ្រោះលើឥណទានរៀបចំឡើងវិញត្រឹមខែមិថុនាឆ្នាំ២០២២ និងមួយផ្នែកទៀតដោយសារការងើបឡើងជាលំដាប់នៃដំណើរការសកម្មភាពសេដ្ឋកិច្ចឡើងវិញក្នុងគន្លងប្រក្រតីថ្មី។

**ក្រាហ្វ ៥៤៖ ចំនួនគណនីឥណទានរៀបចំឡើងវិញសរុប**

(ខែមករា ឆ្នាំ២០២១ - ខែតុលា ឆ្នាំ២០២២)




**ក្រាហ្វ ៥៥៖ សមតុល្យឥណទានរៀបចំឡើងវិញសរុប**

(គិតជាលានដុល្លារអាមេរិក ខែមករា ឆ្នាំ២០២១ - ខែតុលា ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៥៦ ៖ ចំនួនគណនីឥណទានរៀបចំឡើងវិញតាមវិស័យ**

(ខែមករា ឆ្នាំ២០២១ - ខែតុលា ឆ្នាំ២០២២)




**ក្រាហ្វ ៥៧ ៖ សមតុល្យឥណទានរៀបចំឡើងវិញតាមវិស័យ**

(គិតជាលានដុល្លារអាមេរិក, ខែមករា ឆ្នាំ២០២១ - ខែតុលា ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ទោះបីជាទទួលរងឥទ្ធិពលពីវិបត្តិ ប្រព័ន្ធធនាគារបន្តមានស្ថិរភាពរឹងមាំ និងមានភាពធន់ដោយឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗដូចខាងក្រោម៖

i/-ស្ថានភាពដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តមានភាពរឹងមាំ និងអនុលោមតាមបទប្បញ្ញត្តិ (១៥%) ដោយអនុបាតសាធនភាពវិស័យធនាគារមានកម្រិតជាមធ្យម ២២,៥% និងវិស័យមីក្រូហិរញ្ញវត្ថុមានកម្រិត ២១,២%។ ទ្រនាប់ដើមទុនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់បានទាំងស្រុង (១០០%) ដើម្បីបង្កើនលទ្ធភាពក្នុងការធ្វើសំវិធានធនដោយមិនប៉ះពាល់ដល់ដើមទុនរបស់គ្រឹះស្ថាន។

**ក្រាហ្វ ៥៨ ៖ អនុបាតសាធនភាព**

(គិតជាភាគរយ, ឆ្នាំ២០១៧ - ខែកញ្ញា ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ii/-សន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បន្តមានកម្រិតខ្ពស់ជាងកម្រិតកំណត់នៃបទប្បញ្ញត្តិ (១០០%) ដោយអនុបាតក្របខ័ណ្ឌសន្ទនីយភាពរបស់ធនាគារពាណិជ្ជជាមធ្យមមានកម្រិត ១៤៣% និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើជាមធ្យម ១៧២,៨% ដែលបង្ហាញពីលទ្ធភាពឆ្លើយតបទៅនឹងតម្រូវការឥណទាន និងអាចទប់ទល់នឹងការដកប្រាក់បញ្ញើរបស់អតិថិជន។

iii/-អនុបាតឥណទានមិនដំណើរការដែលឆ្លុះបញ្ចាំងពីគុណភាពឥណទាន មាននិន្នាការកើនឡើងបន្តិច ប៉ុន្តែបន្តស្ថិតនៅកម្រិតទាប ក្នុងនោះវិស័យធនាគារមានកម្រិត ៣,២% និងវិស័យមីក្រូហិរញ្ញវត្ថុមានកម្រិត ២,៦%។

**ក្រាហ្វ ៥៩ ៖ អនុបាតក្របខ័ណ្ឌសន្ទនីយភាព**

(គិតជាភាគរយ, ឆ្នាំ២០១៧ - ខែកញ្ញា ឆ្នាំ២០២២)




**ក្រាហ្វ ៦០ ៖ អនុបាតឥណទានមិនដំណើរការ**

(គិតជាភាគរយ, ឆ្នាំ២០១៧ - ខែកញ្ញា ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

iv/-លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បន្តមានចីរភាព ដោយអនុបាតប្រាក់ចំណេញធៀបទ្រព្យសកម្ម (ROA) និងអនុបាតប្រាក់ចំណេញធៀបមូលនិធិភាគទុនិក (ROE) របស់វិស័យធនាគារ មានកម្រិត ១,៤% និង ៧,៥% រៀងគ្នា ខណៈវិស័យមីក្រូហិរញ្ញវត្ថុមានកម្រិត ៣,១% និង ១៤,៣% រៀងគ្នា។ ការរក្សាបានលទ្ធភាពស្វែងរកប្រាក់ចំណេញក៏បានជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុពង្រឹងភាពធន់នឹងវិបត្តិក៏ដូចជាលទ្ធភាពពង្រីកវិសាលភាពសេវាហិរញ្ញវត្ថុរបស់ខ្លួនឱ្យកាន់តែទូលំទូលាយ។

**ក្រាហ្វ ៦១ ៖ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម**

(គិតជាភាគរយ, ឆ្នាំ២០១៧ - ខែកញ្ញា ឆ្នាំ២០២២)




**ក្រាហ្វ ៦២ ៖ អនុបាតប្រាក់ចំណេញធៀបមូលនិធិភាគទុនិក**

(គិតជាភាគរយ, ឆ្នាំ២០១៧ - ខែកញ្ញា ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២- វិស័យធនាគារ

ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារបាន កើនឡើង ១៣,២% ដល់ ២៧៨,១ ទ្រីលានរៀល (៦៧,៩ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះឥណទាន អតិថិជនកើន ១៩,៣% ដល់ ១៨៨,១ ទ្រីលានរៀល (៤៦ ប៊ីលានដុល្លារអាមេរិក) ដោយមានចំនួន ១,៥ លានគណនី។ ឥណទានត្រូវបានផ្តល់ទៅកាន់ វិស័យសំខាន់ៗក្នុងសេដ្ឋកិច្ចដូចជា៖ ការជួញដូរ រាយ ១៦,២% នៃឥណទានសរុប(មានកំណើន ២៧%) ការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ១៣,៩% (៣៥,៦%) ការជួញដូរដុំ ៩,៧% (២៣,២%) សំណង់ ៩,៤% (២០,៩%) ការជួញដូរអចលនទ្រព្យ ៩,៤% (២៩%) កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៨,២% (៣៥,១%) និងផ្សេងៗ ២៣,២% (២៦,៧)%។ ប្រាក់បញ្ញើបានកើនឡើង ៩,៩% ដល់ ១៥៧,៩ ទ្រីលានរៀល (៣៨,៦ ប៊ីលានដុល្លារអាមេរិក) និងមានចំនួន ១១,៧ លានគណនី។ បច្ចុប្បន្នទីស្នាក់ការកណ្តាលនិងសាខារបស់គ្រឹះស្ថានធនាគារមាន ១.៥០៤ ទីតាំង (១,៤%) និងម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) មាន ៣.៩៣៣ (កើន ២៤,២%)។

**ក្រាហ្វ ៦៣ ៖ ឥណទានគ្រឹះស្ថានធនាគារតាមវិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច**
(ឆ្នាំ២០២២ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

**ក្រាហ្វ ៦៤ ៖ ការរួមចំណែកក្នុងកំណើនឥណទានគ្រឹះស្ថានធនាគារតាមវិស័យ**
(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២២ប)




**ក្រាហ្វ ៦៥ ៖ កំណើនឥណទានគ្រឹះស្ថានធនាគារតាមវិស័យ**
(គិតជាភាគរយ, ឆ្នាំ២០២០ - ២០២២ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

អត្រាការប្រាក់បញ្ញើក្នុងវិស័យធនាគារមានការកើនឡើង ដោយប្រាក់បញ្ញើជារៀល និងជាដុល្លារអាមេរិកជាមធ្យម មានអត្រា ៧,១១% និង ៥,៦៥% រៀងគ្នាខ្ពស់ជាងឆ្នាំមុនបន្តិច (៦,១៦% និង ៤,៧៥% រៀងគ្នា)។ ទន្ទឹមនេះ អត្រាការប្រាក់ឥណទានជារៀល និងជាដុល្លារអាមេរិក ជាមធ្យមក៏បានកើនឡើងផងដែរ ដោយមានអត្រា ១២,៩៣% និង ១៣,១៨% រៀងគ្នា ធៀបនឹងឆ្នាំមុន ១២,៤៨% និង១០,៦៨ រៀងគ្នា។

**ក្រាហ្វ ៦៦ ៖ អត្រាការប្រាក់ជាមធ្យមរបស់គ្រឹះស្ថានធនាគារ**
(គិតជាភាគរយ, ឆ្នាំ២០១៥ - ខែកញ្ញា ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៣- វិស័យមីក្រូហិរញ្ញវត្ថុ

ទ្រព្យសកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនឡើង ២៣,២% ដល់ ៤៥,៨ ទ្រីលានរៀល (១១,២ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះឥណទានអតិថិជនបានកើនឡើង ២៤,៧% ដល់ ៣៩,៧ ទ្រីលានរៀល (៩,៧ ប៊ីលានដុល្លារអាមេរិក) ដោយមាន ២,១ លានគណនី។ ឥណទានទាំងនេះបានផ្តល់ទៅកាន់វិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច រួមមាន៖ ក្រុមគ្រួសារ ៣២,៨% នៃឥណទានសរុប (មានកំណើន ១១,៧%) ពាណិជ្ជកម្មនិងជំនួញ ២៣,២% (២០%) កសិកម្ម ១៧,៦% (៤,៦%) សេវាកម្ម ១៣,៨% (៩,៧%) ដឹកជញ្ជូន ៤,៦% (-៦%) សំណង់ ៤,៦% (៣៦%) កម្មន្តសាល ១,៨% (៣៦,៦%) និងផ្សេងៗ ១,៦% (៦២%)។ ទន្ទឹមនេះ វិស័យមីក្រូហិរញ្ញវត្ថុបានកេណ្ឌប្រមូលប្រាក់បញ្ញើ ២០,៧ ទ្រីលានរៀល (៥,១ ប៊ីលានដុល្លារអាមេរិក កើនឡើង ២១,២%) ដែលមាន ២,៦ លានគណនី។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានបណ្តាញប្រតិបត្តិការគ្របដណ្តប់ទូទាំងប្រទេស ដែលមានការិយាល័យចំនួន ១.១០២ ទីតាំង និងបានផ្តល់សេវាកម្មដូចជា ឥណទាន ប្រាក់បញ្ញើ ការផ្ទេរប្រាក់ ធនាគារចល័ត និងការដកនិងដាក់ប្រាក់តាមម៉ាស៊ីន ATM ជាដើម ដែលធ្វើឱ្យអតិថិជនមានលទ្ធភាពប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការបានកាន់តែច្រើន។

**ក្រាហ្វ ៦៧ ៖ ឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តាមវិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច**
(ឆ្នាំ២០២២ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

**ក្រាហ្វ ៦៨ ៖ ការរួមចំណែកក្នុងកំណើនឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាមវិស័យ**

(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២២ប)




**ក្រាហ្វ ៦៩៖ កំណើនឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាមវិស័យ**

(គិតជាភាគរយ, ឆ្នាំ២០២០ - ២០២២ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

អត្រាការប្រាក់បញ្ញើជាមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជារៀល និងជាដុល្លារអាមេរិក បានកើនឡើងដល់ ៧,៥២% និង ៧,៤១% រៀងគ្នា ធៀបនឹងឆ្នាំមុន (៧,១៩% និង ៧% រៀងគ្នា)។ ទន្ទឹមនេះ អត្រាការប្រាក់ឥណទានជាមធ្យមជារៀល បានថយចុះបន្តិច ពី ១៦,៧៤% ឆ្នាំមុន មក ១៦,៧២% ខណៈអត្រាការប្រាក់ឥណទានជាដុល្លារអាមេរិកបានកើនឡើងបន្តិច ពី ១៤,៨០% ឆ្នាំមុន មក ១៤,៩៤%។

**ក្រាហ្វ ៧០ ៖ អត្រាការប្រាក់ជាមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

(គិតជាភាគរយ, ឆ្នាំ២០១៥ - ខែកញ្ញា ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤- គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ

គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុបានអនុវត្តច្បាប់និងបទប្បញ្ញត្តិល្អប្រសើរ និងបន្តមានស្ថានភាពហិរញ្ញវត្ថុរឹងមាំ ដែលឆ្លុះបញ្ចាំងតាមរយៈទ្រព្យសកម្មបានកើនឡើង ១៥% ដល់ ២,១ ទ្រីលានរៀល (៥១៩,៣ លានដុល្លារអាមេរិក)។ ភតិសន្យាហិរញ្ញវត្ថុបានកើនឡើង ១៣,២% ដល់ ១,៨ ទ្រីលានរៀល (៤៤២,៨ លានដុល្លារអាមេរិក) ដោយមាន ៩២.៥៤៧ គណនី ហើយត្រូវបានផ្ដល់ទៅវិស័យជាច្រើនរួមមាន៖ កសិកម្ម ២៨,៧% គ្រួសារ ២១,១% សេវាកម្ម ២០,២% ដឹកជញ្ជូន ៦,៥% សំណង់ ៥,៤% ពាណិជ្ជកម្មនិងជំនួញ ៣,១% និងវិស័យផ្សេងៗ ១៥%។ ប្រភពទុនចម្បងនៃឥណទានភតិសន្យាបានមកពីមូលនិធិភាគទុនិកដោយបានកើនឡើង ៧,៣% ដល់ ៦៤៦,៩ ប៊ីលានរៀល (១៥៨,២ លានដុល្លារអាមេរិក)។ ទីស្នាក់ការកណ្ដាល និងសាខារបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុមានចំនួន ៥១ ទីតាំង។

ក្រាហ្វ ៧១ ៖ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ
(ឆ្នាំ២០១៧ - ឆ្នាំ២០២២ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

## ៥- គ្រឹះស្ថានឥណទានជនបទ

គ្រឹះស្ថានឥណទានជនបទបានរួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដោយបានផ្ដល់សេវាឥណទានខ្នាតតូចនៅតាមជនបទ ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋក្នុងការបង្កើត ឬពង្រីកអាជីវកម្មនានា។ គ្រឹះស្ថានឥណទានជនបទដែលទទួលបានវិញ្ញាបនបត្រពីធនាគារជាតិនៃកម្ពុជា បានផ្ដល់ឥណទានសរុប ២៤៤,១ ប៊ីលានរៀល (៥៩,៣ លានដុល្លារអាមេរិក) ដោយមាន ៧៧.០៩៣ គណនី។

ក្រាហ្វ ៧២ ៖ គ្រឹះស្ថានឥណទានជនបទ
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៨ - ២០២២ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

គ្រឹះស្ថានឥណទានជនបទ ក៏បានចូលរួមអនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយបន្ធូរបន្ថយអត្រាការប្រាក់ និងអនុគ្រោះដល់អតិថិជនដែលរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងសិក្សាលើចំណុចខ្វះខាតនិងតម្រូវការចាំបាច់ផ្នែកច្បាប់និងបទប្បញ្ញត្តិនានា ដើម្បីពង្រឹងការត្រួតពិនិត្យគ្រឹះស្ថានឱ្យស្របតាមការរីកចម្រើននៃទំហំនិងវិសាលភាពប្រតិបត្តិការ។

## ៦- អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន

ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី (CBC) ដែលជាអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានទ្រព្យសកម្មសរុបប្រមាណ ៩០,៧ ប៊ីលានរៀល (២២ លានដុល្លារអាមេរិក) និងមានសមាជិកចំនួន ១៨៤ គ្រឹះស្ថាន។ គ្រឹះស្ថានជាសមាជិកបានបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានចំនួន ៤,១ លានគណនី (ប្រមាណ ២២៣,៩ ទ្រីលានរៀល ស្មើនឹង ៥៤,៣ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះ៖ i/-ឯកត្តបុគ្គលមានចំនួន ៤,១ លានគណនី ជាមួយអតិថិជនសរុបចំនួន ៥,៤ លាននាក់ (មាន ៥៤% ជាស្ត្រី) និង ii/-ក្រុមហ៊ុនមាន ៥.៤០៨ គណនី ជាមួយនឹងចំនួនអតិថិជន ១.៦៣៩ ក្រុមហ៊ុន។ គ្រឹះស្ថានជាសមាជិកបានបញ្ចូលទិន្នន័យមូលប្បទានប័ត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីសរុបមានចំនួន ៦៨៩ ប្រតិបត្តិការ។

គ្រឹះស្ថានជាសមាជិកបានចូលប្រើប្រាស់របាយការណ៍ឥណទាន សរុបមានចំនួន ៥.៩៦០.០៧៤ ប្រតិបត្តិការ ក្នុងនោះ ធនាគារ ២.៦៧៨.០៥៧ ប្រតិបត្តិការ ស្មើនឹង ៤៤,៩% គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៣.១២៤.៨០៤ ប្រតិបត្តិការ ស្មើនឹង ៥២,៤% គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ១៤០.១៣៨ ប្រតិបត្តិការ ស្មើនឹង ២,៤% និងគ្រឹះស្ថានឥណទានជនបទ ១៧.០៧៥ ប្រតិបត្តិការ ស្មើនឹង ០,៣%។

**ក្រាហ្វ ៧៣ ៖ ចំនួនប្រតិបត្តិការប្រើប្រាស់របាយការណ៍ឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ជាមួយនេះ ធនាគារជាតិនៃកម្ពុជាបន្តតាមដាននិងត្រួតពិនិត្យវឌ្ឍនភាពនៃប្រតិបត្តិការរបស់ CBC និងបន្តតាមដាននិងត្រួតពិនិត្យលើទិន្នន័យរបស់គ្រឹះស្ថានជាសមាជិក ដែលរាយការណ៍ប្រចាំគ្រាដោយអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានពាក់ព័ន្ធនឹងការអនុវត្តស្របតាមខ្លឹមសារបទប្បញ្ញត្តិជាធរមានក្នុងការធានាគុណភាពទិន្នន័យ និងនិរន្តរភាពនៃដំណើរការប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៅកម្ពុជា។

## ៧- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងបន្តតាមដានជាប្រចាំចំពោះស្ថានភាពទូទៅ ភាពធន់ និងស្ថិរភាពនៃប្រព័ន្ធទាំងមូល តាមរយៈការអនុវត្តក្របខ័ណ្ឌនៃការត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត ដោយដាក់ចេញនូវវិធីសាស្ត្រត្រួតពិនិត្យនិងវាយតម្លៃ (Supervisory Review and Evaluation Process, SREP) ការធ្វើស្រ្តេសតេស្តនិងស្រ្តេសតេស្តត្រឡប់ (Reverse Stress Test) លើភាពគ្រប់គ្រាន់នៃដើមទុននិងសន្ទនីយភាព តាមដានគុណភាពឥណទានជាពិសេសឥណទានដែលបានរៀបចំឡើងវិញ រួមទាំងការអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិនានារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បានចុះត្រួតពិនិត្យដល់ទីកន្លែងលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយផ្តោតលើគុណភាពឥណទានរៀបចំឡើងវិញ អភិបាលកិច្ច សុខុមាលភាព និងការអនុវត្តស្របតាមច្បាប់បទប្បញ្ញត្តិជាធរមាន។

ជាលទ្ធផលបានបង្ហាញថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រក្សាបាននូវភាពធន់នៃសន្ទនីយភាព និងដើមទុន និងការបញ្ចេញឥណទានប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់។ ចំពោះការអនុវត្តច្បាប់និងបទប្បញ្ញត្តិ របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុភាគច្រើនអនុវត្តបានល្អប្រសើរ។ ដោយឡែកធនាគារជាតិនៃកម្ពុជាក៏បានចាត់វិធានការនានា ដោយផ្តល់ជាអនុសាសន៍កែតម្រូវ និងការពិន័យជាដើម ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមិនបានអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិពេញលេញ។

- **ការងាររៀបចំបទប្បញ្ញត្តិ**

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តបទប្បញ្ញត្តិនិងការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ សេចក្តីណែនាំចំនួន ២ ត្រូវបានចេញផ្សាយ៖ i/-ការអនុវត្តប្រកាសស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាននិងសំវិធានធនលើអ៊ីមភែរមិន[៧១] និង ii/-ការប្រើប្រាស់វិធីសាស្ត្រត្រួតពិនិត្យនិងវាយតម្លៃ (SREP)[៧២] ។ ទន្ទឹមនេះ សេចក្តីព្រាងប្រកាសចំនួន ៥ ទៀត ត្រូវបានរៀបចំឡើង ពាក់ព័ន្ធនឹងក្របខ័ណ្ឌសាធនភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើស្របតាមស្តង់ដារបាសែល III ដែលជាផ្នែកមួយនៃការអនុវត្តផែនការត្រួតពិនិត្យផ្អែកលើហានិភ័យ ក្នុងនោះរួមមាន៖ ប្រកាសទាក់ទងនឹងអនុបាតភាពគ្រប់គ្រាន់នៃដើមទុន ដើមទុនបទប្បញ្ញត្តិ ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ និងហានិភ័យទីផ្សារ ព្រមទាំងសេចក្តីណែនាំស្តីពី ការវាយតម្លៃទ្រព្យធានាក្នុងគោលបំណងវាយតម្លៃលើអ៊ីមភែរមិន។

---

[៧១] នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២២

[៧២] នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២

## V- បរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន

### ១- បរិយាបន្នហិរញ្ញវត្ថុ

ក្រាហ្វ ៧៤ ៖ ចំនួនគណនីប្រាក់បញ្ញើ និងគណនីឥណទាន របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

(គិតជាលានគណនី, ឆ្នាំ២០១៨ - ឆ្នាំ២០២២ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

បរិយាបន្នហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាហិរញ្ញវត្ថុផ្លូវការដល់ប្រជាជន និងអាជីវកម្ម ព្រមទាំងបានរួមចំណែកកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ចរបស់ប្រទេស។ ស្របតាមយុទ្ធសាស្ត្រជាតិ ស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈ i/-ការគាំទ្រការពង្រីកបណ្តាញប្រតិបត្តិការនិងការបង្កើតផលិតផលហិរញ្ញវត្ថុថ្មីៗ ស្របតាមតម្រូវការទីផ្សារ ii/-ការលើកកម្ពស់ការអប់រំផ្នែកហិរញ្ញវត្ថុលើគ្រប់រូបភាព iii/-ការពង្រឹងការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយតម្លាភាព និង iv/-ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុអំណោយផល ដើម្បីឱ្យប្រជាជនទូទៅមានលទ្ធភាពក្នុងការទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការទាន់ពេលវេលា មានតម្លៃសមរម្យ និងមានកិច្ចការពារតាមផ្លូវច្បាប់។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តពង្រីកវិសាលភាពរបស់ខ្លួនដោយបានបង្កើនទីស្នាក់ការកណ្តាល និងសាខាដល់ ២.៦៥៧ ទីតាំង រាជធានី-ខេត្ត និងម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) ដល់ចំនួន ៤.២១៩ ដែលរួមចំណែកផ្តល់លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការដល់ប្រជាជនកាន់តែច្រើន។ ចំនួនគណនីប្រាក់បញ្ញើអតិថិជនបានកើនដល់ ១៤,៣ លានគណនី (កើន ១៧,៧%) និងគណនីឥណទានអតិថិជនកើនដល់ ៣,៧ លានគណនី (កើន ១១,៥%)។ តាមរយៈរបាយការណ៍របស់មូលនិធិ UNCDF ឆ្នាំ២០២១ បានបង្ហាញថាបរិយាប័ន្នហិរញ្ញវត្ថុកម្ពុជានៅមានកម្រិតមធ្យម ដោយ ៦៧% នៃប្រជាជនពេញវ័យកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ខណៈដែលអត្រាប្រជាជនកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុក្រៅផ្លូវការមានប្រមាណ ៣% ថយចុះពី ១២% ធៀបនឹងឆ្នាំ២០១៧។ ទន្ទឹមនេះ តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ និងការផ្តល់សេវាហិរញ្ញវត្ថុឌីជីថលកាន់តែសម្បូរបែបពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អតិថិជនបានប្រើប្រាស់ការទូទាត់តាមអេឡិចត្រូនិកកាន់តែច្រើនឡើង ដោយទំហំប្រតិបត្តិការរបស់សេវាទូទាត់សងប្រាក់បានកើនឡើងដល់ជាង ១០ ដងនៃផលិតផលក្នុងស្រុកសរុប ជាមួយនឹងអត្រាកំណើន ៣៤% ធៀបនឹងឆ្នាំ២០២១ ស្របពេលដែលចំនួនគណនីអ៊ីវ៉ាឡេតបានកើនដល់ ១៦,៦ លានគណនី ស្របពេលដែលអតិថិជនដែលបានចុះឈ្មោះប្រើប្រាស់គណនីបាគងមានចំនួន ៥១០.៥១២ គណនី[៣]។

---

[៣] គិតត្រឹម១១ខែ ឆ្នាំ២០២២។

## ២- ការអប់រំផ្នែកហិរញ្ញវត្ថុ

**- ការងារបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ**

ដោយមានកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ Credit Union Foundation Australia (CUFA) ចំណេះដឹងផ្នែកហិរញ្ញវត្ថុត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ ក្នុងដំណាក់កាលទី២ និងត្រូវបានបង្រៀនសាកល្បងសម្រាប់ថ្នាក់ទី៤និងទី៧ រយៈពេល ៦ សប្តាហ៍ នៅសាលាបឋមសិក្សា ៣ និងអនុវិទ្យាល័យ ៣ ក្នុងខេត្តកំពត កំពង់ចាម និងសៀមរាប។ ទន្ទឹមនេះ ធាតុចូលនិងមតិយោបល់នានាត្រូវបានប្រមូលបន្ថែមដើម្បីកែសម្រួលខ្លឹមសារមេរៀន រូបភាព និងទម្រង់នៃការសរសេរនៅក្នុងសៀវភៅសិស្សនិងសៀវភៅគ្រូ ផងដែរ។

**- ការងារលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនភាពស្ត្រី**

ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនភាពស្ត្រី បាននិងកំពុងបន្តក្រោមកិច្ចសហការជាមួយក្រសួងកិច្ចការនារី តាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលដែលជាស្ត្រីនៅតាមសាលារៀន និងសហគមន៍ ដើម្បីអាចចែករំលែកចំណេះដឹងផ្នែកហិរញ្ញវត្ថុបន្តនៅក្នុងមូលដ្ឋានរបស់ខ្លួន លើប្រធានបទ៖ ការគ្រប់គ្រងហិរញ្ញវត្ថុ ការប្រើប្រាស់សេវាហិរញ្ញវត្ថុ សេវាទូទាត់ឌីជីថល និងកិច្ចការពារអតិថិជន។ លើសពីនេះ វេទិកាជជែកពិភាក្សាតាមប្រព័ន្ធអនឡាញ ចំនួន ២ លើក ត្រូវបានរៀបចំឡើងដោយក្រសួងកិច្ចការនារី អំពីចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងផ្នែកឌីជីថលហិរញ្ញវត្ថុសម្រាប់បង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ច និងអភិវឌ្ឍសហគ្រិនភាពដល់ស្ត្រីផងដែរ។

**- ការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ**

សម្រាប់ឆ្នាំ២០២២នេះ សិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ត្រូវបានប្រារព្ធឡើង ១៣លើក ក្នុងនោះមានថ្នាក់ខេត្ត ៣លើក និងថ្នាក់ក្រុង/ស្រុក ១០លើក ក្នុងគោលដៅបន្តពង្រឹងចំណេះដឹងពាក់ព័ន្ធនឹងវិស័យធនាគារនិងហិរញ្ញវត្ថុ ជូនដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុផ្លូវការ ល្បិចឆបោករបស់ជនអគតិមួយចំនួន សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ និងធានាឱ្យមានកិច្ចគាំពារអតិថិជនជាដើម។

អង្គការ Good Return បានសហការដាក់ឱ្យដំណើរការយុទ្ធនាការដំណាក់កាលទី២ "តោះ! និយាយពីលុយ ៖ តក់ៗពេញបំពង់" កាលពីខែធ្នូ ឆ្នាំ២០២១ កន្លងទៅ។ យុទ្ធនាការនេះមានគោលដៅពង្រឹងការយល់ដឹងរបស់ប្រជាជនពាក់ព័ន្ធនឹងបញ្ហាហិរញ្ញវត្ថុ ដូចជា ការថ្លឹងថ្លែងអំពីជម្រើសផលិតផលនិងសេវាហិរញ្ញវត្ថុ ការយល់ដឹងពីសិទ្ធិនិងកាតព្វកិច្ច និងការធ្វើសេចក្តីសម្រេចរួមគ្នារវាងបុរសនិងស្ត្រីនៅក្នុងគ្រួសារ។ យុទ្ធនាការនេះធ្វើឡើងតាមវិធីសាស្ត្រ ៣ សំខាន់ៗ៖ i/-ការផ្សព្វផ្សាយតាមបណ្តាញសង្គមនូវខ្សែវីដេអូអប់រំខ្លីចំនួន ៤វគ្គ រួមមាន វគ្គទី១ "ក្តីសុបិនសម្រាប់អនាគត" វគ្គទី២ "និយាយចេញមក" វគ្គទី៣ "អនុស្សាវរីយ៍កាលវ័យកុមារ" និងវគ្គទី៤ "ព្យុះជីវិត" ii/-ការផ្សព្វផ្សាយតាមកម្មវិធីវិទ្យុដោយមានការចូលរួមពីវាគ្មិន ដែលមានបទពិសោធន៍ផ្នែកអប់រំហិរញ្ញវត្ថុ និងការចូលរួមរបស់ប្រិយមិត្តអ្នកស្តាប់ និង iii/-កម្មវិធីបណ្តុះបណ្តាលផ្ទាល់ជាមួយកម្មការិនីរោងចក្រ ជាពិសេសនៅក្នុងរាជធានីភ្នំពេញ។

### ៣- កិច្ចការពារអតិថិជន

យន្តការគ្រប់គ្រងនិងដោះស្រាយបណ្តឹងជូនអតិថិជនដែលប្រើប្រាស់សេវារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានពង្រឹង តាមរយៈលេខទូរស័ព្ទហាត់ឡាញ (Hotline) ចំនួន ២៦ នៅគ្រប់សាខារាជធានី-ខេត្ត ។

នៅក្នុងឆ្នាំនេះ បណ្តឹងនិងការសាកសួរព័ត៌មាន មានចំនួន ៣០៦ ករណី ដែលក្នុងនោះ ២៩៦ ករណីដោះស្រាយរួចរាល់ ២ ករណី កំពុងដោះស្រាយ និង ៨ ករណីស្ថិតក្នុងនីតិវិធីតុលាការ។ បណ្តឹងភាគច្រើនពាក់ព័ន្ធនឹង៖ i/-ការស្នើសុំបង់ផ្តាច់ឥណទានមុនកាលកំណត់ និងដកទ្រព្យធានា ii/- ការស្នើសុំកែប្រែព័ត៌មាន ឬលុបឈ្មោះចេញពីប្រព័ន្ធចែករំលែកព័ត៌មានឥណទាន iii/-ការស្នើសុំការអនុគ្រោះផ្សេងៗ iv/-ការស្នើសុំលើកលែងប្រាក់ពិន័យ v/-ការផ្ទេរប្រាក់ខុសគណនី vi/- ការចេញមូលប្បទានបត្រមិនមានសាច់ប្រាក់គ្រប់គ្រាន់ និង vii/-ការសាកសួរព័ត៌មានផ្សេងៗអំពីការប្រើប្រាស់សេវាហិរញ្ញវត្ថុ ជាដើម។ បណ្តឹងអតិថិជនមួយចំនួនត្រូវបានដោះស្រាយភ្លាមៗ ប៉ុន្តែករណីខ្លះតម្រូវឱ្យមានការសម្របសម្រួលដោះស្រាយច្រើនលើករវាងភាគីអតិថិជននិងគ្រឹះស្ថាន។ លើសពីនេះ ធនាគារជាតិនៃកម្ពុជា បានបន្តពង្រឹងសមត្ថភាពរបស់មន្ត្រីទទួលបន្ទុកហាត់ឡាញ តាមរយៈការរៀបចំវគ្គចែករំលែកចំណេះដឹងស្តីពី វឌ្ឍនភាពនៃវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា និងការរៀបចំ "ឯកសារជំនួយស្មារតីសម្រាប់មន្ត្រីទទួលបន្ទុកហាត់ឡាញ" ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការផ្តល់ចម្លើយ និងដំណោះស្រាយឱ្យបានត្រឹមត្រូវ។

លើសពីនេះ យន្តការនៃការរៀបចំប្រព័ន្ធការពារអ្នកដាក់ប្រាក់បញ្ញើកំពុងត្រូវបានសិក្សា និងរៀបចំក្នុងគោលបំណង៖ i/-ការពារអ្នកដាក់ប្រាក់បញ្ញើ ii/-ពង្រឹងជំនឿទុកចិត្តសាធារណជនមកលើប្រព័ន្ធធនាគារ និង iii/-រួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ។

## VI- ការផ្គត់ផ្គង់សេវាធនាគារកណ្ដាល

### ១- ប្រព័ន្ធទូទាត់សងប្រាក់

ស្របតាមវឌ្ឍនភាពនៃសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យធនាគារ ប្រព័ន្ធទូទាត់សងប្រាក់ដើរតួនាទីយ៉ាងសំខាន់ដើម្បីរក្សាប្រសិទ្ធភាពរបស់ប្រព័ន្ធហិរញ្ញវត្ថុនិងសេដ្ឋកិច្ចទាំងមូល។ ហេដ្ឋារចនាសម្ព័ន្ធទូទាត់ត្រូវបានធ្វើទំនើបកម្មជាបន្តបន្ទាប់ តាមរយៈការធ្វើបច្ចុប្បន្នកម្មលើមុខងារបន្ថែមចាំបាច់មួយចំនួនលើប្រព័ន្ធផាត់ទាត់ជាតិ និងប្រព័ន្ធសេវាទូទាត់រហ័សក្នុងគោលបំណងសម្រួលដល់គ្រឹះស្ថានជាសមាជិក និងអ្នកប្រើប្រាស់។ ស្តង់ដា KHQR កូដ ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ ដើម្បីលើកកម្ពស់ការទូទាត់តាម QR កូដ ប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព កាត់បន្ថយចំណាយប្រតិបត្តិការ និងជំរុញបរិយាបន្នហិរញ្ញវត្ថុ។ ក្នុងគោលដៅធានាបានស្ថិរភាព បង្កើនជំនឿទុកចិត្តពីសាធារណជនលើប្រព័ន្ធទូទាត់ ជំរុញការទូទាត់ជាអេឡិចត្រូនិកក្នុងសេដ្ឋកិច្ច និងពង្រឹងភាពរឹងមាំរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ការត្រួតពិនិត្យលើឯកសារនិងដល់ទីកន្លែងត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃពីស្ថានភាពជាក់ស្តែងរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់ តាមដានពីវឌ្ឍនភាពអាជីវកម្មនិងបញ្ហាប្រឈមនានា និងដាក់ចេញនូវអនុសាសន៍កែតម្រូវដើម្បីទប់ស្កាត់នូវហានិភ័យ។

បច្ចុប្បន្ននេះ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ៣៥ ទទួលបានអាជ្ញាប័ណ្ណ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ២ ទទួលបានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការទូទាត់សងប្រាក់ ដែលមានអតិថិជនចុះឈ្មោះបង្កើតគណនីអ៊ីវ៉ាឡេតសរុប ១៧,៩ លានគណនី។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៥១ បានចេញផ្សាយប័ណ្ណទូទាត់ គ្រឹះស្ថាន ៣៧ ផ្តល់សេវាធនាគារតាមអ៊ីនធឺណេត និងគ្រឹះស្ថាន ៣៣ ផ្តល់សេវាធនាគារចល័ត។ ចំនួនប្រតិបត្តិការរបស់សេវាទូទាត់សងប្រាក់បានកើនឡើងពី ៧០៨ លានប្រតិបត្តិការ ដល់ ១ ប៊ីលានប្រតិបត្តិការ ហើយទំហំប្រាក់ក៏បានកើនឡើងដល់ ២៧២,៥ ប៊ីលានដុល្លារអាមេរិក (កើន ៣៤%) ស្មើនឹងជាង ១០ដង នៃផ.ស.ស។

ទន្ទឹមនេះ ការទូទាត់ឆ្លងដែនជាមួយបណ្តាប្រទេសដទៃទៀតក្នុងតំបន់ក៏ត្រូវបានបន្តជំរុញជាលំដាប់ ដោយបាននិងកំពុងបន្តភ្ជាប់ការទូទាត់ឆ្លងដែនជាមួយធនាគារកណ្តាលឡាវ និងធនាគាររដ្ឋវៀតណាម បន្ទាប់ពីកិច្ចសហការដោគជ័យជាមួយធនាគារកណ្តាលថៃ ដើម្បីសម្រួលការទូទាត់ឆ្លងដែនឱ្យកាន់តែមានភាពងាយស្រួល រហ័ស សុវត្ថិភាព និងជំរុញបរិយាបន្នហិរញ្ញវត្ថុ។

ប្រតិបត្តិការសរុបរបស់ប្រព័ន្ធទូទាត់សងប្រាក់បានកើនពី ១០,៤ លានប្រតិបត្តិការ ដល់ប្រមាណ ២៦,៦ លានប្រតិបត្តិការ ហើយទំហំទឹកប្រាក់ក៏បានកើនឡើងដល់ប្រមាណ ១៧២,៦ ប៊ីលានដុល្លារអាមេរិក (កើន ៣១,៣%) ស្មើនឹងជាង ៦ដងនៃផ.ស.ស។

ប្រព័ន្ធទូទាត់សងប្រាក់ចែកចេញជា ២ គឺ ប្រព័ន្ធទូទាត់តម្លៃធំ និងប្រព័ន្ធទូទាត់រាយ៖

#### ក- ប្រព័ន្ធទូទាត់តម្លៃធំ

- ប្រព័ន្ធធនាគារអនឡាញ (OBS)៖ សមាជិករបស់ប្រព័ន្ធធនាគារអនឡាញ (OBS) មាន ៧៩ ក្នុងនោះមានធនាគារពាណិជ្ជ ៥៥ ធនាគារឯកទេស ២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ១ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ១៥ និងស្ថាប័ន

រដ្ឋ ១ (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)។ ការផ្ទេរប្រាក់តាមប្រព័ន្ធ OBS មាន ៥៤.៦៧១ ប្រតិបត្តិការ ដែលក្នុងនោះការផ្ទេរប្រាក់ក្នុងចំណោមគណនីនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជាមាន ៥៣.៥៨៤ ប្រតិបត្តិការ និងការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្តមាន ១.០៨៧ ប្រតិបត្តិការ។ ការផ្ទេរប្រាក់នៅស្នាក់ការកណ្តាលជាប្រាក់រៀលមាន ៣៣.៥៨៤ ប្រតិបត្តិការ ស្មើនឹង៩១,២ ទ្រីលានរៀល (កើន ១២,៧%) និងជាប្រាក់ដុល្លារអាមេរិកមាន ២០.០០០ ប្រតិបត្តិការ ស្មើនឹង ៥៩,៦ ប៊ីលានដុល្លារអាមេរិក (កើន ៣៨,៩%)។ ចំពោះការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅគណនីសាខារាជធានី-ខេត្តជាប្រាក់រៀលមាន ៥៥៤ ប្រតិបត្តិការ ស្មើនឹង ២,៥ ទ្រីលានរៀល (ថយ -២៥,៧%) ខណៈការផ្ទេរប្រាក់ជាដុល្លារអាមេរិកមាន ៥៣៣ ប្រតិបត្តិការ ស្មើនឹង ៩៨១ លានដុល្លារអាមេរិក (ថយ -៥,៩%)។

**ក្រាហ្វ ៧៥ ៖ ការផ្ទេរប្រាក់រៀលតាមរយៈ OBS**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២)




**ក្រាហ្វ ៧៦ ៖ ការផ្ទេរប្រាក់ដុល្លារអាមេរិកតាមរយៈ OBS**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

- ប្រព័ន្ធទូទាត់តម្លៃធំបាគង (Bakong LVPS)៖ ប្រព័ន្ធនេះកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍ ដើម្បីសម្រួលការទូទាត់ ចំពោះប្រតិបត្តិការទូទាត់សងប្រាក់តម្លៃធំអន្តរធនាគារ ប្រតិបត្តិការទូទាត់សមតុល្យសុទ្ធរបស់ប្រព័ន្ធទូទាត់រាយ និងប្រតិបត្តិការទូទាត់ក្នុងទីផ្សារហិរញ្ញវត្ថុ។

### ខ-ប្រព័ន្ធទូទាត់រាយ

- ប្រព័ន្ធផាត់ទាត់ជាតិ (NCS) ជាប្រព័ន្ធបម្រើដល់ប្រតិបត្តិការទូទាត់មូលប្បទានប័ត្រ និងបញ្ជាផ្ទេរឥណទាន។ នៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា ប្រព័ន្ធផាត់ទាត់ជាតិមានសមាជិកផ្ទាល់ ៥១ និងសមាជិកមិនផ្ទាល់ ១៦ ហើយមានសមាជិកចូលរួមតាមមណ្ឌលដោះដូរមូលប្បទានប័ត្រជារូបវន្តទាំង ៧ រួមមាន ខេត្តសៀមរាបមានសមាជិក ២៧ កំពង់ចាម ១៨ ព្រះសីហនុ ១៩ បាត់ដំបង ២០ បន្ទាយមានជ័យ ៨ ស្វាយរៀង ៧ និងកំពង់ធំ ៦។

- សេវាទូទាត់មូលប្បទានប័ត្រៈ ការទូទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀលមានចំនួន ៣៣,៦ ពាន់សន្លឹក (កើន ៥,៩%) និងទំហំប្រាក់ទូទាត់ ១៩,៨ ទ្រីលានរៀល (កើន ៣,៩%)។ ចំណែកឯការទូទាត់មូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិកមាន ១,១ លានសន្លឹក (កើន ២,៧%) និងទំហំប្រាក់ទូទាត់ ៥៣,៩ ប៊ីលានដុល្លារអាមេរិក (កើន ១៦,១%)។

**ក្រាហ្វ ៧៧ ៖ ចំនួនមូលប្បទានប័ត្រជាប្រាក់រៀល និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២២)




**ក្រាហ្វ ៧៨ ៖ ទំហំទឹកប្រាក់មូលប្បទានប័ត្រជាប្រាក់រៀល និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧៩ ៖ ចំនួនមូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិក និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២២)




**ក្រាហ្វ ៨០ ៖ ទំហំទឹកប្រាក់មូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិក និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

- សេវាទូទាត់បញ្ជាផ្ទេរឥណទាន៖ បញ្ជាផ្ទេរឥណទានដែលជាឧបករណ៍ទូទាត់សងប្រាក់អេឡិចត្រូនិកមានការកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងនោះជាប្រាក់រៀលមាន ២២,៥ ពាន់ប្រតិបត្តិការ (កើន ៩១,៨%) និងទំហំប្រាក់ផ្ទេរមានចំនួន ៤,៦ ទ្រីលានរៀល (ថយ -៧,១%) ស្របពេលដែលប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមាន ៦៧៥,៥ ពាន់ប្រតិបត្តិការ (កើន ២០%) និងទំហំប្រាក់ផ្ទេរ ១២,៣ ប៊ីលានដុល្លារអាមេរិក (កើន ១៨,៤%) ។

**ក្រាហ្វ ៨១ ៖ ចំនួនបញ្ជាផ្ទេរឥណទានជាប្រាក់រៀល និង បម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២២)




**ក្រាហ្វ ៨២ ៖ ទំហំទឹកប្រាក់បញ្ជាផ្ទេរឥណទាន ជាប្រាក់រៀល និង បម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៨៣ ៖ ចំនួនបញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារ អាមេរិក និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២២)




**ក្រាហ្វ ៨៤ ៖ ទំហំទឹកប្រាក់បញ្ជាផ្ទេរឥណទានជាប្រាក់ ដុល្លារអាមេរិក និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

- ប្រព័ន្ធសេវាទូទាត់រហ័ស FAST 2.0៖ ប្រព័ន្ធសេវាទូទាត់រហ័សបានដំណើរការទូទាត់លើប្រតិបត្តិការផ្ទេរមូលនិធិជាប្រាក់រៀលតម្លៃតូចដែលមានទំហំប្រាក់អតិបរមា ៨០ លានរៀលក្នុងមួយប្រតិបត្តិការ។ ប្រព័ន្ធសេវាទូទាត់រហ័សមានសមាជិកសរុប ២៥ គ្រឹះស្ថាន ក្នុងនោះគ្រឹះស្ថានធនាគារ ២១ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៤។ ប្រព័ន្ធសេវាទូទាត់រហ័សបានទូទាត់ប្រតិបត្តិការផ្ទេរមូលនិធិ ២២,៧ ពាន់ប្រតិបត្តិការ បានថយចុះ -៦៣,៦% និងទំហំប្រាក់ទូទាត់ ៧១,៨ ប៊ីលានរៀល បានថយចុះ -៤៩,៩% ដោយសារធនាគារជាតិនៃកម្ពុជាបាននិងកំពុងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធឱ្យមានភាពប្រសើរជាងមុន។

**ក្រាហ្វ ៨៥ ៖ ចំនួនប្រតិបត្តិការសេវាទូទាត់រហ័សជារៀលនិងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២)




**ក្រាហ្វ ៨៦ ៖ ទំហំទឹកប្រាក់សេវាទូទាត់រហ័សជារៀលនិងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៨៧ ៖ ចំនួនប្រតិបត្តិការបញ្ជូនមូលនិធិត្រឡប់វិញនិងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២)




**ក្រាហ្វ ៨៨ ៖ ចំនួនប្រាក់បញ្ជូនមូលនិធិត្រឡប់វិញនិងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

- ប្រព័ន្ធខេមបូឌានស៊ែរស្វីច (CSS)៖ ប្រព័ន្ធ CSS មានសមាជិក ៥៦ ក្នុងនោះសមាជិកផ្ទាល់ជាធនាគារពាណិជ្ជ ៤៨ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៥ និងសមាជិកមិនផ្ទាល់ជាធនាគារពាណិជ្ជមានចំនួន ៣។ ប្រព័ន្ធ CSS បានបម្រើលើប្រតិបត្តិការទូទាត់ជាប្រាក់រៀលសរុបចំនួន ៤២២,៤ ពាន់ប្រតិបត្តិការ (កើន ១០,១%) និងទំហំប្រាក់ទូទាត់ ៨៦,២ ប៊ីលានរៀល (កើន ១៩,៤%)។ ទន្ទឹមនេះ ប្រតិបត្តិការទូទាត់ជាប្រាក់ដុល្លារអាមេរិកមានចំនួន ៨៤,៨ ពាន់ប្រតិបត្តិការ (ថយ -២%) និងទំហំប្រាក់ទូទាត់ ១១,៩ លានដុល្លារអាមេរិក (កើន ១៤%)។

**ក្រាហ្វ ៨៩ ៖ ចំនួនប្រតិបត្តិការប្រព័ន្ធខេមបូឌានស៊េរស្វីច ជារៀលនិងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២)




**ក្រាហ្វ ៩០ ៖ ទំហំទឹកប្រាក់ប្រព័ន្ធខេមបូឌានស៊េរស្វីចជារៀល និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៩១ ៖ ចំនួនប្រតិបត្តិការប្រព័ន្ធខេមបូឌានស៊េរស្វីច ជាដុល្លារអាមេរិកនិងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២)




**ក្រាហ្វ ៩២ ៖ ទំហំទឹកប្រាក់ប្រព័ន្ធខេមបូឌានស៊េរស្វីច**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

- ប្រព័ន្ធរីថែលផេ (Retail Pay)៖ ប្រព័ន្ធរីថែលផេ មានសមាជិកសរុប ២៤ ជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការកាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ដែលមានសមាជិកកំពុងដំណើរការជាផ្លូវការ ១៦។ ប្រតិបត្តិការទូទាត់តាមប្រព័ន្ធរីថែលផេ បានដំណើរការទូទាត់ចំនួន ២៥១ថ្ងៃ ជាប្រាក់រៀលមានចំនួន ២៦,៦ ពាន់ប្រតិបត្តិការ (ថយ -១៧,២%) ទំហំប្រាក់ទូទាត់ ៤៦៦,៩ ប៊ីលានរៀល (កើន ៣០,៨%)។ ទន្ទឹមនេះ ប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៨៦,៥ ពាន់ប្រតិបត្តិការ (ថយ -២៤,៣%) ទំហំប្រាក់ទូទាត់ ២៣៨,២ លានដុល្លារអាមេរិក (កើន ២៨%) ។

**ក្រាហ្វ ៩៣ ៖ ចំនួនប្រតិបត្តិការប្រព័ន្ធរីធែលផេជារៀលនិង បម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០២០ - ឆ្នាំ២០២២)




**ក្រាហ្វ ៩៤ ៖ ទំហំទឹកប្រាក់ប្រព័ន្ធរីធែលផេជារៀលនិង បម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០២០ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៩៥ ៖ ចំនួនប្រតិបត្តិការប្រព័ន្ធរីធែលផេ ជាដុល្លារអាមេរិកនិងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០២០ - ឆ្នាំ២០២២)




**ក្រាហ្វ ៩៦ ៖ ទំហំទឹកប្រាក់ប្រព័ន្ធរីធែលផេ ជាដុល្លារអាមេរិកនិងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០២០ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

- ប្រព័ន្ធបាគង៖ ប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់កន្លោង មានសមាជិកសរុបចំនួន ៦៩ ក្នុងនោះមានគ្រឹះស្ថានចំនួន ៥៦ បានដាក់ឱ្យដំណើរការជាផ្លូវការ និងមានអតិថិជនចុះឈ្មោះប្រើប្រាស់តាមរយៈកម្មវិធីបាគងមានចំនួន ០,៥២ លានគណនី។ ក្នុងឆ្នាំ២០២២ ប្រតិបត្តិការតាមរយៈប្រព័ន្ធបាគងមានចំនួន ២៦,១ លានប្រតិបត្តិការ (កើន ២,២ ដង) និងទំហំប្រាក់ទូទាត់ជាប្រាក់រៀលចំនួន ១២,៨ ទ្រីលានរៀល (កើន ៤,១ ដង) និងទំហំប្រាក់ទូទាត់ជាប្រាក់ដុល្លារអាមេរិកចំនួន ១២,២ ប៊ីលានដុល្លារអាមេរិក (កើន ៣,២ ដង) ធៀបនឹងឆ្នាំ២០២១។

ប្រព័ន្ធបាគងកំពុងតភ្ជាប់ជាមួយប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលក្នុងការប្រើប្រាស់ថ្នាល CamDX ក្រោមអនុស្សរណៈយោគយល់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងប្រើប្រាស់តំណភ្ជាប់សម្រាប់ស្វែងរកមើលព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩ របស់សាមីបុគ្គលតាមរយៈប្រព័ន្ធបាគង ដែលជាកិច្ចសហប្រតិបត្តិការជាមួយគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) ផងដែរ។

ក្រាហ្វ ៩៧ ៖ ប្រតិបត្តិការនៃប្រព័ន្ធបាគង ជាប្រាក់រៀល
(ឆ្នាំ២០១៩ - ឆ្នាំ២០២២)




ក្រាហ្វ ៩៨ ៖ ប្រតិបត្តិការនៃប្រព័ន្ធបាគង ជាប្រាក់ដុល្លារអាមេរិក
(ឆ្នាំ២០១៩ - ឆ្នាំ២០២២)




ប្រភព៖ធនាគារជាតិនៃកម្ពុជា

## ២- សេវាគ្រប់គ្រងគណនី

### ក. ចំនួនគណនី

ធនាគារជាតិនៃកម្ពុជាបានគ្រប់គ្រងគណនីសរុបចំនួន ២.១៤១ គណនី ដែលក្នុងនោះមាន ស្ថាប័នរដ្ឋ ៩៨៦ គណនី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ១.១១៥ គណនី និងអង្គភាពផ្សេងៗ ៤០ គណនី (រួមមាន ធនាគារកណ្តាលបរទេស គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិសាធារណៈ និងមន្ទីរសាការី)។ បើធៀបនឹងឆ្នាំមុន ចំនួនគណនីបានកើនឡើង ៧០ គណនី (កើន ៣,៤%) ក្នុងនោះ៖ i/-ស្ថាប័នរដ្ឋ ៩ គណនី សម្រាប់អនុវត្តគម្រោងជាមួយដៃគូអភិវឌ្ឍន៍ និងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុក្នុងការទទួលថវិកាផ្ទាល់ពីអគ្គនាយកដ្ឋានរតនាគារជាតិ និង ii/-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៦១ គណនី។

ក្រាហ្វ ៩៩ ៖ ចំនួនគណនី
(ឆ្នាំ២០១៨- ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ខ. សេវាទទួលប្រាក់បញ្ញើ

ប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថាប័នរដ្ឋ និងអង្គភាពផ្សេងៗនៅធនាគារជាតិនៃកម្ពុជា បានថយចុះធៀបនឹងឆ្នាំ២០២១ ក្នុងនោះប្រាក់បញ្ញើជាប្រាក់រៀលបានកើនឡើងចំនួន ០,៣ ទ្រីលានរៀល (២,៤%) ស្របពេលដែលបញ្ញើជាប្រាក់ដុល្លារអាមេរិកបានថយចុះ ៩០០,៣ លានដុល្លារអាមេរិក (-៧,៥%)។

**ក្រាហ្វ ១០០ ៖ ប្រាក់បញ្ញើជាដុល្លារអាមេរិកនៅធនាគារជាតិនៃកម្ពុជា**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២)




**ក្រាហ្វ ១០១ ៖ ប្រាក់បញ្ញើជារៀលនៅធនាគារជាតិនៃកម្ពុជា**
(ឆ្នាំ២០១៨ - ឆ្នាំ២០២២)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ៣- ការគ្រប់គ្រងចរាចរណ៍ធនបត្រ

### ក. ប្រតិបត្តិការសាច់ប្រាក់របស់បេឡា

ការទទួលនិងការបើកប្រាក់រៀលមានចំនួន ១៥,៧ ទ្រីលានរៀល (កើន ១៨,១%) និង ១៤,៣ ទ្រីលានរៀល (កើន ៤,៦%) រៀងគ្នា។ ចំណែកឯ ការទទួលនិងការបើកប្រាក់ដុល្លារអាមេរិកមានចំនួន ១៥,៧ ប៊ីលានដុល្លារអាមេរិក (កើន ៣១,៣%) និង ៦,១ ប៊ីលានដុល្លារអាមេរិក (កើន ១%) រៀងគ្នា។

**ក្រាហ្វ ១០២ ៖ ការទទួលនិងបើកប្រាក់រៀល**
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៨ - ឆ្នាំ២០២២)




**ក្រាហ្វ ១០៣ ៖ ការទទួលនិងបើកប្រាក់ដុល្លារអាមេរិក**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៨ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ. ការខារគ្រប់គ្រងសាច់ប្រាក់

ការផ្គត់ផ្គង់ក្រដាសប្រាក់ថ្មីគ្រប់ប្រភេទ និងការប្រមូលក្រដាសប្រាក់ចាស់ ទក់ រហែក ត្រូវបាន អនុវត្តជាប្រចាំ ស្របពេលដែលការពង្រឹងសោភ័ណ-ភាពនិងគុណភាពក្រដាសប្រាក់ត្រូវបានបន្ត យកចិត្តទុកដាក់ដើម្បីទប់ស្កាត់ការក្លែងបន្លំក្រដាស ប្រាក់ ជាពិសេសដើម្បីរួមចំណែកលើកកម្ពស់ការ ប្រើប្រាស់ប្រាក់រៀល។

ការផ្គត់ផ្គង់ប្រាក់រៀលទៅឱ្យសាខា ធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តបានថយចុះ -១១,៩% ខណៈដែលការដឹកជញ្ជូនប្រាក់រៀល ចាស់និងលើសពីតម្រូវការមកស្នាក់ការកណ្តាល វិញបានកើនឡើង ៣១,៩%។ ចំណែកឯការផ្គត់ផ្គង់ ប្រាក់ដុល្លារអាមេរិកទៅឱ្យសាខាធនាគារជាតិនៃ កម្ពុជារាជធានី-ខេត្តបានថយចុះ -៣៨% ខណៈដែល ការដឹកជញ្ជូនប្រាក់ដុល្លារអាមេរិកមកស្នាក់ការ កណ្តាល វិញបានកើនឡើង ៣២,៣% ធៀបនឹង ឆ្នាំ២០២១។

**ក្រាហ្វ ១០៤៖ ប្រាក់រៀលដឹកទៅ-មកសាខា ធនាគារជាតិនៃកម្ពុជា**

(គិតជាប៊ីលានរៀល, ឆ្នាំ២០១៨ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១០៥៖ ប្រាក់ដុល្លារអាមេរិកដឹកទៅមកសាខា ធនាគារជាតិនៃកម្ពុជា**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៨ - ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

រាជរដ្ឋាភិបាល បានអនុញ្ញាតឱ្យធនាគារជាតិ នៃកម្ពុជាចេញផ្សាយធនប័ត្រប្រភេទ ២.០០០រៀល និង ២០០រៀល គំរូថ្មី ដើម្បីដាក់ឱ្យចរាចរ និងប្រើប្រាស់ទូទាំងព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២។

ធនាគារជាតិនៃកម្ពុជាបានសហការជាមួយធនាគារកណ្តាលអាមេរិក និងទីភ្នាក់ងារ US Secret Service រៀបចំវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ ស្តីពី "ការពិនិត្យវិនិច្ឆ័យលើក្រដាស ប្រាក់ដុល្លារអាមេរិកក្លែងក្លាយ" កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២។

## គ. ការផ្សព្វផ្សាយពីសារៈសំខាន់នៃប្រាក់រៀល

ការយល់ដឹងរបស់សាធារណជន អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀលត្រូវបានបន្ត លើកកម្ពស់ឱ្យកាន់តែទូលំទូលាយជាមួយកម្មវិធីផ្សព្វផ្សាយស្តីពី ប្រាក់រៀល ដែលត្រូវបានរៀបចំឡើង នៅរាជធានីភ្នំពេញ និងខេត្តចំនួន ៤ រួមមានខេត្តកំពត កំពង់ធំ បាត់ដំបង និងកំពង់ចាម ដោយមាន ការចូលរួមពីមន្ត្រីរាជការ តំណាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សិស្សានុសិស្ស និងសាធារណជន ទូទៅ។ កម្មវិធីផ្សព្វផ្សាយនេះ បានទាក់ទាញសាធារណជនយ៉ាងច្រើនសន្ធឹកសន្ធាប់ ដោយចំនួន អ្នកចូលរួមសរុបមានរហូតដល់ប្រមាណជាង ៥ ពាន់នាក់ និងអ្នកទស្សនាការផ្សាយផ្ទាល់លើទំព័រ ហ្វេសប៊ុកផ្លូវការរបស់ធនាគារជាតិនៃកម្ពុជាមានប្រមាណជាង ៤ ម៉ឺននាក់។ កម្មវិធីផ្សព្វផ្សាយនេះ

ផ្តោតលើសកម្មភាពសំខាន់ៗ ដូចជាៈ ការយកក្រដាសប្រាក់រៀលចាស់ ទក់ ឬ រហែក ប្តូរយកក្រដាសប្រាក់រៀលថ្មីដោយឥតគិតថ្លៃ ការតាំងពិព័រណ៍ស្តីពីប្រព័ន្ធរូបិយវត្ថុកម្ពុជាតាំងពីសតវត្សរ៍ទី១នៃអាណាចក្រហ្វូណនរហូតដល់បច្ចុប្បន្ន ការតាំងបង្ហាញប្រព័ន្ធទូទាត់បាគង និងការផ្សព្វផ្សាយផលិតផលនិងសេវាហិរញ្ញវត្ថុជាប្រាក់រៀលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ក្នុងអំឡុងពេលផ្សព្វផ្សាយនោះ សាធារណជនក៏បានបើកគណនីបាគង និងគណនីតាមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនានា ព្រមទាំងទទួលបានសារអប់រំបណ្តុះគំនិតឱ្យកាន់តែស្រលាញ់និងប្រើប្រាស់ប្រាក់រៀលថែមទៀត។

## VII- ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) អនុវត្តមុខងារ-ភារកិច្ចជាប្រចាំដូចជាការធានាការអនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ ការបញ្ជូនរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុទៅអាជ្ញាធរអនុវត្តច្បាប់ កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ ព្រមទាំងការបណ្តុះបណ្តាលនិងការផ្សព្វផ្សាយ។ ទន្ទឹមនេះ ស.ហ.ក. ក៏មានតួនាទីចូលរួមនិងសម្របសម្រួលការអនុវត្តផែនការសកម្មភាពរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF)។

### ១- ការពង្រឹងក្របខ័ណ្ឌនិងការអនុវត្តច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ក្នុងឆ្នាំ២០២២នេះ ស.ហ.ក. បានចេញសេចក្តីណែនាំចំនួន ៣ រួមមាន សេចក្តីណែនាំស្តីពីការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់បុគ្គលរាយការណ៍ សេចក្តីណែនាំស្តីពីទំនាក់ទំនងធនាគារឆ្លើយឆ្លង និងទំនាក់ទំនងប្រហាក់ប្រហែល និងសេចក្តីណែនាំស្តីពីការផ្ទេរប្រាក់និងការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ សេចក្តីណែនាំទាំងនេះបានតម្រូវឱ្យបុគ្គលរាយការណ៍បង្កើតគោលនយោបាយនិងនីតិវិធី ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ពេលផ្តល់សេវាកម្មផ្ទេរប្រាក់ និងបង្កើតទំនាក់ទំនងធនាគារឆ្លើយឆ្លង ដើម្បីចូលរួមប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

ស.ហ.ក. បានចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជ ៨ ក្រុមហ៊ុនអចលនទ្រព្យ ៦ ក្រុមហ៊ុនផ្តល់សេវាទូទាត់សងប្រាក់ ១ ក្រុមហ៊ុនធានារ៉ាប់រង ២ និងកាស៊ីណូ ៤ ព្រមទាំងបានផ្តល់អនុសាសន៍ជូនគ្រឹះស្ថានទាំងនេះដើម្បីបំពេញបន្ថែមចំណុចខ្វះខាតនៃការងារអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ទន្ទឹមនេះ ស.ហ.ក. ក៏បានពង្រឹងការតាមដានវឌ្ឍនភាពនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិ ដោយផ្អែកលើរបាយការណ៍ប្រចាំគ្រាតាមរយៈការសិក្សានិងវាយតម្លៃលទ្ធផលនៃការវាយតម្លៃហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងលទ្ធផលនៃការងារត្រួតពិនិត្យផ្ទៃក្នុងនិងសវនកម្មផ្ទៃក្នុង របស់បុគ្គលរាយការណ៍ជាដើម។

## ២- ការងារវិភាគ និងបញ្ជូនរបាយការណ៍

ស.ហ.ក. បានបន្តតាមដានការអនុវត្តកាតព្វកិច្ចរាយការណ៍ប្រតិបត្តិការពិបុគ្គលរាយការណ៍ស្របតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ក្នុងឆ្នាំ២០២២ របាយការណ៍ប្រតិបត្តិការសាច់ប្រាក់ដែល ស.ហ.ក. ទទួលបានមានការកើនឡើងប្រមាណ ១៩,៥% និងរបាយការណ៍ប្រតិបត្តិការសង្ស័យមានការថយចុះប្រមាណ -២,៥%។ ទន្ទឹមនេះ ស.ហ.ក. បានរៀបចំកិច្ចប្រជុំជាច្រើនលើកជាមួយបុគ្គលរាយការណ៍ចំនួន ២៤ គ្រឹះស្ថាន រួមមាន៖ គ្រឹះស្ថាន ធនាគារ ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៩ កាស៊ីណូ ១ ក្រុមហ៊ុនធានារ៉ាប់រង ៤ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ២ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ៤ ដើម្បីពិនិត្យនិងពិភាក្សាដើម្បីលើកកម្ពស់ប្រសិទ្ធភាពនិងគុណភាពនៃការរាយការណ៍ប្រតិបត្តិការ ដែលជាកាតព្វកិច្ចគន្លឹះមួយនៃការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

## ៣- កិច្ចសហប្រតិបត្តិការរបស់ ស.ហ.ក.

### ៣.១ កិច្ចសហប្រតិបត្តិការក្នុងស្រុករបស់ ស.ហ.ក.

ស.ហ.ក. បានចុះអនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មជាមួយ i/-អគ្គិសនីកម្ពុជា ii/-ក្រសួងបរិស្ថាន និង iii/-កងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងគោលបំណងពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការក្នុងស្រុក ឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។ ជាសរុប ស.ហ.ក. មានអនុស្សរណៈយោគយល់ជាមួយក្រសួង-ស្ថាប័នក្នុងស្រុកសរុប ២១ និងកំពុងដំណើរការពិភាក្សាជាបន្តបន្ទាប់ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។

ក្នុងនាមជាលេខាធិការដ្ឋាន ស.ហ.ក. បានចូលរួមសម្របសម្រួលកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ.) ចំនួន ២លើក។ កិច្ចប្រជុំទាំង ២ លើកនេះ បានពិនិត្យនិងពិភាក្សាលើលទ្ធផលការងារដែលកម្ពុជាសម្រេចបាន ចំពោះការអនុវត្តលើផែនការសកម្មភាពរបស់ក្រុមការងារត្រួតពិនិត្យរួមនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (ICRG-JG) និងវឌ្ឍនភាពការងារនិងសមិទ្ធផលរបស់ គ.ស.ហ.។

ទន្ទឹមនេះ ស.ហ.ក. បានសម្របសម្រួលរៀបចំកិច្ចប្រជុំអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួមនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (អ.អ.ផ.) ចំនួន ៥ លើក ដែលមានការចូលរួមពីក្រសួង-ស្ថាប័ន ជាសមាជិកចំនួន ២៧។ កិច្ចប្រជុំទាំង ៥ លើកនេះ បានពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ វឌ្ឍនភាពរបស់ប្រទេសកម្ពុជាលើការអនុវត្តតាមផែនការសកម្មភាពរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) និងបញ្ហាប្រឈមនានាក្នុងការអនុវត្តផែនការសកម្មភាពការងារនេះ ដើម្បីឱ្យកម្ពុជាចេញពីបញ្ជីប្រផេះរបស់ FATF បានឆាប់រហ័ស។

ស.ហ.ក. ក៏បានដឹកនាំកិច្ចប្រជុំអនុគណៈកម្មាធិការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (អ.វ.ហ.) ចំនួន ៣ លើក ដែលមានការចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន ១១។ កិច្ចប្រជុំនេះបានពិភាក្សាលើ

ការបង្កើតក្រុមការងារក្នុងក្រសួង-ស្ថាប័ន ឬក្រុមការងារអន្តរក្រសួងតាមម៉ូឌុលនីមួយៗ ការជ្រើសរើស និងបណ្តុះបណ្តាលមន្ត្រីជំនាញ ដើម្បីអនុវត្តការវាយតម្លៃហានិភ័យថ្នាក់ជាតិនេះឱ្យទទួលបានជោគជ័យ។

### ៣.២- កិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ ស.ហ.ក.

ស.ហ.ក. បានចុះអនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មជាមួយ i/-មជ្ឈមណ្ឌលស៊ើបការណ៍ហិរញ្ញវត្ថុនៃសាធារណរដ្ឋហ្កាណា និង ii/-អង្គភាពព័ត៌មានហិរញ្ញវត្ថុនៃប្រទេសម៉ុងហ្គោលី។ គិតត្រឹមឆ្នាំ២០២២ នេះ ស.ហ.ក. បានចុះអនុស្សរណៈយោគយល់ ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសសរុប ៣៦ និងកំពុងដំណើរការពិភាក្សាជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសផ្សេងទៀតផងដែរ។

- ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG)៖ ស.ហ.ក. បានបន្តកិច្ចសហប្រតិបត្តិការយ៉ាងសកម្មជាមួយ APG ដើម្បីពង្រឹងប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មទាំងក្នុងប្រទេសកម្ពុជា និងក្នុងតំបន់។ ជាក់ស្តែង ស.ហ.ក. បានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីស្នើសុំដំឡើងចំណាត់ថ្នាក់លើការអនុវត្តអនុសាសន៍របស់ FATF។ ជាលទ្ធផលប្រទេសកម្ពុជាបានទទួលជោគជ័យក្នុងការដំឡើងចំណាត់ថ្នាក់អនុសាសន៍ចំនួន ៥ ដែលបានទទួលការអនុម័តពីមហាសន្និបាតរបស់ APG។ សមិទ្ធិផលនេះឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ជាពិសេសគ្រប់អាជ្ញាធរពាក់ព័ន្ធ ក្នុងការចូលរួមក្នុងការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

ដើម្បីទទួលបានបទពិសោធន៍ និងឧត្តមានុវត្តល្អៗសម្រាប់កម្ពុជា ស.ហ.ក. បានចូលរួមកិច្ចប្រជុំពិភាក្សាមួយក្រុមការងារ APG ពាក់ព័ន្ធនឹង៖ i/-អភិបាលកិច្ច ii/-នីតិវិធីវាយតម្លៃអញ្ញមញ្ញ iii/-កាលវិភាគសម្រាប់ការវាយតម្លៃអញ្ញមញ្ញជុំទី៣ iv/-ការត្រៀមលក្ខណៈសម្រាប់ការវាយតម្លៃអញ្ញមញ្ញជុំទី៤ v/-ជំនួយបច្ចេកទេស ការបណ្តុះបណ្តាល និងគំរូសិក្សាអំពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម vi/-លទ្ធផលការងារប្រចាំឆ្នាំ២០២២ និងvii/-លទ្ធផលការងារប្រចាំត្រីមាសរបស់ FATF ជាដើម។

ទន្ទឹមនេះ ស.ហ.ក. បានផ្សព្វផ្សាយរបាយការណ៍របស់ FATF ស្តីពីប្រទេសមានហានិភ័យខ្ពស់ដែលតម្រូវឱ្យមានវិធានការប្រឆាំង (High-Risk Jurisdictions Subject to a Call for Action) និងប្រទេសដែលត្រូវបង្កើនការតាមដាន (Jurisdictions Under Increased Monitoring) ដោយតម្រូវឱ្យបុគ្គលរាយការណ៍ជំរុញការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនជាប្រចាំនៅពេលបង្កើតទំនាក់ទំនងអាជីវកម្ម និងប្រតិបត្តិការជាមួយប្រទេសទាំងនោះ។

- ក្រុមអ៊ិកម៉ុង (EGMONT Group) ៖ ស.ហ.ក. បានចូលរួមមហាសន្និបាតប្រចាំឆ្នាំលើកទី២៩ របស់ក្រុមអ៊ិកម៉ុង នៅទីក្រុងរីហ្គា ប្រទេសឡេតូនី ក្រោមប្រធានបទ "វិធីសាស្ត្រថ្មីក្នុងការបង្កើនប្រសិទ្ធភាពការងាររបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុក្នុងបរិស្ថានការងារផ្អែកលើហានិភ័យ"។ មហាសន្និបាតនេះមានកិច្ចប្រជុំក្រុមការងារចំនួន ៤ រួមមាន៖ i/-ក្រុមការងារផ្លាស់ប្តូរព័ត៌មាន (IEWG) ii/-ក្រុមការងារជំនួយបច្ចេកទេសនិងការបណ្តុះបណ្តាល (TATWG) iii/-ក្រុមការងារសមាជិកភាពការគាំទ្រ និងអនុលោមភាព (MSCWG) និងiv/-ក្រុមការងារគោលនយោបាយនិងនីតិវិធី (PPWG)។

ជាមួយគ្នានេះ ស.ហ.ក. ក៏បានចូលរួមកិច្ចប្រជុំដាច់ដោយឡែក ជាមួយសមាជិកនានា នៅក្នុងតំបន់អាស៊ីប៉ាហ្វិកផងដែរ ដោយពិភាក្សាពីបទពិសោធន៍ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការ ការអនុវត្តវិធីសាស្ត្រថ្មីៗ និងករណីសិក្សាល្អៗ ដែលប្រទេសជាសមាជិកអនុវត្តបានដោយជោគជ័យ នាពេលកន្លងមក។

- ក្រុមការងារប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ (FICG) ៖ ស.ហ.ក. បានចូលរួមកិច្ចប្រជុំក្រុម FICG តាមប្រព័ន្ធអនឡាញ ដើម្បីពិនិត្យ តាមដាន និងចែករំលែកព័ត៌មានអំពីការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក្នុងក្របខ័ណ្ឌតំបន់អាស៊ានបូកអូស្ត្រាលីនិងនូវែលសេឡង់។ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ ក្រុម FICG បានរៀបចំរចនាសម្ព័ន្ធ ការប្រជុំ និងយន្តការការងារថ្មីរបស់ខ្លួន ដើម្បីឆ្លើយតបនឹងស្ថានភាពនិងភាពស្មុគស្មាញ ដែលក្រុមឧក្រិដ្ឋជនប្រើប្រាស់វិធីសាស្ត្រនិងបច្ចេកវិទ្យាថ្មីៗ។ ជាមួយគ្នានេះ ក្រុម FICG ក៏បានពិភាក្សាអំពីលទ្ធភាពនៃការរៀបចំកិច្ចប្រជុំផ្ទាល់ក្នុងគន្លងប្រក្រតីថ្មី និងអំពីការពង្រីកសមាជិកថ្មី គឺអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុនៃប្រទេសទីម័រខាងកើត (Timor-Leste)។ ជារួម ទំហំនិងយន្តការការងាររបស់ក្រុម FICG នេះកំពុងវិវត្តទៅមុខយ៉ាងឆាប់រហ័ស ដើម្បីឆ្លើយតបនឹងស្ថានភាពស្មុគស្មាញ និងប្រទាក់ក្រឡាគ្នាលើការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ហើយ ស.ហ.ក. បាននិងកំពុងពង្រឹងនិងបង្កើនធនធានមនុស្ស ដើម្បីឆ្លើយតបតាមការវិវត្តទាំងនេះ។

## ៤. ការបណ្តុះបណ្តាលនិងការផ្សព្វផ្សាយ

ស.ហ.ក. បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាតាមប្រព័ន្ធអនឡាញ ពាក់ព័ន្ធនឹងប្រធានបទសំខាន់ៗ រួមមាន៖ i/-ការវិភាគនិងការស៊ើបអង្កេតពាក់ព័ន្ធនឹងរូបិយប័ណ្ណគ្រីបតូ (Cryptocurrency) ii/-ការប្រឆាំងការសម្អាតប្រាក់ដែលពាក់ព័ន្ធបទល្មើសព្រៃឈើនិងសត្វព្រៃ iii/-ការត្រួតពិនិត្យដែលពាក់ព័ន្ធនឹងទ្រព្យសកម្មនិម្មិត និងiv/-ការស៊ើបអង្កេតការសម្អាតប្រាក់តាមរយៈកាស៊ីណូ បទល្មើសបច្ចេកទេស ការតាមដាន ទប់ស្កាត់ និងយកត្រលប់មកវិញនូវលំហូរសាច់ប្រាក់ខុសច្បាប់។ ដោយឡែក ស.ហ.ក. ក៏បានរៀបចំសិក្ខាសាលា និងផ្តល់បទឧទ្ទេសនាម តាមប្រព័ន្ធអនឡាញចំនួន ១០ លើក ដល់គ្រឹះស្ថានធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងច្បាប់និងបទប្បញ្ញត្តិ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដោយមានសិក្ខាកាមចូលរួមចំនួន ៤២៥នាក់។

## VIII- កិច្ចសហប្រតិបត្តិការអន្តរជាតិ

### ១- កិច្ចសហប្រតិបត្តិការពហុភាគី

ធនាគារជាតិនៃកម្ពុជា បានបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយបណ្តាស្ថាប័នអន្តរជាតិនានា ដើម្បីលើកកម្ពស់សមាហរណកម្មទាំងក្នុងតំបន់និងអន្តរជាតិ ផ្លាស់ប្តូរចំណេះដឹង បទពិសោធន៍ និងអភិវឌ្ឍសមត្ថភាពធនធានមនុស្ស។

- **កិច្ចសហប្រតិបត្តិការអាស៊ាន៖** ក្នុងនាមកម្ពុជាជាប្រធានអាស៊ានឆ្នាំ២០២២ ធនាគារជាតិនៃកម្ពុជាបានដឹកនាំនិងសហការដឹកនាំកិច្ចប្រជុំពាក់ព័ន្ធនានានឹងវិស័យហិរញ្ញវត្ថុរួមមាន៖ i/-កិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី១៨ (ACGM) ក្នុងគោលបំណងជំរុញសេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុអាស៊ាន សមាហរណកម្មវិស័យធនាគារ បរិយាបន្នហិរញ្ញវត្ថុ និងហិរញ្ញប្បទានប្រកបដោយចីរភាព និង ii/-កិច្ចប្រជុំរវាងទេសាភិបាលធនាគារកណ្តាលអាស៊ានជាមួយនាយកប្រតិបត្តិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាស៊ាន (CEOs Dialogue) ដើម្បីពិភាក្សាទៅលើការពង្រឹងនិងពង្រីកការតភ្ជាប់ប្រព័ន្ធទូទាត់ឆ្លងដែនទ្វេភាគីនិងពហុភាគីក្នុងតំបន់អាស៊ាន ឱ្យមានលក្ខណៈឆាប់រហ័ស តម្លៃទាប និងសុវត្ថិភាព។ លើសពីនេះ ធនាគារជាតិនៃកម្ពុជា ក៏បានសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើជាសហប្រធានដឹកនាំកិច្ចប្រជុំសំខាន់ៗចំនួន ២ រួមមាន៖ i/-កិច្ចប្រជុំរួមរវាងរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី៨ (AFMGM) ក្រោមមូលបទរួមអាស៊ានឆ្នាំ២០២២ "អាស៊ានរួមគ្នាធ្វើ ៖ ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា" និង ii/-កិច្ចប្រជុំរវាងធនាគារកណ្តាលនិងក្រសួងហិរញ្ញវត្ថុអាស៊ាន ជាមួយនឹងវិស័យឯកជន ដែលក្នុងនោះរួមមាន ក្រុមប្រឹក្សាធុរកិច្ចអាស៊ាន (ASEAN-BAC) ក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាមេរិក-អាស៊ាន (US-ABC) និងក្រុមប្រឹក្សាធុរកិច្ចសហគមន៍អឺរ៉ុប-អាស៊ាន (EU-ABC) ដើម្បីពិភាក្សាលើប្រធានបទសំខាន់ៗរួមមាន៖ ១/-ផលប៉ះពាល់នៃភាពតានតឹងភូមិសាស្ត្រនយោបាយមកលើសេដ្ឋកិច្ចតំបន់ ២/-ការលើកកម្ពស់បរិយាកាសហិរញ្ញវត្ថុនិងវិនិយោគក្នុងតំបន់ និង ៣/-ការចូលរួមរបស់វិស័យឯកជនក្នុងការជំរុញហិរញ្ញប្បទានប្រកបដោយចីរភាព និងការអនុវត្តបច្ចេកវិទ្យាឌីជីថលក្នុងប្រតិបត្តិការពាណិជ្ជកម្មនិងហិរញ្ញវត្ថុសំដៅលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់អាស៊ានឱ្យកាន់តែខ្លាំងជាងមុន។

- **កិច្ចសហប្រតិបត្តិការអាស៊ាន+៣៖** ធនាគារជាតិនៃកម្ពុជាបានធ្វើជាសហប្រធានជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា ធនាគារកណ្តាលចិន និងក្រសួងហិរញ្ញវត្ថុចិន ដើម្បីដឹកនាំកិច្ចប្រជុំសំខាន់ៗរួមមាន៖ i/-កិច្ចប្រជុំរួមថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្តាលអាស៊ាន+៣ លើកទី២៥ ii/-កិច្ចប្រជុំរួមថ្នាក់អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលរងធនាគារកណ្តាលអាស៊ាន+៣ និង iii/-កិច្ចប្រជុំពាក់ព័ន្ធនានា។ តាមរយៈកិច្ចសហប្រតិបត្តិការអាស៊ាន+៣ សំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់ត្រូវបានពង្រឹង ដោយក្នុងនោះរួមមាន៖ i/-ការកែសម្រួលយន្តការពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) ដើម្បីផ្តល់សន្ទនីយភាពដល់ប្រទេសជាសមាជិក សម្រាប់បង្ការនិងដោះស្រាយវិបត្តិ ii/-ការពង្រឹងសមត្ថភាពអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ដើម្បីតាមដានស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសជាសមាជិក និងការជួយគាំទ្រដល់ដំណើរការយន្តការ CMIM iii/-ការជំរុញការចេញផ្សាយសញ្ញាប័ណ្ណក្នុងតំបន់អាស៊ាន+៣ ស្របតាមគំនិតផ្តួចផ្តើមទីផ្សារសញ្ញាប័ណ្ណ

អាស៊ី ជាពិសេសគឺការជំរុញការធានាលើការបោះផ្សាយសញ្ញាប័ណ្ណនិងការពង្រីកចំណេះដឹងអំពីទីផ្សារសញ្ញាប័ណ្ណអាស៊ី iv/-ការស្វែងរកនូវគំនិតផ្តួចផ្តើមថ្មីៗសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ាន+៣ និង v/-ការរៀបចំកិច្ចសហប្រតិបត្តិការអាស៊ាន+៣ ក្នុងការធានារ៉ាប់រងនិងហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) បានបំពេញបេសកកម្មប្រឹក្សាស្ថានភាពសេដ្ឋកិច្ចចំនួន ២លើក ដោយបានផ្តល់អនុសាសន៍នានាដើម្បីពង្រឹងនិងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅកម្ពុជា។ អង្គភាព AMRO ក៏បានទទួលយកមន្ត្រីជំនាញធនាគារជាតិនៃកម្ពុជាធ្វើជាបុគ្គលិកហាត់ការ (Secondment) មួយរូបជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ២០១៧ មក។

- **មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)៖** IMF បានបន្តបំពេញបេសកកម្មពិភាក្សា (Staff Visit) និងបេសកកម្មពិគ្រោះយោបល់មាត្រា IV ដើម្បីជួយតាមដាននិងវាយតម្លៃស្ថានភាពសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុ ព្រមទាំងផ្តល់អនុសាសន៍លើគោលនយោបាយសេដ្ឋកិច្ចចម្បងៗ។ IMF បានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញរបស់ធនាគារជាតិនៃកម្ពុជា តាមរយៈការផ្តល់ជំនួយបច្ចេកទេសនិងវគ្គបណ្តុះបណ្តាលនានា ការត្រួតពិនិត្យធនាគារ ការអនុវត្តនយោបាយរូបិយវត្ថុ ការតាមដានស្ថានភាពវិស័យអចលនទ្រព្យ និងស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា។ល។ ក្នុងឱកាសកិច្ចប្រជុំកំពូលអាស៊ាន លោកជំទាវ Kristalina Georgieva នាយកគ្រប់គ្រងមូលនិធិរូបិយវត្ថុអន្តរជាតិ បានអញ្ជើញមកបំពេញបេសកកម្មនៅកម្ពុជា ដែលបង្ហាញពីការគាំទ្ររបស់ IMF ចំពោះកម្ពុជាក្នុងការធ្វើជាប្រធានអាស៊ាន ផងដែរ។

- **ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)៖** ADB បានបន្តគាំទ្រការផ្តល់ចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ ដំណាក់កាលទី២ ព្រមទាំងកំពុងធ្វើបច្ចុប្បន្នកម្មលើកម្មវិធី "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥" ទៅជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០២១-២០៣០"។ ក្នុងការរួមចំណែកពង្រឹងសមត្ថភាពមន្ត្រីធនាគារជាតិនៃកម្ពុជា ADB ក៏បានរៀបចំសិក្ខាសាលាស្តីពី ការដោះស្រាយឥណទានមិនដំណើរការ ការចែករំលែកព័ត៌មានស្តីពីការពិនិត្យឡើងវិញទៅលើគោលនយោបាយគាំពារសេដ្ឋកិច្ច និងផ្លែតហូមឌីជីថលនិងការស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញក្រោយវិបត្តិកូវីដ-១៩ ព្រមទាំងរៀបចំសិក្ខាសាលារួមគ្នាជាមួយសាកលវិទ្យាល័យ Cambridge ស្តីពី បច្ចេកវិទ្យាហិរញ្ញវត្ថុ និងនវានុវត្តន៍បទប្បញ្ញត្តិ។ លើសពីនេះ ADB បានជួបប្រជុំជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីពិភាក្សាពីយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសឆ្នាំ២០១៩-២០២៣ សំដៅរៀបចំយុទ្ធសាស្ត្រថ្មីសម្រាប់ឆ្នាំ២០២៤-២០២៨ និងកិច្ចប្រជុំ ស្តីពី ការប្រមូលព័ត៌មានលើវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

- **មជ្ឈមណ្ឌលស៊ាសិន (SEACEN)៖** SEACEN បានរួមចំណែកបណ្តុះបណ្តាល មន្ត្រីជំនាញរបស់ធនាគារជាតិនៃកម្ពុជាតាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលនិងស្រាវជ្រាវ។ នៅឆ្នាំ២០២២នេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃទេសាភិបាលស៊ាសិន (BOG) និងសិក្ខាសាលាជាន់ខ្ពស់ និងសន្និសីទថ្នាក់ទេសាភិបាល ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាលនៃទេសាភិបាលស៊ាសិនឆ្នាំ២០២៣ ដោយមានការចូលរួមពីទេសាភិបាលធនាគារកណ្តាលសមាជិកស៊ាសិន និងតំណាងស្ថាប័នជាសមាជិក ក៏ដូចជាស្ថាប័នអន្តរជាតិមួយចំនួន ដូចជា លោកជំទាវ

Christine Lagarde ប្រធានធនាគារកណ្តាលអឺរ៉ុប (ECB) លោក Luiz Pereira da Silva អនុ-ប្រធានធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) និង លោកបណ្ឌិត Nord Roger តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ជាដើម។

**ប្រអប់ ២ ៖ កិច្ចសហប្រតិបត្តិការពហុភាគីជាមួយស្ថាប័នផ្សេងៗ**

- **ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)៖** JICA បានសហការស្រាវជ្រាវនិងគ្រោងចេញផ្សាយសៀវភៅ ស្តីពី ដុល្លាររូបនីយកម្មនៅកម្ពុជានិងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាសាធារណៈ នាពេលខាងមុខ។ ជាមួយគ្នានេះ ក្រោមគម្រោងសហ-ប្រតិបត្តិការបច្ចេកទេស ធនាគារជាតិនៃកម្ពុជា និង JICA បានពិភាក្សានិងឯកភាពលើគម្រោង ស្តីពី "ការលើកកម្ពស់សមត្ថភាពក្នុងការស្រាវជ្រាវនិងវិភាគសេដ្ឋកិច្ច និងប្រតិបត្តិការនយោបាយរូបិយវត្ថុ" ដែលមានរយៈពេល ៣ឆ្នាំ ចាប់ពីខែមករា ឆ្នាំ២០២៣ ដល់ខែធ្នូ ឆ្នាំ២០២៥។
- **មូលនិធិអភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ (UNCDF)៖** UNCDF បាននិងកំពុងសហការអនុវត្តគម្រោងប្រមូលទិន្នន័យបរិយាបន្នហិរញ្ញវត្ថុសម្រាប់ធ្វើជាសូចនាករមូលដ្ឋាន ដើម្បីវាស់វែងការអនុវត្តយុទ្ធសាស្ត្រជាតិ ដោយផ្តោតលើការទទួលបានការប្រើប្រាស់ និងគុណភាពសេវាហិរញ្ញវត្ថុរបស់អ្នកប្រើប្រាស់ តាមរយៈការសង្កេតលើផ្នែកតម្រូវការ និងការផ្គត់ផ្គង់។ លទ្ធផលនៃការធ្វើអង្កេតនេះ នឹងត្រូវប្រើប្រាស់ដើម្បីវាយតម្លៃឡើងវិញលើស្ថានភាពបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា និងតាមដានលើការអនុវត្តផែនការសកម្មភាពដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិ ស្តីពី "បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥"។
- **កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP)៖** UNDP បានបន្តសហការរៀបចំកម្មវិធីសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងរួមចំណែកគាំទ្រការស្រាវជ្រាវនិងផ្តល់ជាវេទិកាពិភាក្សាទៅលើប្រធានបទសំខាន់ៗ ដែលពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅកម្ពុជា។ UNDP ក៏បានសហការជាមួយមន្ត្រីជំនាញធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើការសិក្សាស្រាវជ្រាវទៅលើ "ការធ្វើអង្កេតទីផ្សារស្តីពីការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ" ដោយផ្តោតចម្បងទៅលើវិនិយោគិនសក្តានុពលរួមមាន៖ i/-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ii/-ក្រុមហ៊ុនធានារ៉ាប់រង និង iii/-បេឡាជាតិសន្តិសុខសង្គម ក្នុងគោលបំណងគាំទ្រដល់គម្រោងចេញផ្សាយមូលបត្ររដ្ឋជាលើកដំបូងរបស់រាជរដ្ឋាភិបាលកម្ពុជា។
- **គណៈកម្មការសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ (UNESCAP)៖** UNESCAP បានសហការអនុវត្តកម្មវិធី និងរៀបចំវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹង ការលើកកម្ពស់សហគ្រិនស្ត្រី ស្តីពី "ការជំរុញសហគ្រិនភាពរបស់ស្ត្រី (Catalyzing Women's Entrepreneurship)" និង "ចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថលសម្រាប់សហគ្រិនស្ត្រី (Digital Financial Literacy for Women Entrepreneurs)" ក្នុងនោះមាន៖ i/-ការសិក្សាពីលទ្ធភាពទទួលបានឥណទានដោយមិនចាំបាច់មានទ្រព្យធានា ii/-វគ្គបណ្តុះបណ្តាល ស្តីពី "ការជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុនិងសហគ្រិនភាពរបស់សហគ្រិនស្ត្រី" iii/-វគ្គបណ្តុះបណ្តាល ស្តីពី "ការរៀបចំបញ្ជីអាជីវកម្មតាមបែបឌីជីថល" និង iv/-វគ្គ

បណ្តុះបណ្តាល ស្តីពី "លទ្ធភាពទទួលបាន និងការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការដល់ស្ត្រីនិងសហគ្រិនស្ត្រី"។

- **សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ (AFI)៖** AFI បានអនុម័តគម្រោងជំនួយបច្ចេកទេសដើម្បីពង្រឹងសមត្ថភាពមន្ត្រីធនាគារជាតិនៃកម្ពុជាក្នុងការប្រមូលនិងវិភាគទិន្នន័យ ស្តីពី "កម្រិតបរិយាបន្នហិរញ្ញវត្ថុ" និងសហការរៀបចំក្របខ័ណ្ឌ ឬនីតិវិធី និងអនុវត្តសកម្មភាពមួយចំនួន ដើម្បីលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថលនៅកម្ពុជា។

- **សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)៖** IFC បានសហការរៀបចំវេទិកាហិរញ្ញវត្ថុសហគ្រាសធុនតូចនិងមធ្យមសកលប្រចាំឆ្នាំ២០២២ (Global SME Finance Forum 2022) ដោយមានការចូលរួមពីតំណាងម្ចាស់ក្រុមហ៊ុន-សហគ្រាស ធនាគារកណ្តាល និងស្ថាប័នហិរញ្ញវត្ថុនានា ប្រមាណជាង ៥០០នាក់ មកពី ៦៥ប្រទេស។ ក្នុងវេទិកានេះ ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាក៏បានចូលរួមផ្តល់ពានរង្វាន់ "ហិរញ្ញវត្ថុសហគ្រាសធុនតូចនិងមធ្យមសកលប្រចាំឆ្នាំ២០២២" ដល់សហគ្រាសធុនតូចនិងមធ្យមឆ្នើម ព្រមទាំងធ្វើជាវាគ្មិនក្នុងវេទិកាអន្តរជាតិនេះផងដែរ។

- **ធនាគារកណ្តាលនៃប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន)៖** ធនាគារកណ្តាលនៃប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន)៖ ហ្វ្រង់កូហ្វូនបានរៀបចំសន្និសីទលើកទី២៦ ថ្នាក់ទេសាភិបាល ធនាគារកណ្តាលនៃប្រទេសនិយាយភាសាបារាំង ដោយមានចូលរួមពីធនាគារកណ្តាលនៃប្រទេសចំនួន ៣០ រួមទាំងធនាគារជាតិនៃកម្ពុជាផងដែរ ដើម្បីពិភាក្សាពីតួនាទីរបស់ធនាគារកណ្តាលក្នុងការចូលរួមកាត់បន្ថយការប្រែប្រួលអាកាសធាតុ រូបិយវត្ថុឌីជីថល និងបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ទន្ទឹមនេះធនាគារជាតិនៃកម្ពុជាក៏ត្រូវបានអញ្ជើញឱ្យធ្វើបទបង្ហាញចែករំលែកបទពិសោធន៍អំពីប្រព័ន្ធបាគង ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិថាជាប្រព័ន្ធទូទាត់ដែលប្រើប្រាស់បច្ចេកវិទ្យាឈានមុខគេនៅលើពិភពលោក។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិផ្សេងទៀតដូចជា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) មូលនិធិអភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ (UNCDF) កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) គណៈកម្មការសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ (UNESCAP) សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ (AFI) សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ។ល។ ដើម្បីរួមចំណែកក្នុងការសិក្សាស្រាវជ្រាវ ពង្រឹងមូលដ្ឋានទិន្នន័យ បរិយាបន្នហិរញ្ញវត្ថុ ចំណេះដឹងហិរញ្ញវត្ថុ ជាដើម។

គណៈប្រតិភូធនាគារជាតិនៃកម្ពុជាដឹកនាំដោយ ឯកឧត្តម ទេសាភិបាល បានចូលរួមសន្និសីទអន្តរជាតិលើកទី៣ ស្តីពីការប្រឆាំងហិរញ្ញប្បទានភេរវកម្ម ក្រោមប្រធានបទ "No Money for Terror" នៅទីក្រុងញូដេលី សាធារណរដ្ឋឥណ្ឌា កាលពីថ្ងៃទី១៨-១៩ ខែវិច្ឆិកា ឆ្នាំ២០២២ ដែលមាន ៨៩ ប្រទេស និង ២០ អង្គការអន្តរជាតិសំខាន់ៗចូលរួម។ នាឱកាសនោះ ឯកឧត្តម បានថ្លែងបទអន្តរាគមន៍គាំទ្រសន្និសីទ និងបានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការចូលរួមជាមួយសហគមន៍អន្តរជាតិប្រឆាំងហិរញ្ញប្បទានភេរវកម្ម។

ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ក៏បានចូលរួមធ្វើជាវាគ្មិនតាមការអញ្ជើញពីស្ថាប័នអន្តរជាតិនានា រួមមាន៖ i/-ការចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលនៃប្រទេស G20 ii/-ការចែករំលែកបទពិសោធន៍អំពី "បញ្ហាប្រឈមរបស់ស្ត្រីក្នុងការទទួលបានសេវាហិរញ្ញវត្ថុ និងភាពជាអ្នកដឹកនាំក្នុងការរៀបចំគោលនយោបាយ និងបទប្បញ្ញត្តិក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី" ព្រមទាំងកិច្ចពិភាក្សា ស្តីពី "ការប្រើប្រាស់រូបិយប័ណ្ណឌីជីថលរបស់ធនាគារកណ្តាលក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងការទូទាត់ប្រកបដោយប្រសិទ្ធភាព" រៀបចំដោយសហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ iii/-ការធ្វើជាវាគ្មិនកិត្តិយសក្នុងវគ្គពិភាក្សាតុមូល ស្តីពីបច្ចេកវិទ្យាហិរញ្ញវត្ថុ និងចូលរួមក្នុងកិច្ចប្រជុំពិភាក្សាលើបញ្ហាប្រឈមថ្មីៗរបស់ធនាគារកណ្តាលនិងគោលនយោបាយឆ្លើយតបនានា រៀបចំដោយ BIS និង iv/-ការចូលរួមចែករំលែកចំណេះដឹងនៅក្នុងវេទិកានវានុវត្តន៍ពាក់ព័ន្ធនឹងការស្វែងរកដំណោះស្រាយចំពោះបញ្ហាសុខភាពក្នុងតំបន់ ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល រៀបចំដោយអង្គការសុខភាពពិភពលោក (WHO)។ ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ក៏បានចូលរួមសន្និសីទថ្នាក់ទេសាភិបាលប្រទេសនិយាយភាសាបារាំង នៅទីក្រុងរ៉ាបា ប្រទេសម៉ារ៉ុក ព្រមទាំងបានចែករំលែកបទពិសោធន៍របស់កម្ពុជាក្នុងការបង្កើតនិងដាក់ឱ្យដំណើរការប្រព័ន្ធបាគង បន្ទាប់ពីប្រព័ន្ធបាគងត្រូវបានទទួលស្គាល់ជាអន្តរជាតិក្នុងការចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច លើកកម្ពស់បរិយាបន្ន និងការប្រើប្រាស់រូបិយវត្ថុជាតិ។

## ២- កិច្ចសហប្រតិបត្តិការទ្វេភាគី

ធនាគារជាតិនៃកម្ពុជា បន្តពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយធនាគារកណ្តាលនៅក្នុងតំបន់និងពិភពលោករួមមាន៖

- ចូលរួមកិច្ចប្រជុំទ្វេភាគីជាមួយធនាគាររដ្ឋវៀតណាម និងបានចុះអនុស្សរណៈយោគយល់ ស្តីពី កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុនិងប្រព័ន្ធទូទាត់សងប្រាក់
- រៀបចំកិច្ចប្រជុំទ្វេភាគីជាមួយធនាគារកណ្តាលឡាវ និងបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពី កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុនិងប្រព័ន្ធទូទាត់សងប្រាក់
- តភ្ជាប់ប្រព័ន្ធទូទាត់ឆ្លងដែនជាមួយធនាគារកណ្តាលថៃ ដោយបច្ចុប្បន្ន ប្រជាជនខ្មែរអាចទូទាត់ថ្លៃទិញទំនិញនិងសេវានៅប្រទេសថៃ ហើយជំហានបន្ទាប់ ប្រជាជនថៃនឹងអាចទូទាត់ថ្លៃទិញទំនិញនិងសេវានៅប្រទេសកម្ពុជាបាន
- ស្រាវជ្រាវរួមគ្នាក្នុងកម្មវិធីភាពជាដៃគូផ្តល់ចំណេះដឹងរបស់ធនាគារកណ្តាលកូរ៉េ (BOK-KPP) លើប្រធានបទ "ការអភិវឌ្ឍប្រព័ន្ធត្រួតពិនិត្យហានិភ័យជាប្រព័ន្ធ"
- ពង្រឹងកិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយធនាគារកណ្តាលបារាំង លើកិច្ចព្រមព្រៀង ស្តីពីការគ្រប់គ្រងទុនបម្រុងអន្តរជាតិ និងបានចុះអនុស្សរណៈយោគយល់ ស្តីពី ការលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពធនធានមនុស្សនិងការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុ
- ចែករំលែកបទពិសោធន៍ក្នុងការបង្កើតប្រព័ន្ធទូទាត់បាគង ជាមួយធនាគារកណ្តាលនៃប្រទេសមួយចំនួនដូចជា ប្រទេសលីបង់ ម៉ាដាហ្គាស្កា និងម៉ូសំប៊ិក ។ល។ និង

- សហការជាមួយធនាគារកណ្តាលអាមេរិក និងទីភ្នាក់ងារ US Secret Service រៀបចំវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ ស្តីពី "ការពិនិត្យវិនិច្ឆ័យលើក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយ"។

ជាមួយនឹងកិច្ចសហប្រតិបត្តិការល្អជាមួយធនាគារកណ្តាលនានា មន្ត្រីធនាគារជាតិនៃកម្ពុជាទទួលបានអាហារូបករណ៍ទៅសិក្សានៅប្រទេសក្រៅដូចជា៖ លុចសំបួ ថៃ វៀតណាម ជាដើម ដែលរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា។

## IX- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

### ១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ន ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| - ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ជាប្រធាន |
| - ឯកឧត្តម ស៊ុំ សន្និសិទ្ធ | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិក |
| - ឯកឧត្តម ជូ គឹមឡេង | តំណាងប្រមុខរាជរដ្ឋាភិបាល | ជាសមាជិក |
| - ឯកឧត្តម អ៊ីវ ថុង | តំណាងឱ្យមជ្ឈដ្ឋានឧត្តមសិក្សា | ជាសមាជិក |
| - ឯកឧត្តម រស់ សីលវ៉ា | តំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| - ឯកឧត្តម ឡាយ ម៉េងស៊ុន | តំណាងឱ្យមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | ជាសមាជិក និង |
| - លោក មុំ ដារ៉េត | តំណាងឱ្យបុគ្គលិកធនាគារជាតិនៃកម្ពុជា | ជាសមាជិក។ |

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាបានជួបប្រជុំចំនួន ៦ លើក គឺកិច្ចប្រជុំក្រុមប្រឹក្សាភិបាល៖

- លើកទី១៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៥០ កាលពីថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេច ស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារជាតិនៃកម្ពុជា សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១។

- លើកទី២៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៥១ កាលពីថ្ងៃចន្ទ ៥កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្ថានភាពថវិកាធនាគារជាតិនៃកម្ពុជាឆ្នាំ២០២១ និងផែនការឆ្នាំ២០២២។

- លើកទី៣៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៥២ កាលពីថ្ងៃព្រហស្បតិ៍ ៩កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២២ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២២។

- លើកទី៤៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៥៣ កាលពីថ្ងៃព្រហស្បតិ៍ ១២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ ដើម្បី i/-ប្រកាសសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ii/- កែសម្រួលសមាសភាពក្រុមលេខាធិការដ្ឋាន

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និង iii/- របាយការណ៍ស្តីពី លទ្ធផលនៃបេសកកម្មពិគ្រោះយោបល់មាត្រាទី IV របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) សម្រាប់ឆ្នាំ២០២២។

- លើកទី៥៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៥៤ កាលពីថ្ងៃសុក្រ ៣រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២ ដើម្បីពិនិត្យ និងអនុម័តលើរបាយការណ៍តារាងតុល្យការ។

- លើកទី៦៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៥៥ កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣របស់ធនាគារជាតិនៃកម្ពុជា។

## ២- ការអភិវឌ្ឍធនធានមនុស្ស

### ក. ស្ថិតិមន្ត្រី-បុគ្គលិក

មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេស មានចំនួន ១.៨៨៩ រូប (ប្រុស ៩៥៩ រូប និងស្រី ៩៣០ រូប) ក្នុងនោះទីស្នាក់ការកណ្តាលមាន ១.៣៧៨ រូប (ប្រុស ៧២០ រូប និងស្រី ៦៥៨ រូប) និងសាខារាជធានី-ខេត្តមាន ៥១១ រូប (ប្រុស ២៣៩ រូប និងស្រី ២៧២ រូប)។ មន្ត្រីនៅទីស្នាក់ការកណ្តាលកើនឡើង ៨៣ រូប (ជ្រើសរើសថ្មី ៨៩ រូប ផ្ទេរចូល ១៤ រូប ផ្ទេរចេញ ៣ រូប ចូលនិវត្តន៍ ១០ រូប លាឈប់ ៦ រូប និងមរណភាព ១ រូប) ខណៈនៅសាខាកើនឡើង ៣១ រូប (ជ្រើសរើសថ្មី ៤៤ រូប ផ្ទេរចូល ៣ រូប ផ្ទេរចេញ ១៥ រូប និងចូលនិវត្តន៍ ១ រូប)។

**តារាង ១ ៖ ស្ថិតិមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាប្រចាំឆ្នាំ២០២២**

| | | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ | ប្រែប្រួល |
|---|---|---|---|---|---|---|
| **ទីស្នាក់ការកណ្តាល** | ប្រុស | ៦៤២ | ៦៦៤ | ៦៨៦ | ៧២០ | ៣៤ |
| | ស្រី | ៥៦៦ | ៥៨៨ | ៦០៩ | ៦៥៨ | ៤៩ |
| | សរុប | ១.២០៨ | ១.២៥២ | ១.២៩៥ | ១.៣៧៨ | ៨៣ |
| **សាខា** | ប្រុស | ២២៤ | ២៣៣ | ២៣១ | ២៣៩ | ៨ |
| | ស្រី | ២៣៣ | ២៥៧ | ២៤៩ | ២៧២ | ២៣ |
| | សរុប | ៤៥៧ | ៤៩០ | ៤៨០ | ៥១១ | ៣១ |
| **សរុបទូទាំងប្រទេស** | ប្រុស | ៨៦៦ | ៨៩៧ | ៩១៧ | ៩៥៩ | ៤២ |
| | ស្រី | ៧៩៩ | ៨៤៥ | ៨៥៨ | ៩៣០ | ៧២ |
| | សរុប | ១.៦៦៥ | ១.៧៤២ | ១.៧៧៥ | ១.៨៨៩ | ១១៤ |

## ខ. ការបណ្តុះបណ្តាល

**- ការងារបណ្តុះបណ្តាលក្នុងប្រទេស**

សមត្ថភាពជំនាញរបស់មន្ត្រីបុគ្គលិកត្រូវបានអភិវឌ្ឍជាប្រចាំតាមរយៈការបើកវគ្គបណ្តុះ-បណ្តាល វគ្គសុក្រឹតការ និងការចាត់បញ្ជូនឱ្យទៅចូលរួមតាមការអញ្ជើញរបស់ក្រសួង-ស្ថាប័ន ដែលរួមមានសិក្ខាសាលាចំនួន ៣៥ លើក (សិក្ខាកាមចូលរួម ៤១០ រូប) វគ្គសិក្សា ១៥ លើក (សិក្ខាកាមចូលរួម ៣២០ រូប) កិច្ចប្រជុំ ៧៥ លើក (មន្ត្រី-បុគ្គលិកចូលរួម ៥៩០ រូប) និងបានរៀបចំកម្មវិធីចុះកម្មសិក្សានៅធនាគារជាតិនៃកម្ពុជាជូនសិស្ស-និស្សិតមកពីបណ្តាគ្រឹះស្ថានឧត្តមសិក្សា ៣៥ លើក (សិស្ស-និស្សិតចូលរួម ១៧៥ រូប)។

ទន្ទឹមនេះ ការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញក៏ត្រូវបានរៀបចំឡើងចំនួន ២ វគ្គសិក្សា គឺ៖ i/-វគ្គសិក្សា NBC FSI-Connect ជំនាញត្រួតពិនិត្យធនាគារ ក្រោមកម្មវិធីរបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុនៃធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) ដែលត្រូវបានរៀបចំចំនួន ៦ ជំនាន់រួចមកហើយ និងមានសិក្ខាកាមចូលរួមសិក្សាសរុបចំនួន ៣៥៦ រូប ក្នុងនោះសិក្ខាកាមអាហារូបករណ៍២៥ រូប។ គុណភាពសិក្សាត្រូវបានវាយតម្លៃតាមរយៈការប្រឡងតាមប្រព័ន្ធអនឡាញ ជាបន្តបន្ទាប់បានចំនួន ៨៧ លើក ហើយមានមន្ត្រី-បុគ្គលិកប្រឡងបញ្ចប់កម្រិតបឋមចំនួន ១១៥ រូប កម្រិតមធ្យម ៦៧ រូប និងកម្រិតខ្ពស់ ៩០ រូប និង ii/-វគ្គសិក្សា NBC-IMF ស្តីពីកម្មវិធីនិងគោលនយោបាយហិរញ្ញវត្ថុ (FPP) របស់មូលនិធិរូបិយវត្ថុអន្តរជាតិមាន៣ជំនាន់ និងមានសិក្ខាកាមសរុបចំនួន ២៥៥ រូប ដោយសិក្ខាកាមទាំង ៣ជំនាន់នេះ បានប្រឡងបញ្ចប់កម្មវិធីសិក្សាទាំងពីរកម្រិតតាមប្រព័ន្ធអនឡាញដោយជោគជ័យ។

ចំពោះការបណ្តុះបណ្តាលនិស្សិតថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ មណ្ឌលសិក្សាបច្ចេកទេសធនាគារ (CBS) បាននិងកំពុងបណ្តុះបណ្តាលនិស្សិត ២៨០ រូប (ស្រី ២០៥ រូប) ដែលក្នុងនោះនិស្សិតជំនាន់ទី៣០ មាន ១៤១ រូប និងជំនាន់ទី៣១ មាន ១៣៩ រូប និងមានសាស្ត្រាចារ្យ ៦០ រូប (ស្រី ១៤ រូប)។ ក្នុងគោលដៅពង្រឹងគុណភាពសិក្សា និងផ្លាស់ប្តូរបទពិសោធន៍ការងារ CBS បានបន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា រួមមាន៖ វិទ្យាស្ថានអាស៊ីសម្រាប់ធនាគារិក (Asian Institute of Chartered Banker - AICB) វិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ (IBF) សមាគមធនាគារនៅកម្ពុជា (ABC) និងវិទ្យាស្ថានបណ្តុះបណ្តាលនៃធនាគារកណ្តាលម៉ាឡេស៊ី ហ្វីលីពីន និងថៃ។ គួររំលេចថា អគារថ្មីនៃមណ្ឌលសិក្សាបច្ចេកទេសធនាគារ ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ ដើម្បីរួមចំណែកពង្រឹងគុណភាពនិងប្រសិទ្ធភាពសិក្សាបន្ថែមទៀត។

**- ការងារបណ្តុះបណ្តាលក្រៅប្រទេស**

មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាត្រូវបានចាត់បញ្ជូនឱ្យចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់ចំនួន ៥៥លើក (មន្ត្រី-បុគ្គលិកចូលរួម ២០៣ រូប) វគ្គសិក្សារយៈពេលខ្លី តាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់ ១២២ លើក (មន្ត្រី-បុគ្គលិកចូលរួម ៧០៩ រូប) និងវគ្គសិក្សារយៈពេលវែង ថ្នាក់អនុបណ្ឌិត ២២ លើក (មន្ត្រី-បុគ្គលិកចូលរួម ២២ រូប)។

ជារួម សកម្មភាពបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេសនៅដើមឆ្នាំ២០២២ ភាគច្រើនត្រូវបានធ្វើឡើងតាមប្រព័ន្ធអនឡាញ។ ប៉ុន្តែនៅចុងឆ្នាំ២០២២ ភាពធូរស្បើយនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ បានអនុញ្ញាតឱ្យសកម្មភាពបណ្តុះបណ្តាលដោយផ្ទាល់ចាប់ផ្តើមកើនឡើងវិញជាបន្តបន្ទាប់។ បច្ចុប្បន្ន ការអភិវឌ្ឍធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជាបានលើកកម្ពស់ការយល់ដឹងទាំងផ្នែកចំណេះដឹងឯកទេសកម្ម និងជំនាញ ដើម្បីឆ្លើយតបទៅនឹងតម្រូវការការងារនិងការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងតំបន់ និងពិភពលោក។

## ៣- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ

សវនកម្មផ្ទៃក្នុង រួមទាំងការតាមដានការអនុវត្តតាមអនុសាសន៍របស់សវនដ្ឋាន និងអធិការកិច្ច គឺជាផ្នែកមួយដ៏សំខាន់នៃដំណើរការអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារជាតិនៃកម្ពុជា។ ក្នុងឆ្នាំ២០២២នេះ ការងារសវនកម្មនិងអធិការកិច្ចត្រូវបានអនុវត្តដល់ទីកន្លែងនិងសម្រេចតាមផែនការដែលបានគ្រោងទុក។ សវនកម្មត្រូវបានធ្វើឡើងនៅនាយកដ្ឋានចំនួន៣ នៅស្នាក់ការកណ្ដាលធនាគារជាតិនៃកម្ពុជា និងសាខាខេត្តចំនួន ៩ (ខេត្តកំពត ក្រចេះ ពោធិ៍សាត់ តាកែវ កំពង់ចាម បន្ទាយមានជ័យ ស្វាយរៀង កំពង់ធំ និងសៀមរាប)។ រីឯការងារអធិការកិច្ច ត្រូវបានអនុវត្តនៅគ្រប់សាខាធនាគារជាតិនៃកម្ពុជា រាជធានី-ខេត្តទាំង ១៩។

ដើម្បីរក្សានិរន្តរភាពប្រតិបត្តិការនៅសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តនៅពេលដែលប្រព័ន្ធសម្រាប់ធ្វើប្រតិបត្តិការមានបញ្ហា ធនាគារជាតិនៃកម្ពុជាបានរៀបចំផែនការនិរន្តរភាពធុរកិច្ចសម្រាប់អនុវត្តនៅសាខាធនាគារជាតិនៃកម្ពុជា។ គណៈកម្មការគ្រប់គ្រងហានិភ័យ បានបញ្ចប់ការពិនិត្យលើផែនការនិរន្តរភាពនេះ ក្រោយពីបានប្រជុំពិភាក្សា ចំនួន ១១លើក។

## ៤- សាខាធនាគារជាតិនៃកម្ពុជា

ប្រតិបត្តិការនៅតាមសាខារាជធានី-ខេត្តត្រូវបានពង្រឹងជាប្រចាំ ជាពិសេសលើការគ្រប់គ្រងចរាចរណ៍សាច់ប្រាក់នៅក្នុងប្រព័ន្ធធនាគារប្រកបដោយប្រសិទ្ធភាព តាមរយៈការផ្ដល់សេវាហិរញ្ញវត្ថុ ការគ្រប់គ្រងគណនី ការទទួលនិងបើកសាច់ប្រាក់ និងសេវាផ្ទេរប្រាក់ ជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រសួង-មន្ទីរ និងអង្គភាពរបស់រាជរដ្ឋាភិបាល។ ក្នុងគោលបំណងជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ក៏បានចូលរួមយ៉ាងសកម្មក្នុងការផ្ដល់សេវាប្ដូរក្រដាសប្រាក់រៀលចាស់ សឹក រេចរឹល ទក់រហែក ជូនដល់សាធារណជន។ ក្រៅពីនេះ សាខាធនាគារជាតិនៃកម្ពុជា រាជធានី-ខេត្ត ក៏បានតាមដានស្ថានភាពសេដ្ឋកិច្ចតាមបណ្ដាខេត្ត ដូចជាការប្រែប្រួលថ្លៃ អត្រាប្ដូរប្រាក់ និងសូចនាករម៉ាក្រូសេដ្ឋកិច្ចដទៃទៀត សម្រាប់ជាធាតុចូលលើការវិភាគស្ថានភាពសេដ្ឋកិច្ចជារួម និងការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។ ម្យ៉ាងទៀតមន្ត្រីជំនាញនៅតាមសាខាក៏បានចូលរួមក្នុងការផ្ដល់ព័ត៌មានអំពីការប្រើប្រាស់សេវាហិរញ្ញវត្ថុដល់សាធារណជន និងសម្របសម្រួលដោះស្រាយបណ្ដឹងអតិថិជនតាមប្រព័ន្ធហាត់ឡាញ។

**ក្រាហ្វ ១០៦ ៖ ស្ថិតិមន្ត្រី-បុគ្គលិកសាខារាជធានី-ខេត្ត**

(ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## សេចក្ដីសន្និដ្ឋាន

កំណើនសេដ្ឋកិច្ចកម្ពុជាបានបន្តងើបឡើង ដែលគាំទ្រជាចម្បងដោយវិស័យកម្មន្តសាល និងភាពប្រសើរឡើងជាលំដាប់នៃវិស័យទេសចរណ៍ ក្នុងពេលដែលវិស័យសំណង់និងអចលនទ្រព្យ និងវិស័យកសិកម្មមានកំណើនទាប។ ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន ដើម្បីរួមចំណែកជំរុញសកម្មភាពសេដ្ឋកិច្ច និងគ្រប់គ្រងសម្ពាធអតិផរណា ដែលបានទទួលរងឥទ្ធិពលពីការកើនឡើងថ្លៃប្រេងឥន្ធនៈនិងម្ហូបអាហារនៅលើទីផ្សារអន្តរជាតិ។ ក្នុងស្ថានភាពនេះ អត្រាប្ដូរប្រាក់ត្រូវបានរក្សាឱ្យមានស្ថិរភាព ដែលបានជួយការពារអំណាចទិញនៃប្រាក់រៀល និងរួមចំណែកកាត់បន្ថយសម្ពាធអតិផរណា។ ទុនបម្រុងអន្តរជាតិបានថយចុះបន្តិច ក្រោមឥទ្ធិពលនៃការប្រែប្រួលស្ថានភាពហិរញ្ញវត្ថុអន្តរជាតិ និងការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិក ប៉ុន្តែបន្តស្ថិតក្នុងកម្រិតខ្ពស់គ្រប់គ្រាន់។

ប្រព័ន្ធធនាគារមានសុខភាពល្អ ដោយស្ថានភាពដើមទុនមានភាពរឹងមាំ សន្ទនីយភាពស្ថិតក្នុងកម្រិតគ្រប់គ្រាន់ ហើយឥណទានមិនដំណើរការបានរក្សាក្នុងកម្រិតទាប។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានផ្ដល់ឥណទានដល់គ្រប់វិស័យ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងដំណាក់កាលស្ដារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩។ ជាមួយគ្នានេះ ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ បានបង្កើនប្រសិទ្ធភាពនិងសុវត្ថិភាពក្នុងប្រតិបត្តិការទូទាត់ ជាពិសេសតាមរយៈការទូទាត់អេឡិចត្រូនិក ព្រមទាំងបានលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងកាត់បន្ថយការទូទាត់ដោយប្រើប្រាស់សាច់ប្រាក់ ស្របតាមគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលរបស់រាជរដ្ឋាភិបាល។ អភិបាលកិច្ចល្អ ការអភិវឌ្ឍធនធានមនុស្ស និងគុណភាពសេវាធនាគារកណ្ដាល ត្រូវបានបន្តលើកកម្ពស់ជាប្រចាំ ដែលបានបង្កើនប្រសិទ្ធភាពការងារនិងគាំទ្រដល់ការរីកចម្រើនវិស័យធនាគារនិងសេដ្ឋកិច្ចជាតិ។ ក្រៅពីនេះ ការអប់រំផ្នែកហិរញ្ញវត្ថុនិងកិច្ចការពារអតិថិជន ត្រូវបានបន្តធ្វើឡើង និងបានបង្កើនការយល់ដឹងរបស់សាធារណជន និងអាជ្ញាធរមូលដ្ឋាន ពាក់ព័ន្ធនឹងការប្រើប្រាស់សេវាធនាគារនិងហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវនិងចំគោលដៅ ដើម្បីគាំទ្រអាជីវកម្មនិងជីវភាពរស់នៅរបស់ប្រជាជន។ ដោយឡែកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានបន្តពង្រឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា ដោយបានលើកកម្ពស់ក្របខ័ណ្ឌគតិយុត្តិ កាតព្វកិច្ចរាយការណ៍ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។

ក្នុងនាមកម្ពុជាជាប្រធានអាស៊ាន នៅឆ្នាំ២០២២ ធនាគារជាតិនៃកម្ពុជាបានរួមចំណែកជំរុញសមាហរណកម្មវិស័យធនាគារ ពង្រីកការតភ្ជាប់ប្រព័ន្ធទូទាត់ឆ្លងដែន និងពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់ ក្នុងក្របខ័ណ្ឌអាស៊ាន និងអាស៊ាន+៣ ទន្ទឹមនឹងការពង្រីកកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុដទៃទៀត ទាំងក្នុងតំបន់និងពិភពលោក។

# ផ្នែកទី២ - ទស្សនវិស័យ និងទិសដៅការងារឆ្នាំ២០២៣

## ទស្សនវិស័យនិងទិសដៅការងារឆ្នាំ២០២៣

សេដ្ឋកិច្ចពិភពលោកត្រូវបានរំពឹងថានឹងមានកំណើនទាបជាងឆ្នាំ២០២២ និងរុំព័ទ្ធដោយភាពមិនច្បាស់លាស់ជាច្រើន ដោយមូលនិធិរូបិយវត្ថុអន្តរជាតិបានព្យាករថាសេដ្ឋកិច្ចពិភពលោកឆ្នាំ២០២៣ អាចនឹងមានកំណើនត្រឹម ២,៧% ប៉ុណ្ណោះ ដែលក្នុងនោះសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍កើនឡើង ១,១% ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍[១] ៣,៧% និងអាស៊ាន-៥[២] ៤,៩%។ ហានិភ័យចម្បងៗ ដែលសេដ្ឋកិច្ចពិភពលោកអាចប្រឈម រួមមាន៖ i/-ការអូសបន្លាយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលអាចបន្តប៉ះពាល់ដល់ខ្សែច្រវាក់ផ្គត់ផ្គង់សកលនិងបន្តដាក់សម្ពាធលើអតិផរណា ii/-ការដំឡើងអត្រាការប្រាក់របស់ធនាគារកណ្តាលអាមេរិកបន្ថែមទៀត ដែលធ្វើឱ្យលំហូរមូលធនចេញពីប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ iii/-បញ្ហាដក់សល់ពីវិបត្តិជំងឺកូវីដ-១៩ ដូចជាការកើនឡើងបំណុលសាធារណៈនិងឯកជន និង iv/-គ្រោះមហន្តរាយធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

**ហានិភ័យនិងបញ្ហាប្រឈមនៃសេដ្ឋកិច្ចពិភពលោក**




ចំពោះកម្ពុជា យោងតាមការរំពឹងទុកប្រកបដោយភាពសុទិដ្ឋិនិយម ការវិលទៅរកភាពប្រក្រតីឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងកំណើនតម្រូវការពីខាងក្រៅនឹងបន្តគាំទ្រកំណើនសេដ្ឋកិច្ចកម្ពុជាឱ្យសម្រេចបានក្នុងរង្វង់ ៦% នៅឆ្នាំ២០២៣។ កំណើននេះ អាចរួមចំណែកដោយវិស័យចម្បងៗ ដូចជា៖ i/-វិស័យកាត់ដេរត្រូវបានរំពឹងថាមានកំណើន ៦,៩% ដែលគាំទ្រជាចម្បងដោយតម្រូវការខាងក្រៅ គួបផ្សំនឹងការដាក់ចេញវិធានការនិងយុទ្ធសាស្ត្រគាំទ្ររបស់រដ្ឋាភិបាលជាពិសេស យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើងនិងកាបូបកម្ពុជា ២០២២-២០២៧។ ទោះយ៉ាងណា កំណើនក្នុងវិស័យនេះអាចនឹងប្រែប្រួលប្រសិនបើសេដ្ឋកិច្ចអាមេរិកនិងអឺរ៉ុបធ្លាក់ចុះជាងការរំពឹងទុក ii/-វិស័យទេសចរណ៍ត្រូវបានរំពឹងថានឹងបន្តមានកំណើនខ្ពស់ ១៨,៥% ដោយសារ

[១] សេដ្ឋកិច្ចសហរដ្ឋអាមេរិកមានកំណើន ១,០% សហភាពអឺរ៉ុប ០,៥% ចក្រភពអង់គ្លេស ០,៣% និង ចិន ៤,៤%។

[២] អាស៊ាន-៥ រួមមាន ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និង វៀតណាម។

ការគ្រប់គ្រងការរាលដាលនៃជំងឺកូវីដ-១៩ យ៉ាងមានប្រសិទ្ធភាពនៅកម្ពុជា និងការបើកទទួលទេសចរឡើងវិញរបស់ប្រទេសក្នុងតំបន់ iii/-វិស័យកសិកម្មត្រូវបានព្យាករថានឹងមានកំណើនប្រមាណ ១,១% ដែលរួមចំណែកគាំទ្រការចូលជាធរមានកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី ព្រមទាំងការដករបាំងពន្ធនាំចូលអង្ករបស់កម្ពុជាទៅកាន់ទីផ្សារអឺរ៉ុប ខណៈដែលបញ្ហាប្រែប្រួលអាកាសធាតុនិងថ្លៃដើមផលិតកម្មខ្ពស់អាចប៉ះពាល់ដល់ការរំពឹងទុកខាងលើផងដែរ និង iv/-វិស័យសំណង់ត្រូវបានរំពឹងថានឹងបន្តមានកំណើនក្នុងរង្វង់ ១,៧% ដែលគាំទ្រជាចម្បងដោយកំណើនតម្រូវការក្នុងស្រុក ដែលផ្តោតលើទីផ្សារអចលនទ្រព្យលំនៅឋានដែលមានតម្លៃសមរម្យ។ ស្ថិតក្នុងដំណាក់កាលនៃការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩ ប្រព័ន្ធធនាគារត្រូវបានរំពឹងថានឹងនៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមគាំទ្រកំណើនវិស័យសំខាន់ៗនៃសេដ្ឋកិច្ច តាមរយៈការផ្តល់ហិរញ្ញប្បទាននិងសេវាហិរញ្ញវត្ថុនានា ដោយឥណទានត្រូវបានរំពឹងថានឹងមានកំណើនក្នុងអត្រា ២២% គួបផ្សំនឹងការបន្តអនុវត្តវិធានការគាំទ្រដទៃទៀត។ ទន្ទឹមនេះ ប្រព័ន្ធទូទាត់អេឡិចត្រូនិកដែលបាននិងកំពុងជួយសម្រួលអន្តរប្រតិបត្តិការរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងបានបង្កើនប្រសិទ្ធភាពក្នុងប្រព័ន្ធទូទាត់សងប្រាក់លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងរួមចំណែកសម្រួលដល់សកម្មភាពពាណិជ្ជកម្មនិងការវិនិយោគរវាងវិនិយោគិនក្នុងស្រុកនិងតំបន់ ក៏នឹងត្រូវបន្តធ្វើទំនើបកម្ម ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចកម្ពុជានៅក្រោយវិបត្តិ។

**ក្រាហ្វ ១០៧ ៖ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ**

(ឆ្នាំ១៩៩៥ - ឆ្នាំ២០២៥ព)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *សម្គាល់៖ ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

**តារាង ២ ៖ កំណើនសេដ្ឋកិច្ចកម្ពុជាតាមវិស័យ**

| | ឆ្នាំ២០២១ | ឆ្នាំ២០២២ប | ឆ្នាំ២០២៣ព |
|---|---|---|---|
| កសិកម្ម | ១,២% | ០,៧% | ១,១% |
| ឧស្សាហកម្ម | ៩,៤% | ៨,១% | ៨,១% |
| សេវាកម្ម | -២,៧% | ៤,៤% | ៥,៨% |
| **កំណើនផ.ស.ស** | **៣,០%** | **៥,១%** | **៦,០%** |

*សម្គាល់៖ ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

### តារាង ៣ ៖ ការព្យាករកំណើនសេដ្ឋកិច្ចកម្ពុជារបស់ស្ថាប័នអន្តរជាតិ

| | ឆ្នាំ២០២២ប | ឆ្នាំ២០២៣ព |
|---|---|---|
| រាជរដ្ឋាភិបាល | ៥,៤% | ៦,៦% |
| មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) | ៥,០% | ៥,៤% |
| ធនាគារពិភពលោក (WB) | ៤,៨% | ៥,២% |
| ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) | ៥,៣% | ៦,២% |

*សម្គាល់៖ ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

### កត្តាអំណោយផល និងបញ្ហាប្រឈមនៃសេដ្ឋកិច្ចក្នុងស្រុក



**កត្តាអំណោយផល**

+ ការកើនឡើងវិញនៃការវិនិយោគក្នុងតំបន់
+ មានទីតាំងភូមិសាស្ត្រនៅចំកណ្តាលអាស៊ាន
+ ការចូលជាធរមាននៃកិច្ចព្រមព្រៀង RCEP និងកិច្ចព្រមព្រៀងទ្វេភាគី
+ ការកើនឡើងការវិនិយោគក្នុងវិស័យកសិ-ឧស្សាហកម្ម
+ លទ្ធភាពខ្ពស់នៃវិស័យធនាគារក្នុងការឆ្លើយតបនឹងតម្រូវការហិរញ្ញប្បទានក្នុងនិងក្រោយពេលនៃវិបត្តិ
+ សេដ្ឋកិច្ចមានភាពបើកទូលាយនិងសមាហរណកម្មខ្ពស់
+ ស្ថិរភាពនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
+ កត្តាភាគលាភប្រជាសាស្ត្រ

**ហានិភ័យនិងបញ្ហាប្រឈម**

- កំណើនទាបជាងការរំពឹងទុកនៃសេដ្ឋកិច្ចពិភពលោក និងតំបន់ ជាពិសេសប្រទេសអឺរ៉ុប និងចិន
- ការកើនឡើងអតិផរណាដែលនឹងប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋ
- លំហូរចេញនៃមូលធនពីប្រទេសកំពុងលូតលាស់ និងកំពុងអភិវឌ្ឍ ដោយសារការរឹតត្បិតស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិ
- ការប្រែប្រួលអាកាសធាតុដែលអាចបន្ថយកំណើនក្នុងវិស័យកសិកម្ម
- ភាពមិនច្បាស់លាស់នៃការវិវត្តជំងឺកូវីដ-១៩
- ឧក្រិដ្ឋកម្មសាយប័រ

ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារកំណើនសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានកំណត់ទិសដៅការងារសំខាន់ៗសម្រាប់ឆ្នាំ២០២៣ មានដូចខាងក្រោម៖

## ១- ការអនុវត្តនយោបាយរូបិយវត្ថុ

- គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្រប
